ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦**

**ម៉ោង ០៩:០២នាទី**

**សវនាការលើកទី៤៧៥**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jan-2017, 10:19
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍

*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)

*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស

*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន

*(Mr. Nicolas KOUMJIAN)*

លោក សេង លាង

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE*)

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ (*Ms. Anta GUISSE*)

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ (*Mr. Calvin SAUNDERS*)

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍(*Ms.Marie GUIRAUD*)

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក សេង លាង | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| សាក្សី 2-TCW-1065 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-1065


សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី .......... ទំព័រ ២
សួរដោយលោក សេង លាង ផ្ដើមពី .......... ទំព័រ ២៩
សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី.......... ទំព័រ ៤៥
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.......... ទំព័រ ៦៦

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1065។ ហើយអង្គជំនុំជម្រះសូមបញ្ជាក់ជម្រាបជូនភាគី និងសាធារណជនជ្រាបថា ដោយលោកមេធាវី ចាន់ សម្បូរ មានធុរៈ ហើយថ្ងៃនេះ គឺជំនួសដោយលោកស្រីមេធាវី សុក សុជាតា ហើយមេធាវីប្រឹក្សាសាក្សី។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាព -- សែ កុលវុឌ្ឍី ឡើយរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម 2-TCW-1065។ សាក្សី និងមេធាវីប្រឹក្សាលោកស្រី សុក សុជាតា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះដែរ មិនមានសាក្សីបម្រុងនោះទេ។ សូមអរគុណលោកប្រធាន។

[០៩:០៣:៥៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយ

គាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និង ដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៦ បានកត់សម្គាល់អំពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះ វិលមុខ អង្គុយយូរមិនបាន និងផ្ដល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:១០]

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរសវនាការពីចម្ងាយ នៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរសំណួរមួយចំនួនទៅសាក្សី។ បាទ សូមអញ្ជើញលោកចៅក្រម!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួន ដើម្បីសួរលោក។ ជាដំបូងខ្ញុំចង់ឲ្យលោកបំភ្លឺនូវចំណុចមួយចំនួន។ កាលពីម្សិលមិញខ្ញុំមិនសូវយល់ថា តើលោកជាគ្រូពេទ្យ ឬក៏ជាគិលានុបដ្ឋាក? ហើយលោកដឹកនាំមន្ទីរពេទ្យហ្នឹង មន្ទីរពេទ្យ១៥៦ ឬក៏១៥៧?

**2-TCW-1065៖**

**ឆ៖** សូមអរគុណ។ ខ្ញុំសូមជម្រាបជូនថា ចំពោះខ្ញុំគឺជាប្រធានពេទ្យ ប្រធានពេទ្យ១៥៦ មិនមែនប្រធានពេទ្យ១៥៧ទេ គឺប្រធានពេទ្យ១៥៦ហ្នឹង។ សូមជម្រាបជូនប៉ុណ្ណឹង។

[០៩:០៦:៤២]

**ស៖** មន្ទីរពេទ្យ១៥៦នេះចំណុះឲ្យតំបន់ ឬក៏ភូមិភាគ? ហើយជាមន្ទីរពេទ្យយោធា ឬក៏មន្ទីរពេទ្យស៊ីវិល?

**ឆ៖** សូមអរគុណ។ ចំពោះមន្ទីរពេទ្យ១៥៦ គឺមន្ទីរពេទ្យចំណុះឲ្យកងពលលេខ៤ ផ្នែកខាងយោធា។ សូមអស់។

**ស៖** កាលពីម្សិលមិញលោកបាននិយាយថា នៅពេលណាមួយនោះ លោកក្លាយជាប្រធានវរសេនាធំ។ អ៊ីចឹងមានន័យថា លោកលែងធ្វើជាប្រធានមន្ទីរពេទ្យ ហើយចូលទៅធ្វើសកម្មភាពយោធាជាប្រធានវរសេនាធំ មែនទេ? ហើយបើអ៊ីចឹងមែន តើលោកប្តូរទៅធ្វើជាប្រធានវរសេនាធំនុ៎ង នៅពេលណាដែរ?

**ឆ៖** សូមអរគុណ។ ខ្ញុំសូមជម្រាបជូនអ៊ីចេះ ចាប់ពីថ្ងៃ២៥ ខែ៥ ៧៨ ដែលខ្ញុំឈប់ធ្វើជាប្រធានពេទ្យហ្នឹង ខ្ញុំចូលកាន់កងទ័ព ចូលកាន់កងទ័ព។ ៧៨ ថ្ងៃ២៥ ខែ៥ ៧៨ ចូលប្រយុទ្ធក្នុងសមរភូមិ។

**ស៖** អ៊ីចឹងចាប់ពីថ្ងៃទី២៥ ខែ៥ ឆ្នាំ១៩៧៨ហ្នឹងទៅ មេរបស់លោកមានផ្លាស់ប្តូរទេ ឬក៏មេរបស់លោកនៅតែដដែលទេ? ហើយអ្នកណាជាមេរបស់លោក?

[០៩:០៨:៣៣]

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា ឆ្នាំ -- ថ្ងៃ២៥ ខែ៥ ៧៨ហ្នឹង ពេលហ្នឹងហើយដែលពួកកម្ពុជាប្រជាធិបតេយ្យធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ា។ អ៊ីចឹងតាមក្រសួង តាមផ្នែកនានាទាំងអស់ គឺត្រូវរត់រប៉ាត់រប៉ាយហើយ ពេលនេះអត់មានមេ អត់មានកូនទេ។ គ្រប់ក្រសួង មន្ទីរ ស្ថាប័ននានា គឺធ្វើរដ្ឋប្រហារ ចាប់កម្មាភិបាល យុទ្ធជន។ អ៊ីចឹងទៅធ្វើមេនេះអត់មានអ្នកណាធំជាងខ្ញុំ មានតែខ្ញុំមួយគ្រប់គ្រងទាហានហ្នឹង។ មានតែខ្ញុំទេ កាលនុ៎ងបែកបាក់គ្នាអស់ហើយ រត់ ខ្លះរត់ទៅត្បូង ខ្លាំងទៅជើង អ្នកណារត់រួចក៏រួច អ្នកណាមិនរួច ក៏គេចាប់បានទៅ។ ហើយខ្ញុំគឺខ្លួនម្នាក់ឯតែម្តង ចាប់ផ្តើមរៀបចំទ័ព ដើម្បីប្រយុទ្ធ ពួក១ខ្មែរក្រហមឡើងវិញ។ សូមអស់យោបល់ហ្នឹង។ អត់មានអ្នកណាមេក្រៅពីខ្ញុំទេ អត់មានទេ មានតែខ្ញុំម្នាក់តែម្តង។

**ស៖** អ៊ីចឹងមុនថ្ងៃទី២៥ ខែ៥ ឆ្នាំ៧៨ហ្នឹង អ្នកណាជាមេផ្ទាល់របស់លោក?

**ឆ៖** អរគុណ។ សូមជម្រាបជូនមុនថ្ងៃ២៥ ខែ៥ ៧៨ហ្នឹង ដែលមេផ្ទាល់ហ្នឹងឈ្មោះ សំ នៀត ប៉ុន្តែស្លាប់ហើយ។ សំ នៀត មួយហើយនិងឈ្មោះ ឈឿន មួយប៉ុន្តែខ្ញុំភ្លេចត្រកូលហើយ ហ្នឹងដែលមេផ្ទាល់របស់ខ្ញុំ។

**ស៖** ពួកគេជាប្រធានកងពលតូច ឬក៏ប្រធានកងពលលេខ៤? ហើយពេលនុ៎ងតើ ហេង សំរិន គាត់ឈរជើងនៅឯណាដែរ?

**ឆ៖** រឿងនេះអ៊ីចេះ បើនិយាយពី សំ នៀត ហើយនិង ឈឿន ហ្នឹងឋានន្តរសក្តិគាត់ហ្នឹងត្រឹមប្រធានកងវរសេនាធំទេ។ ឯចំពោះកងពលវិញ បងហេង សំរិន ក៏គាត់ទីតាំងរបស់គាត់ឈរនៅក្រែកទេ។ ឯខ្ញុំ១៥៦ហ្នឹងឈរនៅភូមិ១ឡ គេហៅភូមិឡនៅខាងត្បូងក្រញូងហ្នឹង ទីតាំងគឺនៅហ្នឹង។ សូមអរគុណ។

[០៩:១១:១៦]

**ស៖** បាទ សូមអរគុណ។ មុនថ្ងៃទី២៥ ខែ៥ ឆ្នាំ៧៨ ពេលដែលលោកធ្វើជាប្រធានមន្ទីរពេទ្យយោធា តើលោកធ្លាប់ចូលរួមប្រតិបត្តិការយោធាទេ? លោកធ្លាប់ចូលរួមក្នុងការវាយប្រហារណាមួយទេ? ឬក៏តួនាទីលោកហ្នឹង គឺត្រឹមតែគ្រប់គ្រងមន្ទីរពេទ្យ ហើយទទួលព្យាបាលយោធាដែលរងរបួសទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា ចំពោះខ្ញុំវិញ គឺថាមន្ទីរទេព្យជួរមុខ ជួរមុខគេតែម្តង។ របួសចូលមក ឬសមរភូមិប្រយុទ្ធចាញ់ឈ្នះ គឺពេទ្យក៏ចូលរួមជាមួយដែរ។ គឺជួរមុខ ជួរមុខគេបង្អស់ហ្នឹង។ ហ្នឹងសូមជម្រាបជូនប៉ុណ្ណឹង អរគុណ។

**ស៖** ពេលដែលលោកថា លោកចូលរួមដែរហ្នឹង លោកជាពេទ្យជួរមុខហ្នឹង មានន័យថា លោកចូលទៅសមរភូមិប្រយុទ្ធគ្នាជាមួយនឹងគេដែរ មែនទេ?

**ឆ៖** អ៊ីចេះ អរគុណ។ សូមជម្រាបជូនថា ខ្ញុំនៅជួរមុខ ដូចថាឥឡូវហ្នឹងខ្សែត្រៀមនៅចម្ងាយហ្នឹង៥០ម៉ែត្រនៅខាងមុខ ឯខ្ញុំនៅខាងក្រោយ បន្ទាប់ពីខ្សែត្រៀមមក ខ្ញុំនៅខាងក្រោយ។ អាហ្នឹងប៉ុណ្ណឹងហ្នឹងបានន័យថានៅជួរមុខ ពេទ្យជួរមុខ។ បាទ អរគុណ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ត្រង់ចំណុចនេះ ខ្ញុំចង់ដឹងថា តើលោកផ្ទាល់ហើយនិងកូនចៅលោកហ្នឹងមានកាន់កាំភ្លើងទេ? ហើយពេលដែលលោកនៅសមរភូមិជួរមុខនោះ លោកមានបាញ់កាំភ្លើងទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា នៅជួរមុខគឺពេទ្យក៏មានកាំភ្លើងដែរ មានកាំភ្លើងដូចយុទ្ធជនប្រយុទ្ធដែរ មានដូចគ្នា។ ពេទ្យក៏ត្រូវការពារខ្លួនឯងដែរ។ ហ្នឹងសូមអរគុណ ជម្រាបជូនប៉ុណ្ណឹង។

**ស៖** ដូច្នេះមានន័យថា លោកមានកាំភ្លើង។ ហើយលោកក៏បាននិយាយអំពីប្រតិបត្តិការយោធាមួយចំនួន។ អ៊ីចឹងខ្ញុំចង់ដឹងថាខ្លួនលោកផ្ទាល់នេះ ធ្លាប់វាយលុកចូលទៅដល់ទឹកដីវៀតណាមទេ?

[០៩:១៤:១៥]

**ឆ៖** អរគុណ។ ចំពោះខ្លួនខ្ញុំផ្ទាល់ហ្នឹងគឺថា នៅខាងក្រោយ ខាងក្រោយខ្សែត្រៀមហ្នឹង ព្រោះពេទ្យហ្នឹងពេទ្យសម្រាប់សង្គ្រោះបន្ទាន់ដែលមានរបួស គ្រោះថ្នាក់ធ្ងន់ធ្ងរ គឺបញ្ជូនមកនៅខាងក្រោយហ្នឹង ចម្ងាយ៥០ម៉ែត្រខាងក្រោយហ្នឹង។ ហើយចំពោះខ្ញុំ អត់មានចូលប្រឡូកក្នុងការប្រយុទ្ធផ្ទាល់ជាមួយទាហានអត់មានទេ គឺនៅបន្ទាប់ខាងក្រោយហ្នឹង។ បាទអរគុណ។

**ស៖** ខ្ញុំនឹងត្រឡប់មកចំណុចនេះនៅពេលក្រោយ។ ឥឡូវនេះខ្ញុំចង់និយាយឡើងវិញអំពីបញ្ហានៃជម្លោះព្រំដែនរវាងកម្ពុជា-វៀតណាម។ បើខ្ញុំយល់មិនច្រឡំទេ គឺមានជម្លោះនៅភូមិភាគបូព៌ា ពីព្រោះថាភូមិមួយចំនួនហ្នឹង បាត់ចេញពីកម្ពុជា។ ដូច្នេះតើមានការពិនិត្យផ្ទៀងផ្ទាត់ ខ្សែព្រំដែនទេ? ហើយបើមាននោះ តើលោកដឹងទេថា អ្នកណាជាអ្នកចេញបញ្ជាឲ្យពិនិត្យខ្សែបន្ទាត់ព្រំដែននោះ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា បើនិយាយពីខ្សែព្រំដែនវិញ កន្លងមកភូមិមួយចំនួនវាបាត់ទៅហើយ ព្រោះមើលក្នុងផែនទី ព្រោះកាលឆ្នាំ២០១២ហ្នឹង ខាងតំណាងអង្គការសហប្រជាជាតិហ្នឹងក៏បានទៅធ្វើការជាមួយខ្ញុំ បានប្រគល់ផែនទីឲ្យខ្ញុំមើល ផែនទីហ្នឹង។ ដល់ខ្ញុំមើលទៅ ក្នុងផែនទីវាអត់មានឃើញខេត្ត -- អ៎! មានឃើញភូមិខ្មែរមួយចំនួន វាអត់នៅក្នុងផែនទីទេ វាបាត់។ ហើយបើជាក់ស្តែងយើងទៅនោះ វាបាត់មែន វាអត់ឃើញ។ ដល់អត់ឃើញអ៊ីចឹង អាហ្នឹងភូមិហ្នឹងមិនដឹងនៅត្រង់ណាអ៊ីចេះ។ អ៊ីចឹងបានយើងថាបាត់ បាត់ពីក្នុងផែនទីហ្នឹង។ បាទ អរគុណ។

[០៩:១៦:២៨]

**ស៖** ខ្ញុំចង់និយាយនៅឆ្នាំ៧៧ ឆ្នាំ៧៨ គឺមានន័យថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ រឿងខេត្តដែលកើតឡើងក្រោយរបបហ្នឹង ខ្ញុំមិនចាប់អារម្មណ៍ទេ។ ខ្ញុំចង់ដឹងថា ក្នុងអំឡុងរបបខ្មែរក្រហមនោះ តើមានការចេញបញ្ជាឲ្យមានការត្រួតពិនិត្យខ្សែបន្ទាត់ព្រំដែន ឬក៏បង្គោលគីឡូម៉ែត្រព្រំដែនទេ? ហើយបើមានការចេញបញ្ជាអ៊ីចឹងមែន ខ្ញុំសួរថា តើអ្នកណាជាអ្នកចេញបញ្ជាបែបហ្នឹង?

**ឆ៖** អរគុណ។ ចំពោះបញ្ហានេះ ចំពោះខ្លួនខ្ញុំ ខ្ញុំអត់ឮផ្ទាល់ទេ។ ប៉ុន្តែតាមរយៈបញ្ជាការដែល

នៅអង្គភាពជាមួយគ្នា គាត់និយាយ គេថា បញ្ហាពីភូមិភាគ ប៉ុន្តែខ្ញុំអត់ឮផ្ទាល់ទេ ប៉ុន្តែក្នុងបញ្ជាការហ្នឹង គាត់និយាយផ្ទាល់អ៊ីចឹង។ អ៊ីចឹងខ្ញុំឮតាមរយៈបញ្ជាការហ្នឹង បានពិនិត្យផ្ទៀងផ្ទាត់ខ្សែព្រំដែនហ្នឹង។ បាទ អរគុណ។

**ស៖** ខ្ញុំនឹងអានកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ <E3/10668> គឺសំណួរចម្លើយលេខ ២ គឺនៅផ្នែកខាងក្រោម ផ្នែកជិតចប់ ផ្នែកចុងក្រោយ។ ខ្ញុំសូមដកស្រង់៖ "ក្រោយពីការរំដោះទីក្រុងមក កម្ពុជាបានបែងចែកជាភូមិភាគ ក៏ប៉ុន្តែខ្ញុំនិយាយតែពីភូមិភាគបូព៌ា ដែលដឹកនាំដោយ សោ ភឹម។ គាត់បានបញ្ជាឲ្យអង្គភាពដែលនៅក្នុងភូមិភាគបូព៌ាហ្នឹង ឲ្យពិនិត្យមើលបង្គោលព្រំដែននៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ក៏ដូចជាកំពង់ចាម។ ភ្នាក់ងារស៊ើបការណ៍នៅគ្រប់អង្គភាព ត្រូវបានបញ្ជូនទៅឲ្យបំពេញបេសកកម្ម។ ពេលនោះក៏មានការឈ្លោះគ្នា ពាក់ព័ន្ធទៅនឹងបង្គោលដែលកំណត់ព្រំដែនរវាងកម្ពុជា និងវៀតណាម។" តើចំណុចនេះ ធ្វើឲ្យលោកនឹកឃើញឡើងវិញទេ? ឬក៏រឿងនេះ លោកធ្លាប់ស្តាប់ឮទេ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា រឿងនេះខ្ញុំគ្រាន់ជាអ្នកស្តាប់ឮទេ គ្រាន់តែស្តាប់ឮ តាមរយៈបញ្ជាការដែលនៅជាមួយគ្នាប៉ុណ្ណោះឯង។ បាទ អរគុណ។

[០៩:១៩:៣៣]

**ស៖** ពេលដែលលោកនិយាយអំពីមេបញ្ជាការ លោកនិយាយពីអ្នកណា? លោកនិយាយពីមេបញ្ជាការកងវរសេនាធំរបស់លោក ឬក៏លោកនិយាយអំពី សោ ភឹម?

**ឆ៖** អរគុណ។ ខ្ញុំសូមនិយាយអំពីបញ្ជាការវរសេនាធំរបស់១៥៦។ បាទ អរគុណ។

**ស៖** ចុះក្រោយមកនោះ លោកធ្លាប់ឮមាននិយាយថា មានការចរចាដើម្បីប៉ុនប៉ងដោះស្រាយបញ្ហាព្រំដែននេះដោយសន្តិវិធីទេ? លោកធ្លាប់ស្តាប់ឮ ឬក៏លោកជាអ្នកឃើញផ្ទាល់?

**ឆ៖** អរគុណ។ ចំពោះខ្លួនខ្ញុំ គឺខ្ញុំមិនបានៗឮទេ ហើយក៏មិនបានឃើញដែរ។ បាទ អរគុណ។

**ស៖** ខ្ញុំនឹងអានកំណត់ហេតុស្តាប់ចម្លើយរបស់លោកដដែលគឺ E3/10668 គឺចម្លើយទី២ លោកបានឆ្លើយដូចថា ដោយសារតែភូមិភាគបូព៌ាគិតថា វៀតណាមមិនគោរពបូរណភាពដែនដីរបស់កម្ពុជា គឺគេបានសម្រេចប្រើប្រាស់កម្លាំងយោធា។ ចំណុចនេះជាចំណុចដែលលោកដឹងដោយខ្លួនឯងផ្ទាល់ ឬក៏គេនិយាយប្រាប់លោកមានការប្រជុំប្រាប់អំពីបញ្ហាហ្នឹងទេ?

**ឆ៖** អរគុណ។ ចំពោះបញ្ហានេះគឺក្នុងបញ្ជាការកងវរសេនា៦ហ្នឹង កាលណាគេមកពីប្រជុំ

ហើយ គឺទៅប្រជុំក្នុងអង្គភាពវរសេនា៦ ដើម្បីផ្សព្វផ្សាយឲ្យដឹង ព្រោះខ្ញុំគ្រាន់តែរយ:ប៉ុណ្ណឹង។ បាទ អរគុណ លោកប្រធាន។

**ស៖** ខ្ញុំភ្លេចអានមួយឃ្លាអម្បាញ់មិញនេះ លោកនិយាយថា "ភូមិភាគបូព៌ាបានសម្រេចប្រើប្រាស់កម្លាំងយោធាក្រោយពីមានបរាជ័យខាងផ្នែកការទូត។" បន្ទាប់មកទៀតលោកបាននិយាយអំពីយុទ្ធនាការយោធាដែលបានកើតឡើងនៅឆ្នាំ១៩៧៧។ លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចបានទេថា លោកមានបានទទួលសេចក្តីណែនាំជាក់លាក់ណាមួយពាក់ព័ន្ធនឹងយុទ្ធនាការយោធានេះទេ? ហើយតើយុទ្ធនាការយោធាហ្នឹងមានគោលបំណងអ្វីដែរ?

[០៩:២២:៣៦]

**ឆ៖** អរគុណ។ ចំពោះការផ្សព្វផ្សាយនិងការយុទ្ធនាការហ្នឹង គឺដឹងតាមរយៈបញ្ជាការកងវរសេនាធំ។ កាលណាគេមកពីប្រជុំពីភូមិភាគហើយ ត្រូវតែផ្សព្វផ្សាយឲ្យអង្គភាពទាំងមូលត្រូវដឹង។ ដឹងតាមរយ:ហ្នឹង។ បាទ អរគុណ។

**ស៖** គេមានបានប្រាប់លោកទេថា តើយុទ្ធនាការយោធាដែលគេសម្រេចធ្វើនៅឆ្នាំ១៩៧៧ហ្នឹងមានគោលបំណងអ្វីខ្លះ? <តើគាត់មានបានបញ្ជាក់ប្រាប់លោកច្បាស់លើបញ្ហាហ្នឹងទេ?>

**ឆ៖** អរគុណ។ និយាយរួមអង្គភាពទាំងមូលគេប្រាប់ គេថា គោលបំណងរបស់ក្នុងភូមិភាគបូព៌ាទាំងមូលហ្នឹង ចុះបញ្ជាការហ្នឹង គាត់និយាយថា គាត់ថានឹងព្រមានឲ្យវៀតណាមឲ្យគោរពតាមព្រំដែនថាឲ្យគោរពតាមព្រំដែន ហ្នឹងគេគ្រាន់និយាយខ្លីប៉ុណ្ណឹង។ បាទ អរគុណ។

**ស៖** ខ្ញុំសូមបន្តអានចម្លើយរបស់លោកតទៅទៀតនៅក្នុងកំណត់ហេតុនោះ។ លោកថា៖ "នៅឆ្នាំ១៩៧៧ យុទ្ធនាការយោធាត្រូវបានចាប់ផ្តើមវាយវៀតណាមនៅគ្រប់មុខព្រួញ ដើម្បីព្រមានវៀតណាមថា កម្ពុជាមិនមែនខ្សោយដូចដែលពួកគេបានគិតនោះទេ។ នេះគឺជាការចាប់ផ្តើមសង្គ្រាមស៊ីសាច់ហុចឈាមរវាងវៀតណាមនិងកម្ពុជា។" ចំណុចនេះ<ដូចគ្នានឹងការចងចាំរបស់>លោក<>ទេ ថាមានការវាយប្រយុទ្ធគ្នានៅគ្រប់មុខព្រួញទាំងអស់? ហើយមានការសម្រេចថា ត្រូវវាយហ្នឹងនៅថ្ងៃណាទេ? ហើយការវាយវៀតណាមហ្នឹង មានបានកំណត់ថាត្រូវវាយវៀតណាមរហូតចូលទៅដល់ក្នុងទឹកដីវៀតណាមទេ?

[០៩:២៤:៥៦]

**ឆ៖** អរគុណ។ ចំពោះបញ្ហាហ្នឹង គឺៗវាយហ្នឹង វាយចូលទឹកដីវៀតណាមអត់មានកំណត់ទេ អត់មានកំណត់ទេ វាយហ្នឹង។ ហើយក្នុងវាយប៉ុន្មានថ្ងៃ ប៉ុន្មានខែក៏មិនកំណត់។ គ្រាន់តែបើកយុទ្ធនាការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដើម្បីព្រមាន។ អ៊ីចឹងយោបល់ខ្ញុំមានប៉ុណ្ណឹង។

**ស៖** ដូច្នេះបើខ្ញុំស្តាប់មិនច្រឡំទេ។ យុទ្ធនាការយោធានេះ គឺមានគោលដៅហ្នឹង គឺថាវាយចូលរហូតទៅដល់ទឹកដីវៀតណាមទៀត។ តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ ចំពោះការវាយហ្នឹង គឺថាអត់មានកំណត់ទេ។ ជួនកាលវាយចូលដីវៀតណាមក៏គេ គឺវាយដែរ ឲ្យតែអាចចូលបាន។ អ៊ីចឹងទិសដៅថា ឥឡូវកំណត់វាយប៉ុន្មានថ្ងៃ ប៉ុន្មានខែចូលត្រឹមណា អត់មានទេ ប៉ុន្តែវាយចូលដល់ប៉ុនណា ទៅប៉ុននុំង។ ហ្នឹង អរគុណ ហ្នឹងតាមខ្ញុំដឹង។

**ស៖** អ៊ីចឹងយុទ្ធនាការយោធាហ្នឹង មានគោលដៅវាយចូលទៅដល់ទឹកដីព្រំដែនឲ្យបានឆ្ងាយបំផុតមែនទេ? ហើយគោលដៅហ្នឹង គេកំណត់មុខសញ្ញាទៅរកជនស៊ីវិល ឬក៏ទៅរកទាហានវៀតណាម?

**ឆ៖** អរគុណ។ ចំពោះមុខសញ្ញារបស់ខ្ញុំ អត់មានគោលដៅទៅខាងស៊ីវិលអីទេ គឺវាយតែបន្ទាយទាហានតែម្តង អាហ្នឹង និយាយពីអង្គភាពខ្ញុំ។ ប៉ុន្តែអង្គភាពក្រៅពីហ្នឹង ខ្ញុំអត់បានដឹងទេ។ ហ្នឹងនិយាយចំពោះមុខព្រួញខ្ញុំទៅទេ ប៉ុន្តែក្រៅពីហ្នឹង អត់ដឹង។ បាទ អរគុណ។

**ស៖** ចុះលោកធ្លាប់ឮថា មានការវាយប្រហារទៅលើមុខសញ្ញាជនស៊ីវិលទេ? ឧទាហរណ៍ដូចជាភូមិ ឬក៏ផ្សារមួយចំនួននុំង នៅទឹកដីវៀតណាមហ្នឹង ត្រូវបានខាងទ័ពខ្មែរក្រហមហ្នឹងវាយប្រហារដែរនោះ?

[០៩:២៧:៣១]

**ឆ៖** អរគុណ។ ខ្ញុំធ្លាប់ឮ ប៉ុន្តែអត់ដឹង អត់ឃើញទេ ប៉ុន្តែធ្លាប់ឮគេនិយាយ ថានឹងវាយចូលផ្សារដូចជាផ្សារស្នាច់ ផ្សារអីហ្នឹង ផ្សារស្នាច់។ ហើយមិនដឹងជាអង្គភាពណាវ៉ៃ វាយចូល វាយអី យើងអត់ដឹងទេ ប៉ុន្តែឮៗ ប៉ុន្តែឲ្យឃើញជាក់ស្តែងនឹងភ្នែក យើងអត់ឃើញ។ បាទ អរគុណ។

**ស៖** លោកស្តាប់ឮអ្វីខ្លះ ពាក់ព័ន្ធនឹងផ្សារស្នាច់នេះ គេប្រុងវាយយ៉ាងម៉េច?

**ឆ៖** ចំពោះខ្ញុំ ខ្ញុំគ្រាន់តែឮវាយចូលផ្សារស្នាច់ ប៉ុន្តែគោលបំណងអ្នកវាយហ្នឹង វាយយ៉ាងម៉េចៗក៏ខ្ញុំមិនដឹងដែរ អត់ដឹងទេ ព្រោះយើងមិនបានសួរ ដឹកឫសដឹកគល់អំពីអ្នកប្រយុទ្ធចូល យើងអត់បានសួរទេ។ គ្រាន់តែឮគេនិយាយ តពីមាត់មួយទៅមាត់មួយ ថាគេនឹងវាយចូលផ្សារស្នាច់ប៉ុណ្ណោះ។ អរគុណ។

**ស៖** តើកងកម្លាំងដែលវាយប្រហារផ្សារស្នាច់ហ្នឹង ជាកងកម្លាំងរបស់កងពលលេខ៤ ឬក៏កងពលណាផ្សេង?

**ឆ៖** អរគុណ។ ចំពោះៗការវាយចូលផ្សារស្នាច់ហ្នឹង ជាៗកងទ័ពរបស់តំបន់ៗនីមួយៗ ព្រោះ

ហ្នឹងគេចែកខាងស៊ីវិលហ្នឹង ខាងតំបន់ទេ។ ឯកងពលហ្នឹង វាយឲ្យចំតែកន្លែងប្រដាក់អាវុធ និងកន្លែងទាហានតែម្តង។ ឯផ្សារហ្នឹង ខាងតំបន់ខាងអីទេ។ អរគុណ។

**ស៖** អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត បានស្តាប់ចម្លើយរបស់លោក។ នៅក្នុងកំណត់ហេតុ E3/10669 លោកបានផ្តល់ព័ត៌មានមួយចំនួន លោកបានគូសសម្គាល់នៅលើផែនទី គឺឯកសារ E3/10669.3។ ខ្ញុំមិនដឹងថាតើយើងអាចបង្ហាញផែនទីហ្នឹងលើអេក្រង់កុំព្យូទ័របានឬក៏អត់ លោកប្រធាន?

[០៩:៣០:១៣]

**ប្រធានអង្គជំនុំ៖**

បាទហើយ វ៉ាត យកឯកសារជូនសាក្សីពិនិត្យ ហើយសូមខាង អេ.វី ដាក់បង្ហាញឯកសារលើអេក្រង់ទូរទស្សន៍តាមសំណើសុំរបស់ចៅក្រម ឡាវ៉ែន៍។

អញ្ជើញលោកមេធាវី -- លោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ ខ្ញុំឆ្លៀតពេលកំពុងរៀបចំបញ្ហាបច្ចេកទេសនេះ ខ្ញុំចង់បញ្ជាក់ថា យើងនិយាយអំពីអង្គហេតុដែលមិននៅក្នុងដីកាដំណោះស្រាយហើយ វាចោទជាបញ្ហាហើយក្នុងការការពារក្តីនេះ។ ខ្ញុំមិនដឹងថាតើលោកចៅក្រម ឡាវ៉ែន៍ គាត់សួរសំណួរហ្នឹងមានគោលដៅទៅរកអ្វីទេ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ គឺគាត់សួរពាក់ព័ន្ធនឹងអង្គហេតុដែលស្ថិតនៅក្រៅដីកាដំណោះស្រាយ។ អ៊ីចឹងវាមានបញ្ហាផ្លូវច្បាប់ហើយ។ អ៊ីចឹងលោកចៅក្រមកំពុងតែសួរព័ត៌មានលម្អិតអំពីការវាយលុកចូលទៅក្នុងទឹកដីវៀតណាមហើយ វាអត់មាននៅក្នុងដីកាដំណោះស្រាយទេ លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ នេះគ្រាន់តែជាការកត់សម្គាល់ទេ។ ហើយ E3/10669.3។

[០៩:៣១:៥៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ ខ្ញុំគិតថាមេធាវី ហ្គីសសេ បានជំទាស់ ក៏ប៉ុន្តែអង្គជំនុំជម្រះបានឆ្លើយតបជាច្រើនដងមករួចមកហើយ គឺអង្គជំនុំជម្រះច្រានចោលនូវការជំទាស់នោះ ពីព្រោះថាយើងកំពុងតែពិនិត្យមើលជម្លោះ

ប្រដាប់អាវុធ។ អ៊ីចឹងវាអាចកើតមាននៅក្នុងទឹកដីខ្មែរ ក៏ដូចជានៅក្នុងទឹកដីវៀតណាម។

**ប្រធានអង្គជំនុំ៖**

អំមិញដូចសម្រេចរួចហើយ យើងភ័ន្តច្រឡំ យើងស្តាប់ខ្មែរ ដូចជាគ្រាន់តែជាការកត់សម្គាល់ទេ។ ហើយមកជំទាស់ទៀត ឥឡូវហ្នឹងងើបជំទាស់ទៅវិញ។

អញ្ជើញលោកស្រីមេធាវី មានបញ្ហាអីទៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ពាក់ព័ន្ធទៅនឹងការកត់សម្គាល់ចុងក្រោយរបស់លោកចៅក្រម ឡាវែន៍ អម្បាញ់-មិញនេះ គាត់ថាជម្លោះប្រដាប់អាវុធហ្នឹងវាពាក់ព័ន្ធទាំងផ្នែកទាំងពីរ។ ក៏ប៉ុន្តែបទចោទហ្នឹង គឺបានដកចេញនូវអង្គហេតុដែលពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅក្នុងទឹកដីវៀតណាម។ ដូច្នេះខ្ញុំចង់ឱ្យលោកចៅក្រមនិយាយអំពីជម្លោះប្រដាប់អាវុធជាទូទៅ។ បើដីកាដំណោះស្រាយមិនបានកំណត់អំពីចំណុចហ្នឹងផង ម៉េចក៏លោកចៅក្រមគាត់សួររឿងចំណុចនេះទៅវិញ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីយល់អំពីបញ្ហាជម្លោះប្រដាប់អាវុធ យើងត្រូវតែពិនិត្យមើលបញ្ហាទាំងមូល ទោះបីជាជនជាប់ចោទមិនត្រូវបានចោទប្រកាន់ពីអង្គហេតុដែលកើតនៅវៀតណាមក៏ដោយ។ ឥឡូវខ្ញុំបន្តទៅទៀត។

[០៩:៣៣:៣២]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី លោកបានឃើញផែនទីនេះហើយ។ លោកមានចាំថាលោកធ្លាប់បានសរសេរឬក៏គូសវាសអ្វីនៅលើផែនទីនេះទេ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះផែនទីនេះតូចពេក ខ្ញុំមើលអត់ឃើញទេនេះ មើលអត់ឃើញសោះ បើផែនទីធំអាចមើលឃើញ នេះមើលអត់ឃើញទេ ទាំងព្រិលទាំងអស់តែម្តង។

**ស៖** នៅក្នុងអេក្រង់កុំព្យូទ័រហ្នឹងមិនជាសំខាន់អ្វីទេ ខ្ញុំនឹងអានទីតាំងមួយចំនួនដែលលោកបានចង្អុលបង្ហាញនៅលើទឹកដីវៀតណាម។ លោកបានចង្អុលបង្ហាញអំពីភូមិត្នោត ភូមិស្នាច់ ភូមិស្វាយ ភូមិផល ភូមិ<ចាស់>។ លោកចាំថា លោកបានចង្អុលបង្ហាញទីតាំងទាំងអស់ហ្នឹងទេ? ហើយលោកចាំទេថានៅទីតាំងទាំងអស់ហ្នឹង មានហេតុការណ៍អ្វីកើតឡើងខ្លះ?

**ឆ៖** ចំពោះភូមិដែលខ្ញុំគូសនៅផែនទីហ្នឹង ព្រោះកន្លងមកខ្ញុំទៅភូមិនុ៎ង ប៉ុន្តែប៉ុន្មានឆ្នាំក្រោយមក ខ្ញុំមិនដែលទៅ មិនដឹងជាយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែពេលនោះ ខ្ញុំចុះទៅដល់កន្លែងនុ៎ង ចុះទៅនុ៎ង ប៉ុន្តែឥឡូវមិនដឹងជាទៅយ៉ាងណា យើងអត់ដឹងទេ ព្រោះវាប្រែប្រួលហើយ មិនដឹងជាទៅយ៉ាងម៉េចៗ យើងអត់ដឹង។

[០៩:៣៥:១៥]

**ស៖** កាលពីម្សិលមិញ ខ្ញុំបានផ្តល់ឲ្យលោកមើលនៅទូរលេខមួយចំនួន ខ្ញុំមិនដឹងថាតើលោកនៅមានជាមួយលោកទេ ឥឡូវនេះ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**2-TCW-1065៖**

**ឆ៖** អរគុណ។ ទូរលេខដែលឲ្យខ្ញុំៗពីម្សិលមិញ គឺនៅ នៅដៃខ្ញុំបាទ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ទូរលេខទី១ ដែលខ្ញុំចង់ពិនិត្យជាមួយលោក គឺមានលេខ E3/891 គឺទូរលេខ៦១ ផ្ញើជូន ម-៨៧០ ជាទីគោរពស្នេហា។ ទូរលេខនេះចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ ផ្ញើដោយឈ្មោះ ផុន។ "យើងខ្ញុំសូមជម្រាបជាបឋមនៅសមរភូមិផ្លូវលេខ២២ ដូចខាងក្រោមនេះ៖ មុខព្រួញផ្លូវលេខ២២ យើងបានវ៉ៃសម្រុកវាជាប់ តាំងពីថ្ងៃទី២៧-២៨ តុលា យប់មិញយើងបុកខ្លាំង ធ្វើឲ្យខ្មាំងបាក់ យើងដេញវាហួសត្រពាំងផ្លុង។ បច្ចុប្បន្នយើងម្ចាស់ការទាំងស្រុង តាមខ្សែការពារចាស់របស់យើងវិញហើយ។ យើងកំពុងដេញតាមខ្មាំង វ៉ៃសម្រុកចូលបន្ទាយលេខ២៧ទៀត។ ឯលទ្ធផលយើងខ្ញុំកំពុងធ្វើការបូកសរុប។" ទូរលេខនេះចម្លងជូនអ៊ំ អ៊ំនួន បងវ៉ាន់ បងវន បងខៀវ។ លោកមាននឹកឃើញអំពីហេតុការណ៍ដែលលោកបានធ្លាប់ចូលរួមដោយផ្ទាល់ ឬក៏លោកធ្លាប់ស្តាប់ឮទេ?

[០៩:៣៧:៣៧]

**ឆ៖**អរគុណ។ ឯកសារមួយចំនួនដែលផ្តល់ឲ្យខ្ញុំនេះ ខ្ញុំយកបានទៅសិក្សាមើល ឃើញថាឯកសារទាំងអស់ដែលធ្វើរបាយការណ៍ចេញពីឈ្មោះ ផុន នេះ បើនិយាយពី ផុន ហ្នឹងមិនមែននៅក្នុងភូមិភាគបូព៌ាទេ អត់មានទេ អត់មានបាទ។ ហើយឈ្មោះ អ៊ំៗ វាយអង្គុលីលេខហ្នឹង ឈ្មោះ អ៊ំ, ហើយអ៊ំនួន

ណា, បងវ៉ាន់ ហ្នឹង ខ្ញុំអត់ដែលឮទេ។ អត់ដែលឃើញទេ។ អ៊ីចឹងនៅភូមិភាគណាផ្សេងហើយ។ មិនដឹងជាភូមិភាគណា ខ្ញុំអត់បានស្គាល់ទេ។ អ៊ីចឹងរឿងទាំងអស់ ដែលកើតនៅភូមិភាគបូព៌ាហ្នឹង គឺនៅខ្សែទី១ ហ្នឹង គឺឈ្មោះ ឆុន តែម្ដងជាអ្នកៗដែលជាប់ក្នុងការរឿងកាប់សម្លាប់ហ្នឹងហើយ ប៉ុន្តែរឿងទាំងអស់គឺឈ្មោះ ឆុន ហ្នឹង។ ឥឡូវឯកសារទាំងអស់ ដែលចៅក្រមលោកបានប្រគល់ឲ្យខ្ញុំហ្នឹង ឯកសារណាមួយក៏ឈ្មោះ ឆុន ដែរ។ ហើយរាយការណ៍មកឈ្មោះ អ៊ំ, អ៊ំនួន ហ្នឹង។ ហើយនៅភូមិភាគបូព៌ាហ្នឹង គ្មានអ្នកណាគេសូវនិយាយហៅ អ៊ំ អ៊ីចឹងទេ អត់មានទេ អត់មានទេ។ ហើយគេរាយអង្គុលីលេខក៏អ៊ីចឹង។ ហ្នឹងបើយើងពិនិត្យមើលតាមអង្គុលីលេខ។ អ៊ីចឹងមនុស្សនេះ មនុស្សនៅភូមិភាគផ្សេងៗ ក្រៅពីភូមិភាគបូព៌ាហើយ។ ហើយចំពោះខ្ញុំអត់បានស្គាល់ អត់បានដឹងទាំងអស់។ អរគុណ។

**ស៖** លោកចង់មានន័យថា អ្នកទាំងអស់ហ្នឹងមកពីភូមិភាគផ្សេង ក្រៅពីភូមិភាគបូព៌ាមែនទេ? ព្រោះក្នុងនេះ គេនិយាយអំពីទីតាំងមួយចំនួនដែលស្ថិតនៅក្នុងភូមិភាគបូព៌ា ហើយលោកថា ឆុន នៅសមរភូមិ។ អ៊ីចឹងខ្ញុំដឹងថា សមរភូមិហ្នឹងគឺវានៅក្នុងភូមិភាគបូព៌ាហ្នឹងហើយ។

[០៩:៣៩:៣៧]

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់បន្តិច ព្រោះលោកក៏មានការងឿងឆ្ងល់ដែរ បញ្ហានេះ ហើយខ្ញុំក៏មានការងឿងឆ្ងល់ដែរ។ ប៉ុន្តែទើបនឹងបានទទួលឯកសារនេះ ឯកសារចុងក្រោយហ្នឹង គឺឈ្មោះ ឆុន ទាំងអស់ ឈ្មោះ ឆុន ទាំងអស់ ហើយរាយការណ៍ហ្នឹងឲ្យ អ៊ំ, អ៊ំនួន ហើយខ្ញុំក៏មិនដឹង នួន ណាដែរ។ ឥឡូវសូមសម្រាបជូនអ៊ីចេះ ដើម្បីឲ្យងាយយល់ ទាំងខ្ញុំ ទាំងលោកចៅក្រម។ សភាពការណ៍កើតឡើងនៅភូមិភាគបូព៌ាវាអ៊ីចេះ ដំបូងឡើយ ដំបូងឡើងរវាងភូមិភាគបូព៌ាទេ--

**ចៅក្រម ក្លូឌា ហ្វេនស៖**

សូមទោស គឺថាវាមិនមានការបកប្រែទៅជាភាសាអង់គ្លេសទេ។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទ ចាប់ផ្ដើមសាជាថ្មី ហើយសូមលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ រៀបចំសំណួរសាជាថ្មី។ ហើយសូមបញ្ជាក់ថា គួរតែសួរគាត់ឲ្យបានច្បាស់លាស់ ហើយគោលបំណងនៃការសួរគឺសួរលើខ្លឹមសារនៃទូរលេខនោះ ថាតើវាឆ្លុះបញ្ចាំងអំពីព្រឹត្តិការណ៍ដែលកើតមានឡើងនៅៗខាងបូព៌ា ឬក៏ព្រឹត្តិការណ៍នៅតំបន់កន្លែងណាមួយដែលលោកសាក្សីស្គាល់។ ហើយចំពោះ ឆុន ហ្នឹងគឺបានច្បាស់

ហើយ ព្រោះសាក្សីប្រកែកថាមិនស្គាល់។ សំខាន់គឺព្រឹត្តិការណ៍ ព្រឹត្តិការណ៍ហេតុការណ៍ដែលកើតមានឡើងដែលមាននៅក្នុងខ្លឹម ដូចខ្លឹមសារក្នុងរបាយការណ៍ នៅក្នុងសារទូរលេខនោះ តើវាផ្ទុះបញ្ជាំងថាមានហេតុការណ៍ហ្នឹងកើតឡើងទេ តាមការដឹង ការឮរបស់សាក្សី នោះជារឿងអាចច្បាស់លាស់ជាង។ អ៊ីចឹងគឺនៅតែជជែករឿងតែមួយ គឺតែឈ្មោះ ផុន ទេ។ យើងយល់ថាឈ្មោះ ផុន ហ្នឹងគឺលោកមិនស្គាល់ទេ ប៉ុន្តែសំខាន់ផងដែរគឺព្រឹត្តិការណ៍ ហេតុការណ៍ដែលកើតមានឡើងនៅក្នុង សរសេរនៅក្នុងសារទូរលេខ។

លោកចៅក្រម ហ្សង់ម៉ាក អាចរៀបសួរឡើងវិញ ព្រោះយូរហើយ អាចភ្លេចហើយ។

[០៩:៤៥:៤០]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** បាទ ខ្ញុំសូមបញ្ជាក់លេខម្តងទៀត គឺឯកសារហ្នឹងគឺលេខ E3/891 គឺចុះហត្ថលេខាដោយឈ្មោះ ផុន ហើយមាននិយាយអំពីការវ៉ៃសម្រុកចូលបន្ទាយលេខ២៧។ កាលពីម្សិលមិញនេះ លោកក៏បាននិយាយអំពីបន្ទាយលេខ២៧ហ្នឹងដែរ។ លោកអាចបញ្ជាក់បានទេ ថាបន្ទាយលេខ២៧ហ្នឹង មានទីតាំងនៅកន្លែងណា? ហើយហេតុអីបានជាគេវ៉ៃចូលទៅបន្ទាយហ្នឹង?

2-TCW-1065៖

**ឆ៖** អរគុណ។ ខ្ញុំបានទទួលលោកចៅក្រម លោកអនុញ្ញាត និងផ្តល់ឯកសារមួយចំនួនឲ្យខ្ញុំទៅសិក្សាមើល។ ខ្ញុំកាន់មានតែយល់ យល់កាន់តែច្រើន។ ពីមុនខ្ញុំយល់ថា អ្នកណាដែលធ្វើរដ្ឋប្រហារនៅបូព៌ាហ្នឹង។ ខ្ញុំក៏នៅមានការងឿងឆ្ងល់ដែរ ប៉ុន្តែខ្ញុំនិយាយមួយកំណាត់ៗ អ៊ីចឹងលោកចៅក្រមគាត់ពិបាកក៏នៅតែឆ្ងល់ដែរ ក៏ពិបាកយល់ដែរ--

**ប្រធានអង្គជំនុំ៖**

លោកចាំស្តាប់សំណួរឲ្យបាន បើស្តាប់សំណួរមិនបាន លោកអាចសួរឡើងវិញ ហើយបើលោកមិនដឹងទេ លោកអាចឆ្លើយថាមិនដឹង។ លោកជាសាក្សី លោកស្តាប់សំណួរឲ្យបាន ឆ្លើយតបនឹងសំណួរ ចាំបាច់ឆ្លើយតបនឹងសំណួរបានហើយ។ ហើយលោកថា មិនដឹងព្រឹត្តិហេតុហ្នឹងទេ គឺលោកឆ្លើយថា មិនដឹង។ ហើយលោកស្គាល់ទេ គឺបើឈ្មោះហ្នឹង មិនស្គាល់ទេ ឈ្មោះទីតាំងក៏ដោយ ឈ្មោះអីមិនស្គាល់ទេ គឺលោកឆ្លើយថា មិនស្គាល់ទៅ គឺចប់ហើយ។ នេះជាចម្លើយសមស្របនៅក្នុងនីតិវិធីតាមផ្លូវតុលាការ។

ចាំស្តាប់សំណួរម្តងទៀត សូមរៀបចំសំណួរម្តងទៀត។ លោកម្សិលមិញ លោកឆ្លើយរួចហើយ

មន្ទីរ២៧ហ្នឹង គឺឆ្លើយជាមួយសំណួររបស់យើងរួចហើយ។ គ្រាន់តែសួរបញ្ជាក់បន្ថែមទេ គឺបានឆ្លើយច្បាស់ណាស់ ហើយលោកជាអ្នកដឹកនាំកម្លាំងទៅវៃនៅទីនោះ គ្រាន់តែមិនបែកអ៊ីចឹង គឺថាលោកបានឆ្លើយច្បាស់ហើយ។ ប៉ុន្តែគឺលោកចៅក្រមបរទេស លោកស្តាប់ទំនងមិនច្បាស់លាស់លើបញ្ហានេះ ឬក៏គាត់មានចំណុចចង់បញ្ជាក់បន្ថែមឲ្យច្បាស់ អ៊ីចឹងគឺសុំសួរបញ្ជាក់លើចំណុចនេះ ណា៎! សំខាន់គឺចង់ស្គាល់ទីតាំង ទីតាំងនៃបន្ទាយ២៧របស់វៀតណាមនោះ។

[០៩:៤៨:០៥]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ព្រោះថាពីម្សិល ចំពោះបញ្ហាទីតាំងក៏ខ្ញុំនិយាយរួចហើយ បន្ទាយ២៧ហ្នឹង។ ប៉ុន្តែខ្ញុំមិនដឹងជាប៉ុន្មានម៉ែត្រចេញពីព្រំដែនទេ ខ្ញុំប៉ាន់ស្មានរួចហើយ ជម្រាបលោកចៅក្រមអ៊ីចឹង។ អា ហ្នឹងហើយសូមជម្រាបជូនប៉ុណ្ណឹង។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកអាចជម្រាបបានទេថា បន្ទាយហ្នឹងនៅក្នុងទឹកដីវៀតណាម ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញ! យ៉ាងម៉េចទៅលោកមេធាវី វ៉ិចទ័រ កូប៉េ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន។ នេះជាការកត់សម្គាល់ខ្លីមួយពាក់ព័ន្ធទៅនឹងការបកប្រែជាភាសាអង់គ្លេស គឺឯកសារ E3/891 គឺបកប្រែទៅគឺថាមានកំហុសមែនទែន ជាពិសេសកាលបរិច្ឆេទនៃសារទូរលេខនេះ ដែលចុះហត្ថលេខាដោយ ឆុន គឺសរសេរថាឆ្នាំ១៩៧៨ តាមការពិត១៩៧៧ទេ។ អ៊ីចឹងឆ្នាំនេះគឺថាខុសដល់ទៅពីរដង។ ហើយការបកប្រែសំណេរជាអង់គ្លេសនេះ គឺនិយាយថា<បន្ទាយ>២២ គឺតាមការពិតនៅ<បន្ទាយ>២៧<> នោះទៅវិញទេ។

[០៩:៤៩:៤៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីឲ្យបានច្បាស់ទាំងអស់គ្នា ទូរលេខដែលខ្ញុំបានអានលេខកាលពីម្សិលមិញ <ឬដែលបាន> ប្រគល់ជូនសាក្សីនៅថ្ងៃនេះ គឺមាននិយាយអំពីបន្ទាយ២៧ទាំងអស់។ ខ្ញុំមិនដឹងថាតើជាមន្ទីរ ឬក៏អីទេជាភាសាខ្មែរនោះ ឬបន្ទាយ ប៉ុន្តែជាភាសាបារាំងហ្នឹងគឺបន្ទាយ បន្ទាយលេខ២៧។ អ៊ីចឹងខ្ញុំចង់ដឹងថា កន្លែង

ហ្នឹងជាកន្លែងយុទ្ធសាស្ត្រយោធារបស់វៀតណាមមែនទេ?

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី លោកអាចជម្រាបឱ្យបានច្បាស់បន្តិចពាក់ព័ន្ធនឹងបន្ទាយ២៧ហ្នឹងទេ? តើបន្ទាយលេខ២៧ហ្នឹង មានតួនាទីអ្វីខ្លះ? ហើយមានមុខងារអ្វីខ្លះ? ជាកន្លែងការពារ ជាបន្ទាយការពាររបស់វៀតណាម ឬក៏យ៉ាងម៉េច?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះលោកចៅក្រមថាសួរថា ខ្ញុំថាបន្ទាយ២៧ហ្នឹងជាបន្ទាយយ៉ាងម៉េច? ឯចំពោះខ្ញុំក៏មិនដឹងយ៉ាងម៉េច ប៉ុន្តែបន្ទាយនេះជាបន្ទាយរបស់វៀតណាម គេការពារប្រជាជនគេនៅនុ៎ង។ គឺនៅទឹកដីវៀតណាមបន្ទាយហ្នឹង។ អរគុណ។

**ស៖** តើយុទ្ធសាស្ត្ររបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ គឺមានគោលដៅវាយសម្រុក ហើយនិងវាយបកមែនទេ? គឺយុទ្ធសាស្ត្ររបស់គេ គឺអ៊ីចឹងមែនទេ? គឺមានការវាយសម្រុកចូល គឺអាចដឹកនាំកម្លាំងលុកលុយចូលទៅវៀតណាម ហើយមានការរុញ វាយរុញវៀតណាមដែលចូលមកលុកលុយកម្ពុជា។ អ៊ីចឹងតើកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ គឺមានយុទ្ធសាស្ត្រអ៊ីចឹងមែនទេ?

[០៩:៥២:០៧]

**ឆ៖** អរគុណ។ ចំពោះយុទ្ធសាស្ត្រនេះ ខ្ញុំបាទអត់ដឹងទេ។ រឿងយុទ្ធសាស្ត្រវាយយ៉ាងម៉េច ចូលយ៉ាងម៉េច អាហ្នឹងអត់ដឹងទេ ព្រោះការធ្វើមិនមែនតែត្រឹមកងពល ឬកងអនុសេនាធំទេ អាហ្នឹងវាផែនការរបស់ខាងគេ ខាងខ្ញុំអត់ដឹងទេ។ មិនដឹងជាយុទ្ធសាស្ត្រគេយ៉ាងម៉េច យើងអត់ដឹងទេអាហ្នឹង។ អរគុណ។

**ស៖** ខ្ញុំមិនមានពេលពិនិត្យមើលទូរលេខទាំងអស់ទេ ក៏ប៉ុន្តែខ្ញុំចង់ឱ្យលោកពិនិត្យមើលទៅលើទូរលេខដែលគេបានបង្ហាញជូននៅក្នុងពេលស្ដាប់ចម្លើយរបស់លោកគឺ ខ្ញុំចង់ឱ្យលោកពិនិត្យមើលឯកសារ E3/10669.1។ លោកមានទូរលេខហ្នឹងនៅនឹងដៃលោកទេ? គឺទូរលេខលេខ E3/10669.1។

**ឆ៖** បាទ អត់មានទេចំពោះខ្ញុំ។

**ស៖** ខ្ញុំអត់មានឯកសារហ្នឹងជាភាសាខ្មែរផង អ៊ីចឹងខ្ញុំទៅមុខទៀត។ លោកសាក្សី លោកធ្លាប់បានជួប សោ ភឹម ដូច្នេះលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ពេលដែលលោកជួបគាត់នោះ លោកមានអារម្មណ៍ថា គាត់ព្យាយាមធ្វើយ៉ាងម៉េចដៀសវាងវាយប្រហារកងទ័ពវៀតណាម ឬក៏គាត់មានបំណងវាយប្រហារទៅលើកងទ័ពវៀតណាម?

**ឆ៖** អរគុណ។ ចំពោះរូបខ្ញុំផ្ទាល់ ការជួបជាមួយ សោ ភឹម នេះវាគ្មាននិយាយអីពាក់ព័ន្ធតែរឿងខ្មែរ-វៀតណាម អត់មានទេ គ្រាន់តែជួបជុំនិយាយក្នុងនាមគ្រួសារ ក្នុងនាមគ្រួសារ និយាយលេងធម្មតា។ ពាក់ព័ន្ធខាងនយោបាយ បច្ចេកទេស វាអត់មាន អត់មានទេ។ គ្រាន់និយាយលេងជួបជុំក្នុងគ្រួសារពីនេះពីនោះហ្នឹង អាចនិយាយបាន ប៉ុន្តែក្នុងផ្លូវការ អត់មានទេ។ បាទ អរគុណ។

[០៩:៥៥:០៧]

**ស៖** លោកបាននិយាយអំពីរដ្ឋប្រហារនៅថ្ងៃទី២៥ ខែ៥ ឆ្នាំ៧៨។ ខ្ញុំចង់ដឹងថា រហូតមកដល់ថ្ងៃហ្នឹង ឬក៏ក្រោយមកហ្នឹងទៀត លោកមានអារម្មណ៍ថា កងទ័ពភូមិភាគបូព៌ា មានបំណងជៀសវាងការវាយប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាម ឬក៏ពួកគេព្យាយាមវាយប្រហារស៊ីសាច់ហុតឈាមគ្នាជាមួយនឹងកងទ័ពវៀតណាម?

**ឆ៖** អរគុណ។ ចំពោះបញ្ហាភូមិភាគបូព៌ាវាអ៊ីចេះ។ អ៊ីចឹងបានខ្ញុំចង់ជម្រាបជូន។ រឿងផែនការប្រយុទ្ធស៊ីសាច់ហុតឈាមគ្នា តស៊ូយូរអង្វែងម៉េច ខាងខ្ញុំបាទអត់ដឹងទេ ប៉ុន្តែរឿងអី ខ្ញុំចង់ៗជម្រាបជូនចៅក្រមរឿងនេះមួយ ព្រោះលោក ពីមុនលោកបានសួរថា ឈ្មោះ ឆុន មករាយការណ៍នៅភូមិភាគបូព៌ាចុះមូលហេតុអីបាន ឆុន ហ្នឹង? ហើយខ្ញុំបដិសេធថា មនុស្ស ឆុន ហ្នឹង មិនមែននៅក្នុងភូមិភាគបូព៌ាទេ។ ហើយចុះម៉េច ឆុន បានរាយការណ៍ក្នុងសមរភូមិបូព៌ា? រឿងនេះ បើថ្ងៃ២៥ ខែ៥ ៧៨ហ្នឹង ខាងៗមជ្ឈិមហ្នឹង ឥឡូវខ្ញុំថាមជ្ឈិមទៅចុះ បានបញ្ជូនភូមិភាគកណ្ដាលមកនុ៎ង ឈ្មោះ កែ ពក ហ្នឹង។ មកដំបូងមនុស្សដូច លោកចៅក្រម លោក--

[០៩:៥៦:៣៨]

**ប្រធានអង្គជំនុំ៖**

នែស្ដាប់ឱ្យយល់! បញ្ហាទី១ គឺសួរនៅក្នុងព្រឹត្តិការណ៍នៃអង្គហេតុ ព័ត៌មានទាំងឡាយដែលកើតមាននៅក្នុងសារទូរលេខនេះ ឆ្លុះបញ្ចាំងអំពីរឿងពិតដែលលោកដឹង ថាតើរឿងហេតុទាំងឡាយដែលគេរាយការណ៍អ៊ីចេះ វាកើតឡើងនៅទីនុ៎ងទេ ទី១។ ទី២ សំណួរអំមិញ គឺសួរទូទៅ អំពីបញ្ហាបំណង គោលបំណងនៃការវាយលុកហ្នឹង ខ្មែរហ្នឹងគឺមានចេតនាវាយលុកទៅខាងវៀតណាម ឬក៏យ៉ាងម៉េច? ឬមួយក៏គ្រាន់តែទប់ ខ្ទប់ ទល់ទេ គ្រាន់តែទប់ការងារដែនដីរបស់ខ្លួនទេ មិនមានចេតនាវាយទេ។ ហ្នឹងជាទូទៅការកត់សម្គាល់ ការសង្កេតឃើញរបស់លោកនៅក្នុង លោកនៅសមរភូមិ។ ហើយអង្គជំនុំជម្រះមិនសួរបញ្ហាឈ្មោះ ឆុន ហ្នឹងទៀតទេ គឺផ្អែកលើឯកសារនេះ គ្រាន់តែសួរព្រឹត្តិការណ៍ដែលកើតមានឡើង ព្រោះ

ឯកសារនេះ ជាឯកសារភស្តុតាងនៅក្នុងសំណុំរឿង។

លោកយល់ទេ? លោកយល់សំណួរទេ ស្តាប់សំណួរសិន។ សំណួរឲ្យបាន សឹមលោកឆ្លើយ។ អរគុណណាស់ អង្គជំនុំជម្រះឃើញលោកចូលចិត្តនិយាយ ប៉ុន្តែក៏និយាយនៅក្នុងលក្ខខណ្ឌត្រឹមត្រូវ ជាភាពចាំបាច់ តបទៅនឹងចំនឹងសំណួរដែរ មិនមែនទៅនិយាយទៅតាមចិត្តចង់នោះទេ។

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ រៀបចំសំណួរសាជាថ្មីម្តងទៀត សំណួរចុងក្រោយរបស់លោក។ ហើយឯកសារទាំងអស់នេះគឺមានតែឆ្នាំ១៩៧៧ ហើយបើ៧៨ហ្នឹងគឺខែ១អីទេ មិនមែនក្រោយថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ទេ។ លោកមើលកាលបរិច្ឆេទឯកសារហ្នឹង គឺច្បាស់លាស់ ហើយដើម្បីលោកឆ្លើយ។ កាលបរិច្ឆេទក្នុងសារនេះ គឺមានតែត្រឹមភាគច្រើន គឺតែនៅក្នុងឆ្នាំ១៩៧៧ទេ។ ហើយលោកចេះតែច្រឡំ១៩៧៨ គឺខ្លួនឯង។ បើ៧៨ ក៏មានតែឯកសារមួយទេ ដែលវាត្រឹមខែ១ ឆ្នាំ១៩៧៨។

[០៩:៥៨:៥៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី លោកបានអានទូរលេខទាំងអស់ហ្នឹងហើយ អ៊ីចឹងលោកដឹងអ្វីខ្លះ ពាក់ព័ន្ធនឹងការវាយប្រហាររបស់កងទ័ពភូមិភាគបូព៌ាទៅលើកងទ័ពវៀតណាមនោះ?

2-TCW-1065៖

**ឆ៖** អរគុណ។ ចំពោះខ្ញុំ អត់មានដឹងអីច្រើនទេ ដឹងតែផែនការគេយកកងទ័ពទៅប្រយុទ្ធ ដឹងតែប៉ុណ្ណឹង អត់មានដឹងថា អូ!ផែនការហ្នឹងវាយទៅយ៉ាងម៉េច យ៉ាងម៉េច ខ្ញុំអត់បានដឹងទេ។ បាទ អរគុណ។

**ស៖** លោកជាប្រធានមន្ទីរពេទ្យយោធា ខ្ញុំគិតថា ប្រាកដជាមានអ្នករបួសច្រើនហើយ។ អ៊ីចឹងខ្ញុំចង់ដឹងថា មានអ្នកស្លាប់ច្រើនទេ? អ្នករបួសច្រើនប៉ុនណាដែរ? ហើយអ្នកដែលរងរបួសហ្នឹង របួសប្រភេទណាដែរ? របួសដោយសារកាំភ្លើងធំ ឬក៏យ៉ាងម៉េច? ព្រោះថាទូរលេខមួយនោះក៏បាននិយាយអំពីការបោកគ្រាប់បែកផ្សែង។ អ៊ីចឹងខ្ញុំ អ៊ីចឹងចង់ដឹងថាតើនៅក្នុងពេលនុ៎ងមានការបោកគ្រាប់បែកទេ បោកផ្សែងពុល គ្រាប់បែកផ្សែងពុល? គឺឯកសារ E3/922 អ៊ីចឹងខ្ញុំចង់សួរលោកបញ្ជាក់ ថាពេលវាយប្រយុទ្ធហ្នឹង មានការបោកគ្រាប់បែកផ្សែងពុលទេ?

[១០:០០:៤០]

**ឆ៖** អរគុណ។ ចំពោះនៅមន្ទីរពេទ្យ ការរបួសវាតែងតែមានហើយ មិនមែនអត់ទេ។ របួសស្លាប់ មិនស្លាប់ ក៏វាតិចដែរ មិនមែនច្រើនទេ។ ធម្មតាធ្វើសង្គ្រាម បើតែស្លាប់មនុស្សច្រើន ក៏មិនអាចធ្វើ

កើតដែរ។ វាមានស្លាប់ខ្លះ របួសខ្លះ ហើយចំពោះខ្ញុំផ្ទាល់ហ្នឹង ចំពោះរឿងខ្ញុំ ថាគ្រាប់បែកផ្សែងពុលនេះ ក៏ខ្ញុំអត់ឃើញដែរ អត់ឃើញទេ។ ប៉ុន្តែឯកសារនេះ វាមាន ប៉ុន្តែខ្ញុំ ខាងខ្ញុំផ្ទាល់ ខ្ញុំអត់ឃើញទេ។

**ស៖** ឥឡូវទុកទូរលេខហ្នឹងចោលទៅ ខ្ញុំអត់មានពេលសួរពាក់ព័ន្ធនឹងទូរលេខទាំងអស់ហ្នឹងទេ។ ខ្ញុំចង់ឲ្យលោកនិយាយអំពី សោ ភឹម។ លោកថា លោកមិនដដែកគ្នាជាមួយគាត់ពីបញ្ហាយោធាទេ អ៊ីចឹងលោកដឹងទេថា គាត់មានគំនិតយ៉ាងម៉េចដែរ ចំពោះវៀតណាមនោះ?

**ឆ៖** អរគុណ។ ចំពោះគំនិតរបស់ សោ ភឹម នុ៎ងទៅវៀតណាម ក៏គាត់មិនដែលនិយាយដែរ គំនិតរឿងអី ក៏គាត់មិនដែលថា ដូចមានគំនិតអីទៅយ៉ាងម៉េច វៃល្អានពានយ៉ាងម៉េច ក៏គាត់មិនដែលនិយាយប្រាប់ដែរ។ អានេះវាជាគំនិតរបស់គាត់ ប៉ុន្តែផែនការដែលថាឲ្យធ្វើម៉េចៗ ក៏ខ្ញុំដឹង។ ដឹងជួនកាលយើងសំណេះសំណាលលេងជាមួយគាត់ ជាញាតិមិត្ត ជាអ៊ីចឹង សួរទេ។ មិនមែនសួរជាផ្លូវការទេ ដែលដឹងហ្នឹង ប៉ុន្តែជាគំនិតរបស់គាត់ មិនដឹងជាយ៉ាងម៉េចៗ យើងអត់ដឹងច្បាស់។ អរគុណ។

**ស៖** តើលោកដឹងអ្វីខ្លះ អំពីវត្តមានរបស់កងទ័ពនៃភូមិភាគកណ្តាលនៅក្នុងភូមិភាគបូព៌ា? ក្នុងពេលណាមួយនោះ តើលោកមានកត់សម្គាល់ឃើញថា មានការសហការគ្នារវាងកងកម្លាំងរបស់ កែ ពក និងកងកម្លាំងរបស់ សោ ភឹម ដែរឬទេ? ឬក៏ថាតើមានជម្លោះរវាងកងទ័ពនៃភូមិភាគទាំងពីរហ្នឹងទេ?

[១០:០៣:២២]

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនបន្តិចរឿងនេះ ជាដំបូងហ្នឹងកងទ័ពភូមិភាគបូព៌ាទេបានប្រយុទ្ធជាមួយវៀតណាមនេះ គ្មានកងទ័ព កែ ពក ណាមកទេ។ ប៉ុន្តែក្រោយមកនេះ ដែលវៀតណាមវៃចូលមកនេះ វៃចូលមកទឹកដីកម្ពុជាហ្នឹង ក៏មានកងទ័ពភូមិភាគកណ្តាលហ្នឹង កែ ពក ហ្នឹង។ ពីម្សិលបានលោកចៅក្រម ជម្រាបជូនថា នៅតាំងពីភូមិស្ទឹង ភូមិតាហៀវ ភូមិខាងម៉ៃសាក់ ភូមិអីហ្នឹង ប៉ុន្តែទ័ពភូមិភាគកណ្តាលមកនៅហ្នឹង មិនទាន់ច្បាំងទេ។ អត់មានទាន់ច្បាំងនៅសមរភូមិមុខទេ គ្រាន់តែមកត្រៀមនៅខាងក្រោយទេ។ តែនៅជួរមុខ គឺកងទ័ពភូមិភាគបូព៌ា ខាងកងពលទេ ជាមួយវៀតណាមនោះ។ គ្រាន់តែនៅមួយកំណាត់ខាងក្រោយហ្នឹងទេ។ មកនៅហ្នឹងថាចាំជួយកងទ័ពភូមិភាគបូព៌ា ប៉ុន្តែមិនទាន់ជួយ។ ក្រោយមកទៀត ចាប់ពីឆ្នាំ៧៨មកនេះ ចាប់ផ្តើមផ្ទុះអាវុធនៅខាងក្នុងប្រទេស ក្រសួងមន្ទីរហ្នឹង ហើយសួរអ្នកណាដែលធ្វើរដ្ឋប្រហារហ្នឹង ហើយខ្ញុំក៏នៅតែឆ្ងល់ដែរ។ អ្នកណាដែលធ្វើរដ្ឋប្រហារហ្នឹងមកវៃខ្មែរនិងខ្មែរហ្នឹង គ្រប់ក្រសួងមន្ទីររត់រប៉ាត់រប៉ាយ អាណាចាប់បាន ចាប់បានទៅ អាណាគេយក

សម្លាប់យក ៗសម្លាប់ទៅ មិនដឹងឯណា។ ពេលនុ៎ងហើយដែលភូមិភាគកណ្ដាលវាធ្វើ ថាមកវៃយួន ប៉ុន្តែមកវៃយួន មកធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ា ឃើញទេ។ ហើយខ្ញុំនៅតែឆ្ងល់អ៊ីចឹង ទើបនឹងពេលនេះទេ ដែលលោកចៅក្រមមេត្តាអនុញ្ញាតឱ្យខ្ញុំឃើញឯកសារនេះ បានខ្ញុំចង់និយាយនេះ។ អ៊ីចឹងឈ្មោះ ឆុន ហ្នឹងប្រហែលជានៅខ្សែមុខហើយ សម្រាប់ធ្វើរដ្ឋប្រហារហើយ។ ហើយចំពោះៗអ៊ំ អ៊ំនួនៗ ហ្នឹង អានេះវាមានថ្នាក់ណាមួយហើយ ដែលអ្នកសម្រេចឱ្យ ឆុន ហ្នឹងធ្វើហ្នឹង ហើយ ឆុន ហ្នឹងរាយការណ៍ឱ្យ អ៊ំនួន ហ្នឹង ដែលធ្វើរដ្ឋប្រហារនៅភូមិភាគបូព៌ាហ្នឹង។ កន្លងមកខ្ញុំក៏ឆ្ងល់ដែរ ហើយខ្ញុំវិភាគថាធ្វើរដ្ឋប្រហារហ្នឹង ប្រហែល--

[១០:០៥:២៩]

**ប្រធានអង្គជំនុំ៖**

លោកសាក្សី លោកមិនមែនអ្នកវិភាគទេ លោកស្ដាប់ឱ្យយល់។ សាក្សីចាំស្ដាប់សំណួរ ហើយឆ្លើយតបនឹងភាពចាំបាច់ទៅនឹងសំណួរបានហើយ មិនមែនជាអ្នកជំនាញមកវិភាគឱ្យអង្គជំនុំជម្រះស្ដាប់ទេ។ អង្គជំនុំជម្រះនឹងយកបញ្ហាទាំងអស់សរុប ដើម្បីវិភាគពិចារណា វាយតម្លៃ ថារឿងហេតុនុ៎ងវាយ៉ាងម៉េច ភស្តុតាងហ្នឹងវាយ៉ាងម៉េច អង្គច្បាប់យ៉ាងម៉េច ដើម្បីចេញសាលក្រមមួយនោះ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកបាននិយាយថា ចាប់ពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៨ លោកនៅតែម្នាក់ឯងទេ ហើយលោកដឹកនាំកងវរសេនាធំមួយ។ ខ្ញុំចង់ដឹងថាតើក្នុងកងវរសេនាធំរបស់លោកហ្នឹង មានកម្លាំងប៉ុន្មាននាក់ដែរ<នៅថ្ងៃ២៥ ឧសភា ១៩៧៨នោះ>? ហើយអ្នកទាំងអស់ហ្នឹង ជាអតីតបុគ្គលិកនៅមន្ទីរពេទ្យ១៥៦ហ្នឹង ឬក៏ជាទាហានមកពីខាងណាផ្សេង?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះខ្ញុំបានដឹកនាំកងកម្លាំងប្រដាប់អាវុធនេះ អាហ្នឹងវាជាកងទ័ពកងពលលេខ៤សុទ្ធ អត់មានមកពីអង្គភាពណាទេ គឺដកចេញពីខ្សែត្រៀមខាងមុខហ្នឹងមក។ ដកចេញមកៗច្បាំងជាមួយភូមិភាគកណ្ដាលហ្នឹងតែម្ដង។ បាទ សូមអរគុណ។

[១០:០៧:២០]

**ស៖** លោកមានកម្លាំងហ្នឹងប៉ុន្មាននាក់ដែរនៅក្នុងដៃ?

**ឆ៖** អរគុណ។ កម្លាំងនៅក្នុងដៃរបស់ខ្ញុំមាន៣០០នាក់។ កម្លាំងថ្មើរជើង៣០០ កម្លាំងកង

ពិសេស៤០នាក់ទៀត គឺត្រូវ៣៤០នាក់។

**ស៖** ពេលណាដែលលោកចាប់ផ្ដើមប្រយុទ្ធគ្នាជាមួយនឹងកងទ័ពភូមិភាគកណ្ដាល តាំងពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ៧៨ហ្នឹងតែម្ដង ឬក៏យ៉ាងម៉េច?

**ឆ៖** អរគុណ។ ពួកខ្ញុំចាប់ប្រយុទ្ធចាប់ពីថ្ងៃ២៥ ខែ៥ ៧៨ ហ្នឹងចាប់ផ្ដើមប្រយុទ្ធតែម្ដង។ បើយើងមិនប្រយុទ្ធយើងស្លាប់ យើងអត់មានអី ស្បៀងក៏គ្មាន អង្រឹងក៏គ្មាន មានតែអាវុធនិងគ្រាប់រំសេវប៉ុណ្ណឹង។ អ៊ីចឹងត្រូវបើកយុទ្ធនាការដើម្បីវាយយករស់។ បាទ អរគុណមានតែប៉ុណ្ណឹងឯង។

**ស៖** ហើយលោកវាយប្រយុទ្ធគ្នាជាមួយនឹងកម្លាំងភូមិភាគកណ្ដាលហ្នឹងប៉ុន្មានថ្ងៃដែរ គឺរហូតទៅដល់ពេលណាដែរ?

**ឆ៖** អរគុណ។ ខ្ញុំចាប់ផ្ដើមប្រយុទ្ធហ្នឹង គិតទៅចាប់ពីថ្ងៃ២៥ ខែ៥ ៧៨ រហូតដល់ៗខែ១១ ឆ្នាំ៧៨, ខែ១១ ៧៨។

**ស៖** មុនថ្ងៃទី២៥ ឧសភា ៧៨ លោកដឹងទេថាកម្មាភិបាលមួយចំនួន ឬក៏ជនជាតិខ្មែរមួយចំនួនហ្នឹងរត់ចូលទៅក្នុងដីកដីវៀតណាម លោកដឹងអំពីរឿងហ្នឹងទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ៗអត់បានដឹងទេ អត់បានដឹង។

**ស៖** ពេលណាដែលលោកខ្លួនឯងផ្ទាល់នេះ មានទំនាក់ទំនងជាមួយនឹងកងទ័ពវៀតណាមជាលើកដំបូងនោះ គឺទាក់ទងគ្នាដើម្បីលោកចូលទៅក្នុងជំរំវៀតណាមនោះ?

[១០:១០:០៨]

**ឆ៖** អរគុណ។ ចំពោះថ្ងៃខែខ្ញុំអត់ចាំទេ ប៉ុន្តែបើឆ្នាំខ្ញុំចាំ គឺខែ១១ ឆ្នាំ៧៨ហ្នឹងហើយ ដែលទំនាក់ទំនងរវាងរឿងខ្មែរ និងជាមួយវៀតណាម កងទ័ពវៀតណាម។ ពេលនោះខ្ញុំក៏គ្រុនដែរ ហើយខ្ញុំក៏បានទៅនៅមេមត់នោះ តំបន់ដែលយើងទៅរំដោះពីកម្ពុជាប្រជាធិបតេយ្យហ្នឹង ខ្ញុំក៏នៅសម្រាកនៅនុ៎ង។ ពេលនុ៎ងខ្ញុំគ្រុន ប៉ុន្តែវៀតណាមក៏បានទាក់ទង ថាយើងត្រូវតែប្រមូលកម្លាំងសាមគ្គីគ្នាដើម្បីរៀបចំរំដោះកម្ពុជាឡើងវិញ។ ពេលនោះហើយដែលយន្តហោះ ឧទ្ធម្ភាគចក្រចុះយកខ្ញុំកណ្ដាលព្រៃហ្នឹង ទៅទីក្រុងហូជីមិញ។ អាហ្នឹង អរគុណ មានប៉ុណ្ណឹង។

**ស៖** រហូតដល់ខែ១១ ឆ្នាំ៧៨ហ្នឹង លោកហើយនិងកូនចៅរបស់លោក ប្រយុទ្ធជាមួយនឹងកងកម្លាំងភូមិភាគកណ្ដាលផង និងជាមួយនឹង ប្រយុទ្ធប្រឆាំងជាមួយនឹងកងទ័ពវៀតណាមផង តើអ៊ីចឹងមែនទេ?

01377399



**ឆ៖** បាទ អរគុណ។ ព្រោះពេលនោះ វាជាសត្រូវយើងទាំងអស់ ជាសត្រូវទាំងអស់ មិនដឹងអ្នកណាយ៉ាង អ្នកណាៗ អត់ដឹងទេ។ ពីមុនយើងរើជាមួយវៀតណាម ដល់ក្រោយមកជាមួយភូមិភាគកណ្តាលទៀត វាធ្វើរដ្ឋប្រហារ ចាប់ផ្តើមរើអាហ្នឹងទៀត។ ពេលនោះវាច្របូកច្របល់ណាស់ មិនដឹងជាស្អីៗទេអាហ្នឹង ដូចថាផ្អែវាប៉ះត្រង់ណា ខាំត្រង់ហ្នឹងហើយ រឿងហ្នឹងវាអ៊ីចឹង។ អ៊ីចឹងបានសភាពការណ៍កើតឡើងវាច្របូកច្របល់ច្រើនណាស់ រកនិយាយមិនអស់ទេ។ បាទ អរគុណ។

[១០:១២:០៨]

**ស៖** លោកអាចជម្រាបឱ្យបានច្បាស់បានទេ ថាអ្នកណាជាអ្នកមកទាក់ទងជាមួយលោកនោះ? អ្នកណាដែល<>លោក<បានជួបនោះ តើជួប>នៅកម្ពុជា <ឬក៏>នៅវៀតណាម<>? ហើយ<ជាពិសេសតើពេល>ណា<ដែល>លោក ទៅហូជីមិញហ្នឹង?

**ឆ៖** អរគុណ។ ជួបដំបូងឡើយនៅក្នុងព្រៃហ្នឹង ខ្ញុំគ្រាន់តែខាងវៀតណាម ខ្ញុំអត់ស្គាល់ទេ មិនដឹងជាឈ្មោះអី ប៉ុន្តែខ្មែរ យើងអាចស្គាល់ឈ្មោះ ឈ្មោះ កុយ បៀន និង កៅ តឹក តែពីរហ្នឹងដែលនៅជាមួយអង្គភាពវៀតណាមដែលគេមកជួបគ្នាមុនដំបូង មកទាក់ទងគ្នាហ្នឹង។ មានតែប៉ុណ្ណឹងទេ អរគុណ។

**ស៖** គេបាននិយាយអ្វីខ្លះ ដើម្បីបញ្ចុះបញ្ចូលឱ្យលោកចូលរួមជាមួយកងទ័ពវៀតណាមហ្នឹង? ហើយក្រោយមកទៀត លោកជួបអ្នកណាខ្លះទៀត?

**ឆ៖** អរគុណ។ ជួបដំបូងគ្រាន់តែយើង គេបញ្ចុះបញ្ចូលថាយើងនឹងរួមគ្នាសាមគ្គីគ្នា ពួតដៃគ្នាដើម្បីវាយរំដោះកម្ពុជា ឱ្យរួចផុតពីកណ្តាប់ដៃរបស់ ប៉ុល ពត ដែលកាប់សម្លាប់ប្រជាជនកម្ពុជា។ គេនិយាយតែប៉ុណ្ណឹង។ ប៉ុន្តែក្រោយមកទៀត ដល់កម្លាំងហ្នឹងចេញបាត់ ខ្ញុំអត់ស្គាល់ទេ គឺកម្លាំងហ្នឹងកម្លាំងសុទ្ធរបស់វៀតណាមតែម្តង ដែលមកទាក់ទងហ្នឹង ប៉ុន្តែខ្ញុំអត់ស្គាល់។

**ស៖** បាទ លោកប្រធាន សំណួរចុងក្រោយមុនពេលឈប់សម្រាក។ លោកមានបានជួបជាមួយខ្មែរដែលរត់ចូលវៀតណាមទេ? ឧទាហរណ៍ដូចជា អ្នកទទួលខុសត្រូវនយោបាយ យោធាដែលបង្កើតជារណសិរ្សដើម្បីវាយប្រឆាំងជាមួយនឹងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យទេ?

[១០:១៤:៣៤]

**ឆ៖** អរគុណ។ ចំពោះខ្ញុំ បានជួបខ្លះដែរ អ្នកនយោបាយសព្វថ្ងៃហ្នឹង អ្នកដែលតស៊ូក្នុងព្រៃជាមួយគ្នាហ្នឹង ក៏បានជួបខ្លះ មិនមែនថាមិនជួបទេ បានជួបខ្លះ។ អរគុណ។

**ស៖** លោកអាចជម្រាបបានទេ លោកខ្លះហ្នឹង អ្នកណាខ្លះ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** អរគុណ។ សូមជម្រាបលោកចៅក្រម ខ្ញុំជួបហ្នឹងដូចជា សម្តេចហេង សំរិន, អ៊ុក ប៊ុនឈឿន អីសុទ្ធតែជួបគ្នាហើយ នាយអគ្គសេនាធិការ ប៉ុល សារឿន ប៉ុលអីហ្នឹងសុទ្ធតែជួបគ្នា ធ្លាប់ជួបគ្នា អត់អីទេ។ បានជួបគ្នាហ្នឹងហើយដែលពិភាក្សាជាមួយគ្នា។ អរគុណ មានប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ ខ្វះម្ភៃប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយ ខ្វះម្ភៃនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១៦ នាទី ដល់ម៉ោង ១០:៣៦ នាទី)*

[១០:៣៦:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

**ស៖** លោកសាក្សី យើងមុនពេលសម្រាកហ្នឹង លោកពន្យល់ថា លោកបានជួបអ្នកនយោបាយមួយចំនួន ឬអ្នកយោធាមួយចំនួន ដូចជា ហេង សំរិន, អ៊ុក ប៊ុនឈឿន, <ប៉ុល សារឿន>។ អ៊ីចឹងខ្ញុំចង់ដឹងថា តើលោក<មានតួនាទីអីដែរក្នុង>ចូលរួមទៅក្នុងការបង្កើតរណសិរ្សហ្នឹង បានកម្រិតណាដែរ នៅពេលនោះ?

**2-TCW-1065៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

**ឆ៖** អរគុណ។ ចំពោះរូបខ្ញុំផ្ទាល់ គឺចេញពីកម្ពុជាទៅ គឺខ្ញុំទៅខាងឡុងខាញ់ នៅកន្លែងជំរំរបស់នគរបាល។ ប៉ុន្តែមុនដំបូង និយាយពីមុនដំបូងទៅចុះ ដើម្បីកុំនិយាយមួយកំណាត់ អ៊ីចឹងលោកចៅក្រមស្តាប់អត់បាន។ មុនដំបូងខ្ញុំជិះយន្តហោះទៅ ចុះនៅទីក្រុងហូជីមិញ។ ចេញពីនុំងទៅ បានវៀតណាមគេនាំទៅ ៗបន្ទាយនគរបាលហ្នឹងឡុងខាញ់។ ទៅសម្រាកនៅឡុងខាញ់ហ្នឹង អស់ប្រហែលជា២សប្តាហ៍។ ចេញពីឡុងខាញ់ទៅៗឡុងយ៉ាវទៀត ទៅកន្លែងជំរំកងទ័ព។ បានចេញពីឡុងយ៉ាវមកទៀត ហ្នឹងមកចាប់ផ្តើមចូលមកកម្ពុជាហើយ។ ចូលរួមបានប៉ុណ្ណឹង បាទ អរគុណ។

[១០:៣៨:៤៤]

**ស៖** នៅពេលដែលលោកត្រឡប់មកប្រទេសកម្ពុជាវិញ តើលោកបានតស៊ូប្រឆាំងនឹងកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យដែរឬទេ? ហើយខ្ញុំសួរលោកថា តើលោកត្រឡប់មកប្រទេសកម្ពុជាវិញ ក្នុងឋានៈជាអ្វីដែរ? ជាយោធា ឬក៏ជាស៊ីវិល? ហើយតួនាទីរបស់លោកជាអ្វីដែរ?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបជូនថា ខ្ញុំដែលចូលមកកម្ពុជាវិញ ខ្ញុំទទួលជាអនុប្រធាននគរបាលភូមិភាគទី៧របស់វៀតណាម ទទួលប្រាំខេត្ត កំពង់ចាម កំពង់ធំ ក្រចេះ ព្រៃវែង និងស្វាយរៀង។ សម្រាប់ទទួលពួកជនកងតូច កងធំដែលគេចាប់បញ្ជូនយកមកឲ្យខ្ញុំដាក់នៅវត្តជ័យបិទមាស ខាងឃុំស្នួងហ្នឹង។ បាទ អរគុណ។

**ស៖** ដើម្បីឲ្យច្បាស់ទាំងអស់គ្នា អ៊ីចឹងលោកត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំណាដែរ? ចង់និយាយថា មុនថ្ងៃ០៧ មករា ឆ្នាំ១៩៧៩ ឬក៏ក្រោយថ្ងៃ០៧ មករា ឆ្នាំ១៩៧៩?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបលោកចៅក្រមថា ខ្ញុំវិលមកកម្ពុជាហ្នឹងគឺក្រោយ៧៩ ពេលរំដោះភ្លាម គឺខ្ញុំបានត្រឡប់មកដើម្បីទទួលពួកឈ្លើយសឹក ដែលយើងប្រមូលបានពីបាត់ដំបង ពីសៀមរាប កំពង់ធំ យកមកដាក់នៅមួយកន្លែងហ្នឹង។ មានចំនួន៤០០នាក់ កងតូច កងធំ យកប្រមូលដាក់កន្លែងហ្នឹង យកមកដើម្បីធ្វើការអប់រំណែនាំពីគោលនយោបាយរបស់រណសិរ្ស។ បាទ អរគុណ។

**ស៖** ហើយអ្នកទោសទាំងអស់ហ្នឹង ឈ្លើយសឹកហ្នឹង តើជាអតីតយោធាពីភូមិភាគបូព៌ា ឬក៏មកពីភូមិភាគណាផ្សេង ពីអង្គភាពយោធាណា ពួកគាត់ហ្នឹងចំណុះឲ្យអង្គភាពយោធាណាដែរ?

[១០:៤១:០៨]

**ឆ៖** អរគុណ។ ចំពោះការចាប់បញ្ជូនមកកន្លែងខ្ញុំ គឺចម្រុះ។ ហើយមក ចាប់ពីសៀមរាប កំពង់ធំ បញ្ជូនមកហ្នឹងទាំងអស់ កងធំ កងតូចរបស់ខ្មែរក្រហម បញ្ជូនមកអប់រំកន្លែងហ្នឹង ព្រោះកន្លែងយើង

រៀបចំសាលាសម្រាប់អប់រំមនុស្សឲ្យល្អ។ អរគុណ។

**ស៖** ហើយការអប់រំហ្នឹង គេបង្រៀនពីអ្វីដែរ? ហើយគោលបំណងនៃការអប់រំហ្នឹងអ្វីដែរ?

**ឆ៖** អរគុណ។ ការអប់រំ គឺថាគោលបំណងរបស់យើងឲ្យប្រជាពលរដ្ឋហ្នឹងធ្វើបានល្អត្រឹមត្រូវ ឲ្យស្គាល់អំពីកាប់សម្លាប់របស់ពួក ប៉ុល ពត។ យើងអប់រំឲ្យគាត់យល់ ពីកាប់សម្លាប់ កុំឲ្យគាត់ច្រឡំភ័ត្ត ហើយការអប់រំនេះ យើងអប់រំទៅតាមគោលនយោបាយរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិ គោលការណ៍១១(ខ) និង ៨(ខ) យើងអប់រំប៉ុណ្ណឹង។ អរគុណ។

**ស៖** ហើយនៅពីលើលោកនោះ តើមានអ្នកមានណាត្រួតពិនិត្យលើការអប់រំហ្នឹងដែរឬទេ របៀបអប់រំដែរឬទេ? តើអង្គាល់នោះលោកមានសិទ្ធិសេរីភាពក្នុងការផ្ដល់ការអប់រំតាមតែចិត្តលោកដែរ ឬទេ ឬក៏មានអ្នកណានៅពីលើលោក ជាអ្នកកំណត់ថា ត្រូវអប់រំបែបនេះ បែបនោះ ត្រូវបង្រៀនអីៗជា ដើមហ្នឹង?

**ឆ៖** អរគុណ។ នៅពេលនោះគឺនៅពីលើខ្ញុំអត់មានខ្មែរទេ មានតែវៀតណាម ៗប្រធាន ខ្ញុំអនុប្រធាន ប៉ុន្តែយើងអប់រំទៅតាមគោលនយោបាយរបស់រណសិរ្ស យើងផ្សព្វផ្សាយតាមហ្នឹង។ តែប៉ុណ្ណឹង អរគុណ។

**ស៖** តើ<យើងអាច>និយាយ<បាន>ថា <បុគ្គលនោះក៏យល់>ស្របនឹងគោលនយោបាយ វៀតណាមដែរ បានអាចអប់រំបាន ឬក៏យ៉ាងណា?

[១០:៤៣:៤៩]

**ឆ៖** អរគុណ។ ពេលនោះវៀតណាមក៏គេ ៗបង្គាប់ឲ្យខ្មែរថាអប់រំតាមគោលនយោបាយរបស់ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ពេលនុ៎ងខ្មែរយើងក៏មិនទាន់រៀបចំអីដែរ នៅឡើយទេ ៧៩ មិន ទាន់រៀបចំទេ គឺនៅទាំងអស់។ អ៊ីចឹងមានតែវៀតណាមទេ គេគ្រប់គ្រងយើងនោះ ហើយវៀតណាមគេ ជាប្រធាន ហើយខ្ញុំជាអនុប្រធាន។ អនុប្រធានមានតែខ្ញុំមួយហ្នឹងខ្មែរនោះ។ នៅកន្លែងដែលយើងប្រមូល ពីកងតូច កងធំយកមកដាក់នៅកន្លែងហ្នឹង។ អរគុណ។

**ស៖** តើចំនួនអ្នកដែលគេអប់រំនោះ មានចំនួនប៉ុន្មានដែរ? មានអតីតយោធាប៉ុន្មាននាក់ដែរកាល នុ៎ង?

**ឆ៖** អរគុណ។ នៅពេលប្រមូលពីកងតូចកងធំបាន មានចំនួន៤០០នាក់។ ប៉ុន្តែក្នុងចំណោម ៤០០នាក់នោះអត់មានផ្នែកទាហានទេ អត់មានទេ សុទ្ធតែផ្នែកស៊ីវិលទាំងអស់ ដែលយើងប្រមូលបាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គ្រប់ខេត្តមកហ្នឹង អត់មានខាងទាហាន អត់មានទេ។ បាទ អរគុណ។

**ស៖** អ៊ីចឹងកាលនោះហ្នឹងពួកគាត់ជាកម្មាភិបាល ឬក៏គ្រាន់តែជាអ្នកមូលដ្ឋានទេ?

**ឆ៖** អរគុណ។ ពេលដែលយើងប្រមូលមកវាជាកម្មាភិបាលកងតូចកងធំ មិនមែនជាប្រជាពលរដ្ឋទេ ជាកម្មាភិបាលដឹកនាំក្នុងកងតូចកងធំរបស់ៗខ្មែរក្រហមហ្នឹង។ អរគុណ។

**ស៖** ហើយបន្ទាប់មកទៀតហ្នឹង តើទំនាក់ទំនងរវាងលោក ហើយនិងមេលោកហ្នឹង ថយចុះដែរឬទេ អាក្រក់ទៅអាក្រក់ទៅដែរឬទេ?

[១០:៤៦:២៥]

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ហើយនិងមេៗខ្ញុំ មិនដឹងជានរណាមេ ខាងខ្មែរ ខាងវៀតណាមហ្នឹង សូមៗលោកចៅក្រមបញ្ជាក់បន្តិច។

**ស៖** ចង់និយាយថា ប្រធានលោកជាទូទៅនោះ តើលោកមានត្រូវបានគេចាប់ខ្លួនទេកាលនុ៎ងជាមួយមេលោកអីជាដើមហ្នឹង? ហើយបើគេចាប់ខ្លួនលោកនុ៎ង ដោយមូលហេតុអ្វីដែរ?

**ឆ៖** ចំពោះខ្ញុំនៅជំរំនេះខ្ញុំអប់រំកងតូចកងធំ ប៉ុន្តែក្រោយមកហ្នឹង គឺឃើញថាមានការទំនាស់គ្នាទំនាស់រវាងឯខ្ញុំនិងវៀតណាមហ្នឹង មិនឯកភាពគ្នារឿងខាងនយោបាយ។ អ៊ីចឹងខ្ញុំប្រាប់ខ្ញុំក៏ទៅនៅមហាផ្ទៃ។ ដល់នៅមហាផ្ទៃហ្នឹង ក៏មករៀបចំមហាផ្ទៃ ហើយខ្ញុំជាអ្នករៀបចំមុនគេទៀតនៅមហាផ្ទៃ។ តាំងពី ស៊ិន សុន -- ស៊ិន សុង, សុន សេន អីនៅជាមួយគ្នាទាំងអស់ហ្នឹង។ ហើយខ្ញុំរៀបចំតាំងពី តេ-៣ តេអី សុទ្ធខ្ញុំរៀបមុនគេទាំងអស់។ ដល់ក្រោយមកនៅហ្នឹង ហើយខ្ញុំទទួលដំណឹងបានអ៊ីចេះ បានជាខ្ញុំជាប់គុក។ ដំណឹងថាគ្រួសារហ្នឹង ៧៨ហ្នឹងសម័យ ប៉ុល ពត ហ្នឹងបានកៀរប្រមូលទៅនៅ នោះទៅពោធិ៍សាត់នោះ អ្នកស្វាយរៀងប្រមូលទៅនោះទាំងអស់ ទៅនៅលាច។ អ៊ីចឹងខ្ញុំក៏សូមមេបញ្ជាការនៅមហាផ្ទៃ សូម សំ នៀត ហ្នឹងដើម្បីទៅរកមើលគ្រួសារដែលគេជម្លៀសទៅនុ៎ង។ ទៅនុ៎ងមិនទាន់ដល់ផងមិនទាន់ ក៏យកទាហានទៅប្រាំនាក់ទៅជាមួយខ្ញុំ។ មុនទៅដល់នុ៎ង គេចោទប្រកាន់ថាយើងប្រុងរត់ទៅណាទៀត។ អាត្រង់ហ្នឹងហើយដែលធ្វើឲ្យៗខ្ញុំបានជាប់គុក។ ថាចោទប្រកាន់អត់សមហេតុសមផល អាហ្នឹង។ ជាប់គុកហ្នឹង១ឆ្នាំ៨ខែខ្ញុំនោះ ហ្នឹងឆ្នាំ៨០ ជាប់គុកហ្នឹងឆ្នាំ៨០។ អរគុណ។

[១០:៤៨:៥២]

**ស៖** ប្រហែលជាមានបញ្ហាបកប្រែ ព្រោះចម្លើយរបស់លោកដូចមិនសូវច្បាស់ចំពោះខ្ញុំ។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកទៅពោធិ៍សាត់ហ្នឹងដើម្បីធ្វើអ្វីដែរ? ហើយទៅ

ហ្នឹងទៅនៅពេលណាដែរ? ការធ្វើដំណើររបស់លោកទៅពោធិ៍សាត់ហ្នឹងក្នុងគោលបំណងអ្វីដែរ?

**ឆ៖** អរគុណ។ ខ្ញុំទៅហ្នឹងក៏គឺក្នុងឆ្នាំ៧៩ ខ្ញុំទៅគោលបំណងតែមួយទេ គ្មានគោលបំណងអីទេ គឺទៅមើលគ្រួសារ ទៅរកគ្រួសារដែលជំនាន់ ប៉ុល ពត ជម្លៀសទៅលាចទុំង ទៅទុំង។ គោលបំណងមានតែប៉ុណ្ណឹងទេ។ គ្រាន់តែយើងទៅអ៊ីចឹង បរទេសគេអាចចោទប្រកាន់ថាយើងនេះប្រុងរត់ទៅខាងក្រៅ វាអ៊ីចេះ វាត្រឡប់ទៅអ៊ីចឹងវិញ។ ហើយដល់មកសួរទៅ សួរទៅ ហើយសួរខ្ញុំ សួរលើកណាក៏សួរដែរ សួរថាខ្ញុំមិនដែលរត់ទៅណា មករកៗគ្រួសារតើ។ បានថាហ្នឹងវាមានទំនាស់តាំងពីហ្នឹងទៅ ដែលយើងមិនឯកភាពគ្នាលើគោលនយោបាយរបស់គេហ្នឹង។ អ៊ីចឹងជាប់គុក១ឆ្នាំ៨ខែ ជាប់គុកហ្នឹង។

**ស៖** អ៊ីចឹងគឺបានន័យថា គេចាប់លោកដាក់គុកហ្នឹង ដោយសារតែគេយល់ឃើញថា លោកចង់គេចចេញពីប្រទេសខ្មែរ ហើយអ៊ីចឹងគេលែងទុកចិត្តលោកទៅ។ ខ្ញុំនិយាយថា “គេ” ហ្នឹង ចង់សំដៅទៅលើ មិនដឹងថាសំដៅទៅលើវៀតណាម ឬក៏សំដៅបុគ្គលណាផ្សេងទេ។ ខ្ញុំនិយាយថា “គេ” ហ្នឹង មិនទុកចិត្តលោក គេចាប់លោកដាក់គុកអីហ្នឹង។ លោកអាចបញ្ជាក់ឲ្យច្បាស់បានទេ អ្នកណាគេដែរ “គេ” ហ្នឹង? ហើយខ្ញុំសង្ខេបអំមិញហ្នឹង ត្រូវទេ?

[១០:៥០:៥៦]

**ឆ៖** អរគុណ។ ខ្ញុំសូមបញ្ជាក់ថា អ្នកដែលគេមិនទុកចិត្តហ្នឹង គឺវៀតណាម ព្រោះពេលនោះមានតែវៀតណាម ខ្មែរមិនសូវមានទេ។ គេចោទខ្ញុំថា ខ្ញុំប្រុងរត់ទៅថៃ។ ហើយខ្ញុំវាមិនដែលស្គាល់ថៃផងនេះ រឿងថៃខ្ញុំ មិនដែលស្គាល់គ្នាយ៉ាងម៉េច ហើយក៏វាទំនាក់ទំនងអីយ៉ាងម៉េច ព្រំដែនក៏វាគ្មានដែរ។ ហើយដល់គេចោទអ៊ីចឹងមក គេលេសហ្នឹងមួយដើម្បីចាប់យើងដាក់គុក។ លេសប៉ុណ្ណឹង។ ហើយធ្វើសវនាការក៏អត់មាន ស្អីក៏គ្មាន គេគ្រាន់តែសួរអ៊ីចឹង។ បីបួនខែគេមកសួរម្ដង វៀតណាមហ្នឹង បីបួនខែសួរម្ដង។ ហើយខ្ញុំមិនដឹងថាឆ្លើយម៉េច តែប៉ុណ្ណឹង។ អរគុណ។

**ស៖** ហើយគុកហ្នឹងដឹកនាំដោយខ្មែរ ឬក៏ដោយវៀតណាម? ហើយគេមានបានកាត់សេចក្ដីលោកទេ ជំនុំជម្រះសេចក្ដី ថាតើគេធ្វើយ៉ាងម៉េចទៅ ពេលដែលគេចាប់លោកដាក់គុកហ្នឹង?

**ឆ៖** អរគុណ។ ខ្ញុំសូមជម្រាបលោកចៅក្រមថាអ៊ីចេះ ពេលដែលចាប់ខ្ញុំ គេចោទប្រកាន់ថាខ្ញុំប្រុងរត់ទៅថៃ ចូលថៃ។ អ៊ីចឹងវាចាប់ដាក់គុកឆ្នាំ៧៩ហ្នឹង បើនិយាយពីជីវភាពក្នុងគុកហ្នឹង យ៉ាប់ណាស់ យ៉ាប់មែនទែន គ្មានបាយហូបទេ ស្ងោរពោតក្រហមទេ ឲ្យហូបនោះ។ មួយពេលមួយកូនចានចង្កឹះ។ ជួនកាលក៏មានអំបិល ជួនកាលក៏អត់អំបិលពេលនោះ។ ហើយអ្នកគ្រប់គ្រងគឺវៀតណាម អ្នកចោទ

ប្រកាន់ហ្នឹង។ អត់មានបាយទេ មានពោតក្រហមមួយកូនចានចង្កឹះហ្នឹង ស្ងោរឱ្យរីកប៉ុនៗម្រាមដៃ ឱ្យហូបទៅអ្នកទោស។ ខ្ញុំនឹកស្ដាយណាស់ រួចពីសម័យមួយ មកជួបសម័យមួយទៀត។ អរគុណ។

**ស៖** សំណួរចុងក្រោយលើប្រធានបទហ្នឹង។ បើខ្ញុំមិនច្រឡំទេគឺថា លោកជាប់គុក៨ខែ ក្រោយមកគេដោះលែងលោក ហើយមិនមានការជំនុំជម្រះសេចក្ដីលើករណីលោកទេ។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ វាត្រឹមត្រូវ។

[១០:៥៣:៤៤]

**ស៖** ឥឡូវខ្ញុំសុំចូលប្រធានបទថ្មីមួយទៀតខ្លីទេ។ នៅពេលដែលលោកនៅភូមិភាគបូព៌ា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកមានបានឃើញថ្នាក់ដឹកនាំពីមជ្ឈិមទៅធ្វើទស្សនកិច្ចនៅភូមិភាគបូព៌ាដែរឬទេ? ដូចជាជនជាប់ចោទនៅក្នុងសាលសវនាការយើងនេះជាដើម លោកមានឃើញពួកគាត់ចុះទៅធ្វើទស្សនកិច្ចទេ?

**ឆ៖** អរគុណ។ ចំពោះរូបខ្ញុំផ្ទាល់ អត់បានឃើញទេ អត់បានឃើញ ហើយមិនស្គាល់ ក៏មិនបានឃើញទៀត។ អរគុណ។

**ស៖** ក្នុងឋានៈជាកម្មាភិបាលនៅភូមិភាគបូព៌ា តើលោកមានទទួលការណែនាំ ឬក៏លោកធ្លាប់ដឹងអំពីការដាក់គោលនយោបាយចំពោះអតីតទាហាននៃរបប លន់ នល់ ដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំគឺគោលនយោបាយ អត់មាន ព្រោះខ្ញុំខាងផ្នែកសុខាភិបាល ផ្នែកពេទ្យ។ អ៊ីចឹងវាអត់មានជាប់ឥទ្ធិពលនយោបាយ ទាហាន លន់ នល់, លន់អីអត់មានទេ ព្រោះពេទ្យសម្រាប់ជួយសង្គ្រោះមនុស្ស។ អរគុណ នៅសម័យនោះ។

**ស៖** តើលោកមានធ្លាប់ដឹងអំពីការបាត់ខ្លួន អ្នកដែលគេហៅទៅអប់រំដែរឬទេ? ហើយរឿងហ្នឹងមានកើតឡើងដែរឬទេ?

[១០:៥៥:៥៣]

**ឆ៖** អរគុណ។ ចំពោះខ្ញុំបានដឹង គ្រាន់តែបានដឹងថា ការបាត់ខ្លួន ប៉ុន្តែបាត់ទៅណា ទៅណា ក៏យើងអត់ដឹងដែរ។ គ្រាន់តែដឹងថាបាត់ ប៉ុន្តែមិនដឹងថាបាត់ទៅច្រកល្ហកណា ក៏ខ្ញុំអត់ដឹងដែរ ដឹងប៉ុណ្ណឹងទេ។ ហើយដឹង ដឹងថាគេហៅទៅរៀន គេអត់ដឹងគេទៅណាទេ។ វាដឹងគោលការណ៍គេ យ៉ាងម៉េចៗ អត់ដឹងទេ ប៉ុន្តែដឹងបាត់ពីអង្គភាពហើយ។ អរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** នៅពេលដែលលោកនៅភូមិភាគបូព៌ា តើលោកដឹងដែរឬទេ ថាតើក្នុងចំណោមប្រជាជននៅភូមិភាគបូព៌ា ថាមានវត្តមានប្រជាជនវៀតណាមដែរឬទេ? តើលោកមានដឹងដែរឬទេ ថាតើមានការអនុវត្តគោលនយោបាយប្រឆាំងចំពោះប្រជាជនវៀតណាមនៅភូមិភាគបូព៌ាដែរឬទេ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អរគុណ។ នៅរបបប្រជាធិបតេយ្យ គឺថាប្រជាជនវៀតណាមអត់មានទេ អត់មានតែម្តង។ បាទ អរគុណ។

**ស៖** លោកចង់និយាយថា លែងមានវៀតណាមទៀតហើយ ឬក៏អត់មានវៀតណាម? អ៊ីចឹងខ្ញុំសួរលោកថា ហេតុអ្វីបានជាមិនមានប្រជាជនវៀតណាមនៅទីនោះ? ពួកគាត់ហ្នឹងចេញទៅវៀតណាមវិញបាត់អស់ហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** អរគុណ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង អត់មានវៀតណាមតែម្តង អត់មានមានតែខ្មែរ វៀតណាមអត់មានទេ។ អាហ្នឹងគេចេញទៅអស់ យ៉ាងម៉េចៗ ក៏ខ្ញុំមិនដែលឃើញដែរ ប៉ុន្តែខ្ញុំមើលទៅវាអត់មាន អត់មានវៀតណាម។

**ស៖** សំណួរចុងក្រោយ ទាក់ទងទៅនឹងប្រជាជនចាម។ តើលោកមានបានទទួលការណែនាំ ឬក៏លោកមានដឹងអំពីគោលនយោបាយជាក់លាក់ណាមួយប្រឆាំងចំពោះប្រជាជនចាម ឬក៏ជនជាតិចាមដែរឬទេ?

[១០:៥៨:៣៥]

**ឆ៖** អរគុណ។ ចំពោះខ្ញុំបាទ ខ្ញុំអត់បានទទួលទេ ចំពោះប្រជាជនចាម វាអត់បាន ក៏គេមិនដែលផ្សព្វផ្សាយដែរ ព្រោះខ្ញុំផ្នែកសុខាភិបាល។ អ៊ីចឹងនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យគឺមិនដែលឲ្យពេទ្យដឹងទេ រឿងអីក៏ដោយ អ៊ីចឹងយើងអត់ដឹង។ ហើយខ្ញុំតែមិនដឹង គឺខ្ញុំឆ្លើយថាមិនដឹង។ អរគុណ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកសាក្សី ខ្ញុំសូមអរគុណដែលបានឆ្លើយនឹងសំណួរខ្ញុំ។ ខ្ញុំអស់សំណួរហើយលោកប្រធានសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តទៅនេះផ្តល់វេទិកាជូនទៅខាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក សេង លាង៖**

ជាបឋម ខ្ញុំបាទសូមគោរពអង្គសវនាការទាំងមូល។

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំបាទឈ្មោះ សេង លាង ជាសហព្រះរាជអាជ្ញារងជាតិ។ ថ្ងៃនេះខ្ញុំមានសំណួរមួយចំនួន បន្ថែមទៅលើសំណួរដែលអង្គជំនុំជម្រះបានសួរលោកសាក្សីកន្លងមកហើយ ហើយសំណួរដំបូងរបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងកាលពីម្សិលមិញ លោកបានមានប្រសាសន៍អំពីនីរសាររបស់លោក សោ ភឹម ម្នាក់ដែលរត់គេចខ្លួនលោករួចនោះ។ ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់ថា ដោយសារថាលោកឧស្សាហ៍ចេញចូលផ្ទះ ជួបជាមួយនឹង សោ ភឹម តើលោកអាចបញ្ជាក់បានទេថា នៅក្បែរ សោ ភឹម ហ្នឹងមានកងការពារ ឬក៏នីរសារជិតដិតហ្នឹងប្រហែលជាប៉ុន្មាននាក់ដែរ?

[១១:០០:២៣]

2-TCW-1065៖

**ឆ៖** អរគុណ។ នៅកងការពាររបស់ សោ ភឹម គឺមានប្រាំនាក់។ បាទ អរគុណ។

**ស៖** ឈ្មោះអីខ្លះ លោកអាចជួយប្រាប់បានទេ?

**ឆ៖** បាទ ឥឡូវវាភ្លេចអស់ នៅចាំតែពីរនាក់ទេ ឈ្មោះ ជឿក ហើយឈ្មោះហ្នឹង អ៊ឹង តែបីទៀតភ្លេចអស់ហើយ វាយូរឆ្នាំពេក។

**ស៖** តើលោកមានស្គាល់បុរសម្នាក់ឈ្មោះ នង នីម និងឈ្មោះ ចេង ដែរឬទេ?

**ឆ៖** ខ្ញុំបាទអត់ស្គាល់ទេ នង នីម ហើយ ចេង បាទអត់ស្គាល់។

**ស៖** បាទ មិនៗជាអ្វីទេ។ ឥឡូវលោកបានមានប្រសាសន៍ថា លោកស្គាល់ឈ្មោះ អ៊ឹង តើលោកស្គាល់គាត់ដល់កម្រិតណា លោកអាចជួយបញ្ជាក់បានទេ?

**ឆ៖** ចំពោះ ជឿក ហើយចំពោះ អ៊ឹង ហ្នឹងគឺតាមនិយាយវាត្រូវជាក្មួយដែរ និយាយវាត្រូវជាក្មួយខ្ញុំដែរ ប៉ុន្តែវាស្លាប់ទៅហើយ ជឿក ហ្នឹងក៏ស្លាប់ហើយ។ អរគុណ។

[១១:០១:៤១]

**ស៖** អរគុណលោកដែលបានជួយបំភ្លឺ។ ម្សិលមិញលោកបានមានប្រសាសន៍នៅប្រហែលជាម៉ោង០៣:០៩នាទី លោកបានមានប្រសាសន៍ពាក់ព័ន្ធជាមួយនឹង សោ ភឹម។ លោកបានប្រាប់គាត់ថា ប៉ុល ពត ក្បត់ហើយ ប៉ុន្តែលោក សោ ភឹម ហ្នឹងអត់ជឿលោកទេ គាត់ថា ប្រហែលជា សុន សេន ទេ

ជាអ្នកធ្វើរដ្ឋប្រហារ ប៉ុល ពត។ អ៊ីចឹងដើម្បីបញ្ជាក់រឿងហ្នឹងឲ្យបានច្បាស់ ខ្ញុំសូមអានបន្ថែមនូវកិច្ចសម្ភាសន៍ពីរ ដែលកិច្ចសម្ភាសន៍ទី១ គឺកិច្ចសម្ភាសន៍ពាក់ព័ន្ធជាមួយនឹងលោក នង ស៊ីម។ លោក នង ស៊ីម ហ្នឹងគឺជាមនុស្សដែលធ្វើនៅក្នុងកងការពាររបស់លោក សោ ភឹម ដែរ ហើយលោកបានផ្តល់នូវកិច្ចសម្ភាសន៍មួយជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥។ ហើយខ្ញុំសូមអានសម្រង់ហ្នឹងត្រង់ទំព័រទី៦២។ ខ្ញុំសូមអាន សំណួរចម្លើយគឺ លោកឈ្មោះ ដានី ហ្នឹងគាត់បានសួរទៅនឹងលោក នង អ៊ីម ថា៖ “គាត់និយាយ បើតាមលោកពូចាំ គាត់និយាយថាម៉េច? នង អ៊ីម បានឆ្លើយថា៖ គាត់ថា អញអត់មានខុសអីទេ។ ទៅដល់កន្លែងគល់តែម្តង។ ដានី៖--

**ប្រធានអង្គជំនុំ៖**

ឈប់! ឈប់!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមទោស តើខ្ញុំអាចសុំឯកសារយោងបានទេ ឬក៏ខ្ញុំស្តាប់មិនទាន់?>

**លោក សេង លាង៖**

ឯកសារហ្នឹងគឺជាឯកសារកិច្ចសម្ភាសន៍របស់ ឌី.ស៊ី.ខេម ដែលចុះថ្ងៃទី -- រវាងលោក នង ស៊ីម និងមន្ត្រី ឌី.ស៊ី.ខេម ដែលចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥។ ឯកសារហ្នឹងអត់មានជាភាសាអង់គ្លេសទេ មានជាភាសាខ្មែរ។ ហើយឯកសារហ្នឹងត្រូវបាន--

[១១:០៣:៣៣]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

*(គ្មានការបកប្រែ)*

**លោក សេង លាង៖**

អត់មាន E3 *ណាំប៊័រ*ទេឯកសារហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លេខ ERN E3 មានទេលោក?

**លោក សេង លាង៖**

ឯកសារនេះអត់មានE3ទេ ប៉ុន្តែឯកសារនេះត្រូវបានអង្គជំនុំជម្រះបានផ្ញើជូនភាគីម្តង ហើយជូនដំណឹងថា នឹងប្រើប្រាស់នៅក្នុងអង្គសវនាការ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមកែតម្រូវសហការីរបស់យើង ឯកសារមាន E3 គឺ E3/10717។ ឯកសារនេះបានទទួលកាលពី យកដាក់ក្នុងសំណុំរឿងកាលពីសប្ដាហ៍មុន ក៏មានលេខ ERN ផងដែរ។

**លោក សេង លាង៖**

សូមទោស ដោយសារខ្ញុំព្រីនឯកសារនេះចេញមក តែវាអត់មានឃើញលេខ ERN ហើយនិងលេខៗឯកសារ ហើយតែ--

[១១:០៤:៣១]

**ប្រធានអង្គជំនុំ៖**

លោកអាចៗសួរសំណួរផ្សេងទៅ! សួរសំណួរ -- លោកសួរសំណួរខាងផ្សេងទៀតទៅ ហើយទុកសំណួរនេះក្រោយទៅ។

**លោក សេង លាង៖**

អរគុណលោកប្រធាន។

**សួរដោយលោក សេង លាង៖**

**ស៖** អ៊ីចឹងខ្ញុំសូមចូលដល់ប្រធានបទមួយទៀតសិនទៅ ហើយខ្ញុំនឹងវិលមកប្រធានបទនេះផ្សេងទៀតក្រោយទៀត បើសិនជាខ្ញុំមានពេល។ ប្រធានបទមួយទៀត គឺពាក់ព័ន្ធជាមួយនឹងសង្គ្រាមនៅឆ្នាំចុងឆ្នាំ៧៧ហ្នឹង ខ្ញុំចង់ឲ្យលោកជួយបញ្ជាក់បន្តិចថា ថាតើលោកទៅ -- នៅពេលដែលគេបញ្ជូនលោកទៅសមរភូមិមុខក្នុងឆ្នាំ៧៧ហ្នឹង តើលោកបញ្ជាក់ពេលវេលាឲ្យបានច្បាស់មើល ថាតើនៅថ្ងៃណាឲ្យពិតប្រាកដ? ហើយពេលទៅដល់ភ្លាមហ្នឹង គឺគេឲ្យលោកធ្វើសង្គ្រាមភ្លាម ឬក៏មានការត្រៀមរៀបចំដែរ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ព្រោះខ្ញុំបាននិយាយកន្លងមក ក៏ខ្ញុំរួចហើយ ព្រោះខ្ញុំទៅសមរភូមិ រឿងថ្ងៃខែយើងអត់បានដឹង វាភ្លេចហើយ វាយូរហើយ ប៉ុន្តែយើងទៅក្នុងនាមសុខាភិបាល គឺទៅក្នុងនាមសុខាភិបាល ចុង៧៧ហ្នឹង។

[១១:០៦:០៦]

**ស៖** តើអំឡុងពេលហ្នឹង លោកទៅដល់មានការវាយប្រយុទ្ធជាមួយនឹងកងទ័ពវៀតណាមភ្លាម ឬក៏ខាងកងពលលេខ៤របស់លោកហ្នឹង មានពេលវេលាសម្រាប់ការត្រៀម មុននឹងធ្វើការវាយប្រហារ

ហ្នឹង? បើមាន តើការត្រៀមរយៈពេលប្រហែលប៉ុន្មានដែរ?

**ធ៖** អរគុណ។ ព្រោះទៅដឹងរយៈពេលប៉ុន្មានម៉ោង ប៉ុន្មានម៉ោង យើងអត់ដឹងទេ ព្រោះអត់កត់ត្រាទេ ប៉ុន្តែទៅហ្នឹង ទៅពេលយប់។ រយៈពេលប៉ុន្មានម៉ោង ក៏យើងមិនដឹងដែររឿងហ្នឹង មិនបានកត់ត្រាទុកទេ។ បាទ សូមអរគុណ មានប៉ុណ្ណឹងទេ។

**ស៖** លោកសាក្សី បើតាមកិច្ចសម្ភាសន៍របស់លោកជាមួយនឹង គឺនៅក្នុងឯកសារ E3/10668 គឺត្រង់សំណួរចម្លើយទី៩ លោកបានឆ្លើយថា ដែលសំណួរគេសួរថា៖ "តើការត្រៀមរៀបចំនៅក្នុងភូមិភាគបូព៌ាមានរយៈពេលប៉ុន្មាន មុននឹងពេលវាយវៀតណាមដំបូង ក្នុងឆ្នាំ៧៧? ចម្លើយលោកឆ្លើយថា៖ យើងត្រៀមរៀបចំប្រហែល១ខែមុនចាប់ផ្តើម។" តើលោកមានប្រតិកម្មយ៉ាងម៉េចចំពោះចម្លើយលោកនៅពេលនោះ?

**ធ៖** អរគុណ។ ជាមួយចម្លើយនេះ គឺប្រជុំក្នុងកងវរសេនាធំ ព្រោះខ្ញុំដឹងតាមកងវរសេនាធំប្រហែលជា១ខែ គេលើកគោលការណ៍ហ្នឹងប្រហែល១ខែ ដើម្បីឲ្យស៊ើបការណ៍ចុះពិនិត្យមើលតាមព្រំដែន។ តែ១ខែហ្នឹង របស់កងវរសេនាធំទេ ដែលប្រជុំនុំង ១៥៦ហ្នឹង។ បាទ អរគុណ។

[១១:០៧:៥៥]

**ស៖** លោកអាចជួយបញ្ជាក់បានទេថា ក្នុងអ្នកដែលបញ្ជូនលោកទៅធ្វើទ័ពនៅសមរភូមិមុខហ្នឹង នៅកងពល១៥៦ហ្នឹង តើគាត់ជានរណា? ហើយនៅក្នុងអង្គភាពហ្នឹង របស់លោកពេទ្យហ្នឹង តើមានគ្នាប៉ុន្មាននាក់ដែរ?

**ធ៖** អរគុណ។ ចុះពេទ្យដែលបញ្ជូនខ្ញុំទៅសមរភូមិមុខហ្នឹង ទៅនាមជាពេទ្យហ្នឹង គឺប្រធានកងវរសេនាធំ១៥៦ហ្នឹងឯង។ ហើយមានគ្នាប្រាំមួយនាក់ ពេទ្យហ្នឹងមានគ្នាប្រាំមួយនាក់ ព្រោះយើងនៅខ្សែត្រៀមខាងក្រោយ យើងមិនចូលប្រយុទ្ធទេ ព្រោះយើងក្នុងនាមជាពេទ្យ។ បាទ អរគុណ។

**ស៖** ក្នុងការត្រៀមលក្ខណៈរបស់លោកហ្នឹង តើអង្គភាពលោកហ្នឹង ត្រូវបានមានការរៀបចំបរិក្ខារ ថ្នាំពេទ្យ ឬក៏សម្ភារៈអីគ្រប់គ្រាន់ដែរទេ ដើម្បីត្រៀមក្នុងការធ្វើសង្គ្រាមពេលហ្នឹង? លោកអាចបញ្ជាក់បានទេ?

**ធ៖** អរគុណ។ ផ្នែកសុខាភិបាល កាលណាចុះធ្វើសមរភូមិ គេត្រៀមទាំងអស់ សម្ភារៈប្រើប្រាស់ បម្រើក្នុងសមរភូមិហ្នឹង គឺគេមិនឲ្យខ្វះទេ។ បាទ អរគុណ។

**ស៖** អ៊ីចឹងតើក្នុងអំឡុងពេល មុនពេលដែលបើកការប្រយុទ្ធហ្នឹង តើមានមេដឹកនាំមជ្ឈិម ឬក៏

មេដឹកនាំភូមិភាគដែលណា ត្រូវធ្វើទស្សនកិច្ចខ្សែត្រៀមជួរមុខនុ៎ងដែរឬទេ?

**ឆ៖** អរគុណ។ មុននឹងការប្រយុទ្ធនៅសមរភូមិនុ៎ង នៅមុខព្រួញខ្ញុំហ្នឹង អត់មានទេ។ អត់មានមជ្ឈិម អត់មានអីទេ គឺប្រធានអង្គភាពជាអ្នកគ្រប់គ្រងហ្នឹងតែម្ដង ១៥៦ហ្នឹងតែម្ដង។ អរគុណ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា ហេតុអ្វីបានជាគេជ្រើសរើសយកវរសេនាធំលេខ១៥៧ លោកហ្នឹង ជាគោលដៅក្នុងការវាយបន្ទាយលេខ២៧ របស់វៀតណាមហ្នឹង? លោកដឹងពីមូលហេតុទេ?

[១១:១០:៣២]

**ឆ៖** អរគុណ។ ចំពោះអង្គភាពកងវរៈ១៥៦ មិនមែន៥៧ទេ បាទ៥៦។ ១៥៦ ឈរចំមុខព្រួញហ្នឹង មុខព្រួញ១២៧។ អ៊ីចឹងកងពលលេខ៤ វាចែកគ្នាជាបីវរសេនាធំ។ វរសេនាធំ១៥៤ ឈរនៅមេមត់ ១៥៥ឈរនៅស្អំ-អំពុក បោះនៅបុសតាកុក ហើយខ្ញុំ១៥៦ហ្នឹងឈរចំផ្លូវលេខ២៧ហ្នឹង ខ្ញុំនៅក្រញូងហ្នឹង។ អ៊ីចឹងគឺទទួលមុខព្រួញហ្នឹង។ អរគុណ។

**ស៖** អរគុណលោកសាក្សី។ ខ្ញុំសួរសំណួរមួយទៀត ពាក់ព័ន្ធនឹងបញ្ហាហ្នឹងដែរ តើមុនការវ៉ៃ មុនការវ៉ៃបន្ទាយលេខ២៧ និងគោលដៅនានា តើមានការសិក្សាទេ ថាតើបើប្រៀបធៀបកម្លាំងទ័ពរបស់វៀតណាម សម្ភារៈសឹក ហើយនិងមធ្យោបាយនានា ហើយនិងកម្លាំងប្រយុទ្ធនុ៎ង តើមានការវ៉ៃតម្លៃថា កងពលលេខ៤ហ្នឹង នឹងអាចយកជ័យជម្នះលើវៀតណាមបានដែរទេ?

**ឆ៖** អរគុណ។ ឥឡូវចំពោះ១៥៦ មុខព្រួញ១៥៦ កាលណាមុននឹងធ្វើអីហ្នឹងគឺអង្គភាព១៥៦ហ្នឹងគឺស៊ើបការណ៍ចុះទៅហើយ ចុះទៅពិនិត្យជាក់ស្ដែង។ តើប្រៀបធៀបលទ្ធផលហ្នឹងយ៉ាងម៉េចអីម៉េច គេចុះ ព្រោះសមរភូមិ គ្រប់សមរភូមិណា ក៏គេធ្វើអ៊ីចឹងដែរ។ បាទ អរគុណ។

**ស៖** អ៊ីចឹងក្នុងការវាយគោលដៅផ្សេងៗ ដែលលោកបានរៀបរាប់កាលពីមុនហើយហ្នឹង រួមទាំងបន្ទាយ២៧ផង តើវរសេនាធំលេខ១៥៦របស់លោកហ្នឹង ប្រើកម្លាំងទ័ពប៉ុន្មាន? ហើយមានអាវុធយុទ្ធភណ្ឌអីខ្លះដែរ ក្នុងការគាំទ្រការវ៉ៃប្រហារពេលហ្នឹង?

[១១:១២:៣៧]

**ឆ៖** អរគុណ។ ចំពោះ១៥៦ វាមានជាង១.០០០នាក់ ប៉ុន្តែកម្លាំងគេមិនដែលប្រើទាំងអស់ទេ កម្លាំងយោធា គេប្រើមួយចំណែកតូចណាមួយ ទុកកម្លាំងផ្លាស់ប្ដូរ។ ឯអាវុធយុទ្ធភណ្ឌធុនធ្ងន់ មានត្រឹមតែត្បាល់៨០, ដេកា ហ្នឹងអាធុនធ្ងន់ មានប៉ុណ្ណឹង។ អរគុណ។

**ស៖** អ៊ីចឹងនៅក្នុងការវាយប្រហារបន្ទាយ២៧ហ្នឹង លោកបានមានប្រសាសន៍ថា កាលពីម្សិល

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

មិញលោកបានមានប្រសាសន៍ថា ក្រុមរបស់លោកវ៉ៃបានបែកខ្សែត្រៀមប្រហែលជាជាងពាក់កណ្ដាល ហើយតែដោយសារថា មានអន្តរាគមន៍ពីរថក្រោះ និងយន្តហោះវៀតណាមនោះ ទើបបានក្រុមលោកមិនអាចវ៉ៃបន្តទៀតបាន ហើយសម្រេចចិត្តដកថយ។ ហើយខ្ញុំចង់ឱ្យលោកបញ្ជាក់បន្តិចមើល ថាបើលោកជាពេទ្យហ្នឹង តើលោកអាចក្តាប់បានទេ តួលេខអ្នករបួស និងអ្នកស្លាប់នុំង តើលោកអាចក្តាប់បានដែរឬទេ? ហើយតើមានមេដឹកនាំណាមួយនៅក្នុងវរសេនាធំរបស់លោកត្រូវរងរបួសដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបជូនអ៊ីចេះ ព្រោះកន្លងមកវាភ្លេចទៅហើយយូរពេក រឿងរបួស រឿងស្លាប់ហ្នឹងតែងតែមានរបាយការណ៍ រាយការណ៍បូកសរុបជាប្រចាំ ជាប្រចាំថ្ងៃអ៊ីចឹង។ ប៉ុន្តែក្នុងនាមគណៈបញ្ជាការហ្នឹង គឺត្រូវរបួសម្នាក់ ឈ្មោះ ឈឿន ដែលគេបាញ់ត្រូវដើមទ្រូងហ្នឹង។ ហើយវាមាន -- វៀតណាមគេមានអន្តរាគមន៍តាំងពីរថក្រោះ តាំងពីយន្តហោះ ហោះពីលើ។ ត្រូវរបួសបញ្ជាការមួយឈ្មោះ ឈឿន។ បាទ អរគុណ។

**ស៖** តើ ជឿន ហ្នឹងគាត់ជាមេបញ្ជាការធំរបស់កងពល -- វរសេនាធំ១៥៦ ឬក៏មេបញ្ជាការថ្នាក់ ឋានៈណាដែរ លោកអាចប្រាប់បានទេ?

**ឆ៖** អរគុណ។ ឈឿន ហ្នឹងជាប្រធានយោធានកងវរសេនាធំ១៥៦។ បាទ អរគុណ។

**ស៖** ក្រោយពេលដែល ឈឿន ហ្នឹងរងរបួសនោះ តើគាត់រងរបួសធ្ងន់ទេ? ហើយគេបញ្ជូនគាត់ទៅព្យាបាលនៅឯណាដែរ លោកអាចប្រាប់បានទេ?

[១១:១៥:១៣]

**ឆ៖** អរគុណ។ ពេលដែលឈ្មោះ ឈឿន គណៈបញ្ជាការរងរបួសហ្នឹង គេបញ្ជូនទៅព្យាបាលនៅព-២នោះ ពេទ្យព-២ របស់ភូមិភាគនោះ។ បាទ អរគុណ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ក្រោយពីគាត់ត្រូវរបួសហើយ តើអ្នកណាគេឡើងកាន់ការងារជំនួសគាត់ ក្នុងការវាយនៅបន្ទាយ២៧ហ្នឹង?

**ឆ៖** អរគុណ។ ព្រោះក្នុងវរសេនាធំនីមួយៗគឺមានបួននាក់ បញ្ជាការមានបួននាក់ អ៊ីចឹងអត់មួយ បីនាក់ឡើងទៅជំនួសបាន គឺមានបួននាក់។ អរគុណ។

**ស៖** អរគុណលោកសាក្សី។ ឥឡូវចូលដល់សំណួរមួយទៀត នៅពេលដែលលោកមានប្រសាសន៍ថា ក្រុមរបស់លោកដោយសារវ៉ៃវាយមិនបែក ទើបដកមកតាមព្រំដែនវិញ។ តើលោកអាចរៀបរាប់បានទេ ថានៅពេលដែលក្រុមរបស់លោកមកនៅព្រំដែនហ្នឹង តើស្ថានភាពរបស់លោក កងទ័ព

របស់លោកហ្នឹង នៅព្រំដែនហ្នឹងគ្រាន់តែការទប់ទល់កុំឲ្យកងទ័ពវៀតណាមរុលចូលមកមុខ ឬក៏មានគោលដៅវ៉ៃទៅមុខថែមទៀត?

**ឆ៖** អរគុណ។ ចំពោះកងទ័ព១៥៦ ដែលបានដកមកក្រោយនេះ គ្រាន់តែមានវិធានការទប់ទល់ប៉ុនន៉ុងទេ ដើម្បីឲ្យ កុំឲ្យរំកិលចូលមកក្នុងទៀត។

[១១:១៦:៥៦]

**ស៖** តើលោកអាចបញ្ជាក់បានទេអំពីយុទ្ធវិធីដែលកងទ័ពរបស់លោកប្រើប្រាស់ក្នុងការទប់ទល់កុំឲ្យវៀតណាម កងទ័ពវៀតណាមរុលចូលមកក្នុងទឹកដីកម្ពុជាហ្នឹង គឺៗលោកប្រើយុទ្ធសាស្ត្រអីលោកអាចលម្អិតបានទេ?

**ឆ៖** អរគុណ។ ចំពោះបញ្ហាយុទ្ធសាស្ត្រ និងយុទ្ធវិធី យុទ្ធសាស្ត្រគឺរៀនដូចគ្នាទាំងអស់។ រៀនដូចគ្នា ប៉ុន្តែយុទ្ធវិធីគឺកលល្បិចរបស់បញ្ជាការមួយៗ អានេះវាអត់ដូចគ្នាទេ យុទ្ធវិធី វាខុសគ្នា។ អ៊ីចឹងមេទ័ពមួយៗត្រូវមានយុទ្ធវិធី។ ឯយុទ្ធសាស្ត្រនៅសាលារៀនតែមួយ អ្នកណាក៏ដូចអ្នកណាដែរ ប៉ុន្តែយុទ្ធវិធីនៃការប្រយុទ្ធជាក់ស្តែងនៅសមរភូមិ។ ប្រយុទ្ធយ៉ាងម៉េច កុំឲ្យគ្រោះថ្នាក់ច្រើន ហើយយកជ័យជម្នះ។ សូមអរគុណ។

**ស៖** អ៊ីចឹងក្នុងការការពារខ្លួនរបស់ក្រុមលោកហ្នឹង តើកងវរសេនាធំ១៥៦របស់លោកហ្នឹងមានប្រើប្រាស់មីន ឬក៏ចម្រូងដើម្បីក្នុងការដាក់តាមផ្លូវដើម្បីទប់ទល់ការរុលចូលរបស់កងទ័ពវៀតណាមដែរឬទេ?

**ឆ៖** អរគុណ។ អង្គភាពខ្ញុំអត់មានប្រើប្រាស់អីទេ មីនក៏ប្រើ ចម្រូងក៏ប្រើ អត់មានប្រើទេពេលនោះ។

**ស៖** អ៊ីចឹងក្រោយពេលដែល -- លោកថាលោកបានទប់ទល់អស់មួយរយៈពេលនៅព្រំដែនហ្នឹង អ៊ីចឹងនៅពេលដែលលោកថា វៀតណាមបានវ៉ៃដាច់វរសេនាធំលេខ១៥៥ ហើយរុលវ៉ៃមកពីក្រោយខ្នងទ័ពរបស់លោកទៀត តើពេលហ្នឹងមានរឿងអ្វីកើតឡើងចំពោះវរសេនាធំ១៥៦ របស់លោក?

[១១:១៩:០៩]

**ឆ៖** អរគុណ។ រឿងនេះ សំណុំរឿងពីម្សិលខ្ញុំជម្រាបម្តងហើយ។ ពួកខ្ញុំនៅជាប់នឹងខ្សែត្រៀមខាងមុខទេ ខ្សែត្រៀមខាងមុខ ប៉ុន្តែវៀតណាមដែលគេវ៉ៃដាច់ វ៉ៃដាច់នៅអំពុក នៅបុសតាកុក ១៥៥អ៊្ហ!។ អ៊ីចឹងវាបោះតាមផ្លូវជាតិលេខ៧មក មកព័ទ្ធពីក្រោយខ្នងអង្គភាពខ្ញុំ។ ដល់ព័ទ្ធអ៊ីចឹង យើងក៏មិនដឹងដែរ

មិនដឹងថាបុកដាច់ពីឯកើតមក ពីភ្នំបុសតាកុកដែរ។ ដល់ឃើញរថក្រោះវាបាញ់ទៅក្រោយខ្នង បានយើងដឹងថាអ្ហ៎! មានដាច់មុខព្រួញណាមួយហើយ។ អ៊ីចឹងយើងមុខព្រួញយើងក៏ដកថយ ដកថយមកលិចវិញ មកតាមក្បាលដំរី តាមទួលសង្កែទួលអី ដើម្បីមកទប់ មកទប់ខាងមុខវៀតណាមវិញ។ អាហ្នឹងប៉ុណ្ណឹង អរគុណ។

**ស៖** ចង់ឲ្យលោកជួយបញ្ជាក់ថា ក្នុងការវាយវៀតណាមនៅខែធ្នូ ឆ្នាំ៧៧ហ្នឹង តើកងទ័ពភូមិភាគបូព៌ាហ្នឹង បញ្ជូនទៅព្រំដែនទាំងអស់ ឬក៏មានរក្សាទុកក្រុមណាមួយនៅខាងក្នុង ដើម្បីទប់ទល់ក្នុងករណីដែលវ៉ៃមិនឈ្នះ ហើយវៀតណាមរុលចូលវិញ យកទ័ពនោះដើម្បីទប់ទល់ដែរទេ ឬក៏ដាក់នៅព្រំដែនទាំងអស់តែម្ដង?

**ឆ៖** អរគុណ។ ពេលដែលចាប់ផ្ដើមបើកយុទ្ធនាការ ពេលនុំងគឺកងទ័ពបញ្ជូនទៅទាំងអស់ អត់មានទុកក្នុងទេ អត់មានទេ។ បាទ អរគុណ។

**ស៖** បាទ អរគុណលោកសាក្សី។ អ៊ីចឹងលោកបានមានប្រសាសន៍ថា កងទ័ពវៀតណាមបានរុលចូលមកក្នុង រហូតដល់ភូមិខ្នារ ប្រហែលជា២០គីឡូចូលដល់ភូមិខ្នារ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ តើនៅពេលដែលវៀតណាមរុលចូលមកហ្នឹង តើមានកងទ័ពខ្មែរក្រហមទប់ទល់ជាមួយកងទ័ពវៀតណាមនោះទេ? បើមាន តើការទប់ទល់នោះយ៉ាងម៉េចដែរ?

[១១:២១:២៣]

**ឆ៖** អរគុណ។ ពេលវៀតណាមបុកចូលនេះ បុកដាច់ទាំងអស់ហ្នឹង អត់មានកងទ័ពណាទប់ទល់ទេ តាមផ្លូវជាតិលេខ៧ហ្នឹង។ អ៊ីចឹងបាន១៥៦, ១៥៤ ដកមកក្រោយដើម្បីទប់ស្កាត់ខាងមុខវៀតណាមទៀត មកទប់ស្កាត់ខាងមុខ។ ព្រោះពេលនុំងបុកដាច់អស់ហើយ ព្រោះដាច់ខ្សែត្រៀមខាងនោះហើយ ខាងខ្ញុំដកម៉េចនឹងទាន់ បើបុកដាច់មកហើយ។ អ៊ីចឹងយើងមានដកខាងក្រោយមក ដកបន្តមក បានយើងទប់ស្កាត់ខាងមុខវិញ ដើម្បីកុំឲ្យវៀតណាមរុល។ បាទ អរគុណ។

**ស៖** តើក្នុងការរុលចូលរបស់កងទ័ពវៀតណាមហ្នឹង លោកចាំបានទេថា តើកងទ័ពវៀតណាមហ្នឹងមានចំនួនច្រើនដែរឬទេ បើធៀបជាមួយនឹងកងទ័ពភូមិភាគបូព៌ាហ្នឹង? ហើយនៅពេលហ្នឹងតើវៀតណាមប្រើប្រាស់សព្វាវុធអីខ្លះ ហើយនិងកម្លាំងគាំទ្រអីខ្លះ ក្នុងការចូលលុកលុយនៅពេលនុំង?

**ឆ៖** អរគុណ។ នៅពេលវៀតណាមបុកចូលនេះគឺ វៀតណាមប្រើរថក្រោះ ប្រើអាវុធធុនធ្ងន់ទំនើបៗ ១៣០លី, ១០៥ និយាយរួមប្រើគ្រប់ប្រភេទ។ ហើយកម្លាំងបុកចូលគឺកម្លាំងស្រួចរបស់វៀត-

ណាម កម្លាំងធំ បុកដាច់មក។ អរគុណ។

**ស៖** អ៊ីចឹងតើកងពល១៥៦ និង១៥៥របស់លោកហ្នឹង ដែលដកមកខាងក្រោយទប់ហ្នឹង តើអាចទប់កម្លាំងវៀតណាមដែលរុលចូលហ្នឹងបានដែរឬទេ?

**ឆ៖** អរគុណ។ ពេលនោះមិនមែនតែកងទ័ព១៥៦ទេ កងទ័ពតំបន់ គ្រប់តំបន់ក៏មកចូលរួមដើម្បីទប់ស្កាត់ដែរ។ អ៊ីចឹងវៀតណាមអត់មានបុកចូលទៀតទេ អត់មានចូលទៀតទេវៀតណាម គឺនៅប៉ុណ្ណឹង ហើយនិងថយក្រោយទៅវិញ។ អរគុណ។

[១១:២៣:៣៨]

**ស៖** តាមដែលលោកសង្កេតនៅពេលហ្នឹង តើកម្លាំងកងទ័ពវៀតណាមហ្នឹង បើសិនជាកម្លាំងកងទ័ពវៀតណាមមានបំណងចង់រុលចូលមកមុខទៀតនោះ តើកងទ័ពកម្ពុជាប្រជាធិបតេយ្យពេលហ្នឹងអាចមានលទ្ធភាពទប់ទល់ដែរឬទេ?

**ឆ៖** អរគុណ។ ពេលនោះសភាពការណ៍កើតឡើងអ៊ីចឹង ឧទាហរណ៍ បើវៀតណាមបុករុលចូលមកមុខទៀត កងទ័ពប្រជាធិបតេយ្យអាចមាន ៗលទ្ធភាព។ នោះអាកងពលដែលគេបញ្ឈរទុកនោះសម្រាប់ទប់ស្កាត់ វាមាន មានពីរកងពលទៀត មានពីរកងពលទៀត។ អ៊ីចឹងដែលបុកចូលហើយនេះអាពួកពីរកងពលហ្នឹងណា៎ ពេលនុ៎ងវាដើរមកកាត់យប់តែម្ដង តាមភូមិតាអាំនេះកាត់ព្រៃមក ដើម្បីមកស្ទាក់កាត់ផ្លូវ។ ពីរកងពលហ្នឹង កងពលលេខ២ កងពលលេខ១ និងកងពលលេខ២នេះ។ អ៊ីចឹងវៀត-ណាម គេដកអស់។ គេដឹកសភាពការណ៍ អ៊ីចឹងគេដកអស់ គេអត់នៅទេ។

**ស៖** អ៊ីចឹងតាមអ្វីដែលលោកអះអាងហ្នឹង វៀតណាមដកពេលហ្នឹងដោយសារថា កងទ័ពកម្ពុជាប្រជាធិបតេយ្យមានកម្លាំងខ្លាំង ហើយអាចរើបណ្ដេញកងទ័ពវៀតណាមចេញពីតំបន់ដែលពួកគេចូលមកកាន់កាប់ហ្នឹង ឬក៏កងទ័ពវៀតណាម គេដកទៅដោយស្ម័គ្រៗ ដោយខ្លួនឯង?

**ឆ៖** អរគុណ។ រឿងនេះ កងពលលេខ១ និងកងពលលេខ២ហ្នឹង វាចូលមកហើយ វាដើរកាត់យប់ ម្យប់ៗទាល់ភ្លឺតែម្ដង ដើម្បីមកទប់ស្កាត់ផ្លូវ។ តែវៀតណាមគេដឹងសភាពការណ៍ហ្នឹង គេដកដោយខ្លួនឯង គេដកចេញ កុំឲ្យមានបញ្ហា។ វៀតណាមគេដកដោយខ្លួនឯង។

[១១:២៥:៣៩]

**ស៖** ក្រោយវៀតណាមដកហ្នឹង ទៅវិញ តើកងពលលេខ៤របស់លោកហ្នឹងមានធ្វើការបូកសរុបទេ ថាតើមានការខូចខាតកម្លាំងប៉ុន្មាន ហើយនិងបើសម្ភារៈបរិក្ខាប្រយុទ្ធប៉ុន្មានដែរ មានបូកសរុប

ទេ?

**ឆ៖** អរគុណ។ លោកសួរខ្ញុំ របួសកងពល រឿងកងពលខ្ញុំអត់ដឹងទេ ប៉ុន្តែគេត្រូវតែមានការបូកសរុបហើយ នៅតាមអង្គភាពនីមួយៗ ត្រូវតែបូក។ ការខូចខាតប៉ុន្មាន សម្ភារៈប៉ុន្មាន អាយុជីវិតមនុស្សប៉ុន្មាន របួសប៉ុន្មាន គេបូកសរុប ប៉ុន្តែខ្ញុំអត់បានដឹងទេ។ បាទ អរគុណ។

**ស៖** ចុះពេលហ្នឹង ក្រោយរៀតណាមដកទៅវិញហ្នឹង តើ សោ ភឹម មានបានទៅពិនិត្យកម្លាំងកងទ័ពសមរភូមិមុខដែរទេ?

**ឆ៖** អរគុណ។ វាជាធម្មតា ប្រធានភូមិភាគគេមិនដែលចុះសមរភូមិទេ គេចាំបញ្ជាឲ្យកងពលទេដែលចុះ។ ហើយកងពលហ្នឹង ក៏មិនចុះដែរ គឺប្រធានកងវរសេនាធំទេ អ្នកចុះ។ គឺទទួលបន្តគ្នា ហើយថ្នាក់ភូមិភាគ គេមិនដែលចុះទៅមើលទេ។ សូមអរគុណ។

**លោក សេង លាង៖**

លោកប្រធានដោយសារពេលវេលាវាជិតអស់ហើយ ហើយខ្ញុំគិតថា ខ្ញុំគួរតែពិនិត្យលេខ ERN ឲ្យបានច្បាស់ម្តងទៀត អ៊ីចឹងខ្ញុំសូមចប់ពេលហ្នឹង ហើយសូមទុកសំណួរហ្នឹងសួរពេលរសៀល តើសុំការអនុញ្ញាតពីលោកប្រធាន។

[១១:២៧:២៥]

**ប្រធានអង្គជំនុំ៖**

បាន មិនអីទេ!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមានលេខ ERN ហើយឬនៅ? លោក កូប៉េ បានលើកឡើងមកហើយថា បើឯកសារតែមួយអ៊ីចេះ គឺវាមានទាំងលេខ E3 និងមាន ERN ផងដែរហើយ។

**លោក សេង លាង៖**

លោកស្រីចៅក្រម ខ្ញុំមានឯកសារហ្នឹងហើយ ប៉ុន្តែខ្ញុំចង់ផ្ទៀងផ្ទាត់លេខ ERN និងចំណុចដែលខ្ញុំត្រូវដកស្រង់ហ្នឹង ក្រែងលោវាមានការខុសគ្នា។ អ៊ីចឹងខ្ញុំសុំពេលវេលាបន្តិចដើម្បីព្រាង កុំឲ្យពេលដែលខ្ញុំសួរទៅមានការភ័ន្តច្រឡំ។ សូមអធ្យាស្រ័យ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះពេលសមស្របសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាស

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះរសៀល។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ នៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក សេង លាង៖**

អរគុណលោកប្រធាន។ ដើម្បីជាកិច្ចចាប់ផ្ដើមនេះ ខ្ញុំចង់បង្ហាញរូបថតពីរសន្លឹកដែលរូបថតមួយគឺដកចេញពីក្នុងឯកសារ E3/10714 និងឯកសាររូបថតមួយទៀតគឺដកចេញពីឯកសារ E3/10715។ ដើម្បីសួរបញ្ជាក់សាក្សី ថាតើគាត់អាចស្គាល់មនុស្សពីរនាក់នេះទេ ហើយសំណួរគឺពាក់ព័ន្ធជាមួយនឹងបុគ្គលដែលបម្រើការនៅអង្គភាពការពាររបស់លោក សោ ភឹម។ សូមលោកប្រធានអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៣៥:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**លោក សេង លាង៖**

លោកប្រធាន ខ្ញុំសូមស្នើបញ្ចាំងរូបថតនេះនៅលើអេក្រង់ទូរទស្សន៍ផង ដើម្បីងាយស្រួលឲ្យភាគីតាមដាន។ គឺសូមបញ្ចាំងរូបទី១ គឺរូបដែលចេញពីឯកសារ E3/10715 ដែលមាន ERN ជាភាសាខ្មែរ 01327936 និង ERN  ជាភាសាអង់គ្លេស 01338191។

**សួរដោយលោក សេង លាង៖**

**ស៖** លោកសាក្សី  លោកមើលរូបនៅក្នុងអេក្រង់ទូរទស្សន៍នេះ  តើលោកមានស្គាល់បុរសម្នាក់នៅក្នុងរូបនេះដែរឬទេ?

**2-TCW-1065៖**

**ឆ៖** ថាម៉េចទេ សួរអំមិញ។ សូមអភ័យទោស សូមសួរម្តងទៀត អត់ឮផង។

**ស៖** សូមឲ្យៗលោកខាង -- អាឡូ! ស្តាប់ឮបានឬនៅ?

**ឆ៖** បាទៗ ឮហើយៗ។

**ស៖** អ៊ីចឹងសូមឲ្យលោកមើលរូបបុរសម្នាក់ដែលមានរូបនៅក្នុងអេក្រង់ទូរទស្សន៍ហ្នឹង  តើតាមលោកអាចចងចាំថា គាត់ជានរណាដែរឬទេ?

**ឆ៖** នីម។ ឈ្មោះ នីម នេះខ្ញុំសូមជម្រាបជូនអ៊ីចេះ។ បើតាមខ្ញុំមើលឃើញ នីម នេះប្រហែលជាអ្នកបើកបរឡានឲ្យ សោ ភឹម, នីម ហ្នឹង។

[១៣:៣៨:១៥]

**ស៖** បាទៗ អរគុណលោកសាក្សី។ អ៊ីចឹងខាង អេ.វី ជួយដាក់រូបថតមួយទៀត គឺរូបថតដែលចេញពីឯកសារ E3/10714 ត្រង់ ERN ជាភាសាអង់គ្លេស -- ខ្មែរ 01327930 និង ERN ជាភាសាអង់គ្លេស 01327936។ ERN ជាភាសាខ្មែរ 01327930 ហើយនិង ERN ជាភាសាអង់គ្លេស 01327 936។

**ប្រធានអង្គជំនុំ៖**

ខាងៗ សោតទស្សន៍បាន--

*(សម្រាករយៈពេលខ្លី)*

ហើយបានៗសហព្រះរាជអាជ្ញារងបានរៀបចំឲ្យខាងអេ.វីធ្វើមុនទេ?

**លោក សេង លាង៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

ឥឡូវព្រីនៗ យកតែក្រដាសទៅដាក់ជូនគាត់ទៅ ហើយប្រាប់ទៅភាគីពាក់ព័ន្ធឱ្យគេដឹងពីលេខទៅបានហើយ។

[១៣:៤១:៥៧]

**សួរដោយលោក សេង លាង៖**

**ស៖** អ៊ីចឹងឯកសាររូបថតមួយទៀតហ្នឹង គឺឯកសារដែលដកចេញពីឯកសារ E3/10714 ដែលមាន ERN ជាភាសាខ្មែរ 01327930 និង ERN ជាភាសាអង់គ្លេស 01327936។ សូមឱ្យលោកសាក្សីមើលរូបថតហ្នឹងទៅ តើលោកអាចចំណាំបានទេថា គាត់ជានរណា?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះរូបថតនេះ បើតាមខ្ញុំពិនិត្យមើល ឈ្មោះពិតប្រាកដឈ្មោះ អ៊ឹង មែន។ ប៉ុន្តែរឿងរ៉ាវទាំងអស់នៅបូព៌ា គឺមនុស្សហ្នឹងអាចដឹងរឿងច្រើន ឈ្មោះ អ៊ឹង ហ្នឹង។ គ្រាន់តែខ្ញុំស្គាល់ ប៉ុន្តែគ្មានទំនាក់ទំនងអីទេ ប៉ុន្តែដឹង អ៊ឹង គឺនៅជាមួយ សោ ភឹម។

**ស៖** អរគុណលោកសាក្សី។ ហើយបន្តិចទៀតខ្ញុំនឹងអានកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរបស់មនុស្សទាំងពីរនាក់នេះ ដែលគាត់បានធ្វើសម្ភាសកន្លងមកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ប៉ុន្តែមុននឹងដល់ការអានឯកសារនេះ ខ្ញុំសូមបែរត្រឡប់ទៅក្រោយបន្តិច ថាកាលពីម្សិលមិញម៉ោងប្រហែលជា០៣:០៩នាទី លោកបានមានប្រសាសន៍ថា លោកប្រាប់ ប៉ុល ពត ហើយ -- បានប្រាប់ សោ ភឹម ថា ប៉ុល ពត បានក្បត់ហើយ តែគាត់មិនជឿ។ គាត់ថា សុន សេន ទេដែលជាអ្នកធ្វើរដ្ឋប្រហារ ប៉ុល ពត។ ហើយបន្តិចក្រោយមកទៀត លោកបាននិយាយថា បើគាត់ជឿខ្ញុំ គាត់គេចខ្លួនកងទ័ពភូមិភាគបូព៌ាបីកងពលអាចការពារគាត់បាន។ ដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់នៅក្នុងរឿងនេះ ខ្ញុំសូមអានសម្រង់នៃកិច្ចសម្ភាសន៍មួយរបស់បុគ្គលម្នាក់ដែលមានឈ្មោះថា នង ស៊ីម ហើយដែលលោកអះអាងថាជាអ្នកបើកឡានឱ្យលោក សោ ភឹម ហ្នឹង គឺសម្រង់ហ្នឹងដកចេញពីឯកសារលេខ E3/10717 ត្រង់ ERN ជាភាសាខ្មែរ 01340501។ នេះគឺជាកិច្ចសម្ភាសន៍មួយដែលធ្វើឡើងរវាងឈ្មោះ នង អ៊ីម ជាមួយនឹងបុគ្គលិក ឌី.ស៊ី.ខេម ដែលមានឈ្មោះថា ដានី។ ហើយខ្ញុំសូមអានសម្រង់ដូចតទៅ--

[១៣:៤៤:៤៦]

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញារង ឈ្មោះអីគេ? អានឲ្យច្បាស់លាស់មើល ម្តង ស៊ីម ម្តងនេះម៉េច។ ឈ្មោះអីគេ?

**លោក សេង លាង៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

បើក! បើកក្បាលមីក្រូហ្វូន! អានៗឈ្មោះឲ្យច្បាស់! ម្តងដូចមិនច្បាស់ទេ មិនត្រូវឈ្មោះទេណ៎ា ហើយមានការប្រែប្រួល។

**សួរដោយលោក សេង លាង៖**

**ស៖** អរគុណលោកប្រធាន។ ប្រហែលជាកំហុសខ្ញុំគឺ ឯកសារនេះគឺឈ្មោះ នង នីម ដែលគាត់ផ្តល់សម្ភាសជាមួយនឹងបុគ្គលិក ឌី.ស៊ី.ខេម ដែលឈ្មោះ មានឈ្មោះថា ឡុង ដានី។ ហើយខ្ញុំសូមអានសម្រង់នេះដូចតទៅ៖ “ឡុង ដានី៖ គាត់និយាយ បើតាមលោកពូចាំគាត់និយាយថាម៉េចខ្លះ? នង នីម ឆ្លើយថា៖ គាត់ថា អញអត់មានខុសអីទេ ទៅដល់កន្លែងគល់តែម្តង។ ឡុង ដានី បានសួរទៀតថា៖ ទៅដល់កន្លែងពីណា? នង នីម ឆ្លើយថា៖ កន្លែងអាពត តែទៅៗជាមិនដល់។ ឡុង ដានី សួរថា៖ គាត់ថាម៉េច? នង នីម ឆ្លើយថា៖ គាត់ថា ទៅទាល់តែដល់ គាត់អត់មានខុសអីទេ អត់មានខុសអី។ ឡុង ដានី សួរថា៖ គាត់ថាអីចឹង? គាត់អត់មានខុសអីទេ? នង នីម ឆ្លើយថា៖ អត់ខុសអី។ ឡុង ដានី សួរទៀតថា៖ បំណងគាត់ ៗទៅភ្នំពេញតែម្តង? នង នីម ឆ្លើយថា៖ ទៅភ្នំពេញ។ ឡុង ដានី សួរថា៖ គាត់អត់ប្រុងរត់ អត់ប្រុងគេចខ្លួនទេ? នង នីម ឆ្លើយថា៖ អត់ព្រមគេចទេ បើគេចក៏រួចដែរ តែគាត់អត់ព្រមគេច។” ខ្ញុំសូមបញ្ចប់ការដកស្រង់ត្រឹមនេះ។ ហើយខ្ញុំចង់សួរលោកថាតើលោកមានប្រតិកម្មយ៉ាងណាចំពោះការលើកឡើងរបស់ឈ្មោះ នង នីម នៅក្នុងកិច្ចសម្ភាសន៍របស់គាត់នេះ?

[១៣:៤៦:៥៦]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះខ្លួនខ្ញុំៗអត់មានប្រតិកម្មទេ ព្រោះ នង នីម ជាអ្នកបើកឡានផ្ទាល់ឲ្យ សោ ភឹម ហ្នឹងហើយ នង នីម។ អត់មានប្រតិកម្មទេ ហើយរឿងរ៉ាវ ក៏យើងមិនដឹងអស់ដែរ។ ប៉ុន្តែ នង នីម គាត់ដឹងរឿងច្រើន យ៉ាងម៉េចៗ ខ្ញុំអត់មានប្រតិកម្មអីទេ។

**ស៖** អរគុណ។ ខ្ញុំនៅមានមួយសំណួរទៀតចង់ឲ្យលោកជួយបញ្ជាក់។ កាលពីម្សិលមិញ

លោកបានមានប្រសាសន៍ថា ឈ្មោះ អ៊ឹង ដែលគាត់ជាមនុស្សម្នាក់ដែលបានរត់គេចខ្លួនរួចនោះ។ ហើយ លោកក៏បានពិភាក្សាជាមួយឈ្មោះ អ៊ឹង ដែរក្រោយមកនោះ តើលោកអាចនិយាយលម្អិតបន្តិចទេ ថាតើ លោកបានពិភាក្សារឿងអីខ្លះជាមួយឈ្មោះ អ៊ឹង ហ្នឹង?

**ឆ៖** អរគុណ។ ចំពោះខ្ញុំៗអត់មានពិភាក្សាអីវែងឆ្ងាយ គ្រាន់តែសួរ។ សួរថាពេលដែល សោ ភឹម ហ្នឹងគាត់ទៅហ្នឹង ទៅជាមួយអ្នកណា? គ្រាន់តែសួរឈ្មោះ អ៊ឹង ប៉ុណ្ណឹង ឥឡូវឈ្មោះ អ៊ឹង នេះរូបថតនេះ ពិតប្រាកដហើយនេះ។ វាជាអង្គរក្សរបស់គាត់ ឈ្មោះ អ៊ឹង នេះ ប៉ុន្តែត្រកូលខ្ញុំអត់ចាំ។ ខ្ញុំគ្រាន់តែសួរតែ ប៉ុណ្ណឹងទេ ថាទៅហ្នឹងទៅជាមួយអ្នកណាខ្លះ? ហើយ អ៊ឹង ថាទៅជាមួយៗគាត់។ ហើយទិសដៅទៅ យ៉ាងម៉េចៗគឺខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់បានសួរប៉ុណ្ណឹង។ បាទ អរគុណ។

[១៣:៤៨:២៤]

**ស៖** អរគុណលោកសាក្សី។ អ៊ីចឹងដើម្បីរំឭករឿងដែល សោ ភឹម គាត់ទៅដល់អរិយក្សត្រហ្នឹង ខ្ញុំសូមអានសម្រង់មួយ ក្រែងលោថាលោកបានពិភាក្សា ប៉ុន្តែលោកភ្លេច ហើយបើសិនជាលោកនៅចាំ លោកអាចបញ្ជាក់ បើសិនលោកអត់ចាំ ខ្ញុំចង់ឲ្យលោកឆ្លើយតប មានប្រតិកម្មយ៉ាងម៉េចចំពោះសម្រង់ ហ្នឹង។ សម្រង់នេះគឺជាសម្រង់ដែលឈ្មោះ ស៊ិន អ៊ឹង បានផ្តល់ធ្វើកិច្ចសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌល ឯកសារកម្ពុជាដែរ គឺសម្រង់ឯកសារ E3/10716 ត្រង់ ERN ជាភាសាខ្មែរ 01340587 រហូត88។ វាងវែងបន្តិច ប៉ុន្តែវាចាំបាច់ដើម្បីបង្ហាញការពិត។ ខ្ញុំសូមអាន៖ ដានីបានសួរទៅកាន់ អ៊ឹង ថា៖ "ដានី សម្រាកនៅអរិយក្សត្រមួយយប់? អ៊ឹង បានឆ្លើយថា៖ សម្រាក។ ដល់អរិយក្សត្រហ្នឹង ថ្ងៃហ្នឹងភ្លៀង។ មកដល់អរិយក្សត្រមិនបានសម្រាក យប់ហ្នឹងថាប្រុងចូលភ្នំពេញ ថ្ងៃហ្នឹងមិនបានសម្រាកហ្នឹង។ ដើរ តាំងពីថ្ងៃថ្មើរនេះ ហើយវាភ្លៀង ដល់ភ្លៀងនៅសម្រាកហ្នឹង។ ហើយអ្នកដែលនៅអរិយក្សត្រហ្នឹង គេរត់ ចេញពីហ្នឹងដែរ គេរកចាប់ក្នុងក្រុងហ្នឹង វារត់មកនៅផ្ទះចម្ការហ្នឹង។ ដល់ផ្ទះចម្ការ គាត់ថា បងមិនបាច់ អញ្ជើញទៅទេ តែទៅគេចាប់ហើយ ព្រោះគេចាប់អស់ហើយខាងបូព៌ាយើងនៅក្នុងក្រុង។ ដល់អីហើយ គាត់ក៏នៅសម្រាកហ្នឹងទៅ។ សម្រាកហ្នឹងទៅ ដល់យប់គេមកព័ទ្ធចាប់បាញ់។ ដានី បានសួរថា៖ ដឹងថា កងពលជាអ្នកព័ទ្ធចាប់? អ៊ឹង ឆ្លើយថា៖ មិនដឹងដែរ។--"

[១៣:៥០:២៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំកត់សម្គាល់ឃើញថា ឯកសារហ្នឹងមានតែជាភាសាខ្មែរទេ មាន៧០ទំព័រ។ អ៊ីចឹងអាចផ្តល់ ERN ឬក៏លេខទំព័របានដែរឬទេ ព្រោះថាឥឡូវហ្នឹងយើងមិនដឹងថា លោកកំពុងអាននៅកន្លែងណាទេ សម្រង់ដែលលោកកំពុងអានហ្នឹង។ អ៊ីចឹងសុំលោកជួយផ្តល់លេខ ERN ហើយលេខទំព័រផងបានទេ?

**លោក សេង លាង៖**

សម្រង់ហ្នឹងខ្ញុំអាន ERNអំមិញខ្ញុំជម្រាបហើយគឺលេខ 0134058 ត្រង់ទំព័រ៥៧ និង 01340588 ត្រង់ទំព័រ៥៨។

**សួរដោយលោក សេង លាង៖**

**ស៖** អ៊ីចឹងខ្ញុំសុំអានបន្តទៀត៖ "អ៊ឹង ឆ្លើយថា៖ មិនដឹងដែរ។ ប៉ុន្តែមកដល់ហ្នឹង គាត់ផ្ញើសំបុត្រមួយចូលទៅភ្នំពេញ ហើយគាត់ថា ឱ្យចាំយកសំបុត្រមកវិញ។ ឱ្យនីរសារហ្នឹងទៅដល់ហ្នឹង យកសំបុត្រឱ្យ ប៉ុល ពត។ អីហើយហ្នឹង គេដេញនីរសារមកវិញ។ គាត់ផ្ញើសំបុត្រមួយទៀតទៅអ្នកស្មៀន ផ្ញើមួយទៀត ផ្ញើសំបុត្រអីហ្នឹង បញ្ជូនទៅទៀត។ គេដេញអ្នកហ្នឹងមកទៀត គេអត់ចាប់អ្នកនីរសារហ្នឹង។ ដានី សួរថា៖ ឈ្មោះអី? អ៊ឹង ឆ្លើយថា៖ មិនដឹងឈ្មោះ វានៅ វានៅក្មេង នៅភ្នំពេញ។ គេដេញមកវិញរហូត។ ដល់ដេញមកវិញ គាត់ដឹងហើយ ដឹងថា គេអត់ទទួលតប។ គេតបសំបុត្រមកវិញ ក៏គេមិនតប។ ជំនាន់ហ្នឹង គ្មានទូរស័ព្ទដូចឥឡូវឯណា។ រួចហើយគាត់ក៏ដឹងខ្លួនថា បែបផែនការអីហើយ។ គាត់មិនដឹង គាត់នៅតែនឹកឃើញថា គាត់ត្រូវតែចូលយ៉ាង។ ដានី សួរថា៖ បើសំបុត្រហ្នឹងគេសរសេរថាម៉េច? អ៊ឹង ឆ្លើយថា៖ សរសេរដាក់ថា គាត់មកដល់អរិយក្សត្រហើយ។ សូមឱ្យមិត្តមកយក មកទទួលខ្ញុំ ៗដល់អរិយ-ក្សត្រហើយ។ មកផ្លូវកាត់ គ្មានតាមផ្លូវសាឡាងណា ដាក់ខ្ញុំអ៊ីចឹង ស្តាប់ស្មៀន គេសរសេរហ្នឹង គាត់ប្រាប់។ ដានី ថា៖ គាត់មកដល់អរិយក្សត្រហើយ ឱ្យមិត្តមកទទួល? អ៊ឹង ឆ្លើយថា៖ ហ្នឹងហើយ។ ឱ្យមិត្រមកទទួល ខ្ញុំដល់អរិយក្សត្រហើយ។ ទៅសំបុត្រពីរដងមួយល្ងាចហ្នឹង។" ខ្ញុំសូមបញ្ចប់ការដកស្រង់ ហើយចង់សួរលោកសាក្សីថា តើរឿងហេតុអស់នេះ អ៊ឹង មានបានពិភាក្សាជាមួយលោកទេ? ហើយបើសិនជាមិនមានពិភាក្សាទេ តើលោកមានប្រតិកម្មតបអីទេ ចំពោះការលើកឡើងរបស់ អ៊ឹង?

[១៣:៥៤:០០]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះការលើកឡើងឈ្មោះរបស់ អ៊ឹង នេះចំពោះខ្ញុំ អត់មានអីប្រតិកម្មអីទេ

ព្រោះរឿងទាំងអស់ ព្រោះខ្ញុំអត់ដឹង ព្រោះឈ្មោះ អ៊ីង នេះដែលនៅតាមគាត់ ថាគ្មានប្រតិកម្មអីទេខ្ញុំនោះ។ លើកយ៉ាងម៉េចៗ ក៏ខ្ញុំគ្មានប្រតិកម្មដែរ ព្រោះអារឿង អ៊ីង ហើយនិងគាត់ដឹងរឿងច្រើន ព្រោះខ្ញុំនៅឆ្ងាយ ខ្ញុំអត់ដឹងទេ។ បាទ អរគុណ។

**លោក សេង លាង៖**

បាទ អរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំសូមបញ្ចប់សំណួរត្រឹមហ្នឹងហើយ។ ហើយប្រគល់វេទិកានេះជូនព្រះរាជអាជ្ញាអន្តរជាតិ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំទោសដែលត្រូវកាត់។ តាមបទពិសោធន៍កន្លងមកគឺថា យើងមិនអាចថា អានអត្ថបទមួយដ៏វែងល្អិត ហើយបន្ទាប់មកសួរអំពីប្រតិកម្មរបស់សាក្សីនោះទេ។ <បញ្ជាក់ឲ្យច្បាស់អ្វីដែលលោកចង់ដឹង។ តើលោកចង់ដឹងថាតើគាត់បាននៅទីនោះទេឬ? តើលោកចង់ដឹងថាតើគាត់ត្រូវនិយាយអ្វីអំពីទំនាក់ទំនងតាមប្រព័ន្ធទូរស័ព្ទ អំពីនីរសារ ហើយនិងអ្វីៗផ្សេងៗទៀតឬ? ខ្ញុំគិតថា វាគ្មានប្រយោជន៍អ្វីទេ ក្នុងការយកភស្តុតាងមានតម្លៃមកអានយ៉ាងវែង ដើម្បីឲ្យមាននៅក្នុងប្រតិចារឹក រួច>ហើយចុងក្រោយមកសួរពីប្រតិកម្មបែបនេះទៅវិញ។

**ប្រធានអង្គជំនុំ៖**

បាទ តទៅទៀត អត់អីទេ សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ។

[១៣:៥៥:២៧]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៀតដើម្បីឲ្យលោកបញ្ជាក់អំពីអ្វីដែលលោកបានប្រាប់យើង ហើយខ្ញុំសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់ ថាតើលោកដឹងអ្វីលោកមិនដឹងអ្វី។ គឺថាយើងនឹងសួរអំពីអ្វីដែលលោកបានឮ បានឃើញ និងបានដឹង។ ខ្ញុំសូមសួរសំណួរមួយចំនួនទាក់ទងទៅនឹងប្រវត្តិរូបរបស់លោក។ តើលោកធ្លាប់ទទួលការអប់រំដែរឬទេ? ហើយថាតើលោកទទួលការអប់រំបានដល់កម្រិតណាដែរ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចុះខ្ញុំទទួលបានការអប់រំដែរ គ្រាន់មើលបាន សរសេរបាន អានបាន ការអប់រំ។

**ស៖** លោកបានប្រាប់យើងកាលពីម្សិលមិញនៅពេលរសៀល ប្រហែលជាម៉ោង<១៣:៤៣> នាទី លោកបាននិយាយថា លោកបានចូលបដិវត្តន៍នៅថ្ងៃ២៩ មីនា ៧០ នៅស្វាយរៀង។ ហើយហេតុផលដែលលោកចូល ដោយសារតែសម្តេច ព្រះបរមរតនកោដ្ឋ អំពាវនាវឲ្យកូនចៅចូលទៅក្នុងព្រៃម៉ាគី។ មុនពេលដែលលោកចូលបដិវត្តន៍ តើលោកមានតួនាទី ឬក៏មានការងារអ្វីដែរ? ឧទាហរណ៍ថាតើលោកធ្វើស្រែ ធ្វើចម្ការ ឬក៏មានការងារអីផ្សេងទេ?

[១៣:៥៧:០៥]

**ឆ៖** អរគុណ។ ចំពោះខ្ញុំមុននឹងធ្វើបដិវត្តន៍ អត់មានតួនាទីអីទេ ជាកសិករសុទ្ធសាធ។ អរគុណ។

**ស៖** ផ្នែកដែលខ្ញុំទើបតែអានឲ្យលោកស្តាប់កាលពីមុននេះបន្តិច លោកនិយាយអំពីចូលបដិវត្តន៍នៅខែមីនា ៧០ ដោយសារតែ សម្តេចឪបានអំពាវនាវនោះ។ <>បក្សកុម្មុយនីស្តកម្ពុជា<បានចាប់ផ្តើមបដិវត្តន៍របស់ខ្លួនដើម្បី>ផ្តួលរំលំសម្តេចឪ <និងរដ្ឋាភិបាលរបស់សម្តេច>នៅឆ្នាំ៦៨។ ចុះថាតើចន្លោះពី៦៨ ដល់៧០ តើលោកនៅក្នុងបក្សកុម្មុយនីស្តនោះដែរឬទេ?

**ឆ៖** អរគុណ។ ក្នុងចន្លោះឆ្នាំ១៩៦៨មក៧០ គឺខ្ញុំអត់ដឹងទេ អត់ដឹង អត់ដឹងហើយ អត់ឮទៀតក្នុងចន្លោះហ្នឹង។

**ស៖** នៅពេលដែលលោកចូលបដិវត្តន៍ហ្នឹង តើលោកមានតួនាទីអ្វីដែរ ជាទាហានធម្មតា ឬក៏ជាមេបញ្ជាការ មានតួនាទីអ្វីដែរ?

**ឆ៖** អរគុណ។ ដែលខ្ញុំចូលបដិវត្តន៍ឆ្នាំ៧០នោះ គឺខ្ញុំមានតួនាទីជាកងអនុសេនាធំ។

**ស៖** តើលោកជាបញ្ជាការកងវរៈ, កងអនុ<សេនាធំ> ឬក៏គ្រាន់តែជាទាហានធម្មតាទេ?

**ឆ៖** ខ្ញុំជាកងអនុសេនាធំ កងអនុសេនាធំ។

**ស៖** កាលពីម្សិលមិញ លោកនិយាយថា កងអនុ<សេនាធំ>របស់លោកហ្នឹង មានទាហានប្រហែលជា១២០នាក់ អីចឹងមែនទេ?

[១៣:៥៩:៣៤]

**ឆ៖** បាទ គឺទាហានរបស់ខ្ញុំ គឺមាន១២០នាក់ ត្រឹមត្រូវ។

**ស៖** សូមអរគុណ លោកបញ្ជាក់ច្បាស់ហើយ។ តើលោកបានក្លាយទៅជាសមាជិកបក្សកុម្មុយ-នីស្តកម្ពុជាដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំបានទទួលជាទាហានកងអនុសេនាធំ។ ចូលឆ្នាំ៧១ហ្នឹង ខ្ញុំមិនដែលៗ បានទទួលតួនាទីជាបក្ស ស្អីៗទេ ព្រោះខ្ញុំមករៀនពេទ្យ ទៅខាងពេទ្យវិញ។ បាទ អរគុណ។

**ស៖** តើមានប្រវត្តិរូបអ្វីដែលធ្វើឲ្យលោកមិនអាចក្លាយទៅជាបក្ខជនបានទេ? ឧទាហរណ៍ដូច ជាប្រវត្តិក្រុមគ្រួសារ ឬក៏មានចំណុចអ្វីដែលធ្វើឲ្យលោកមិនអាចក្លាយជាបក្ខជនបាន?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ បានមិនក្លាយទៅជាបក្ខជន ព្រោះយើងរៀនពេទ្យ ខាងពេទ្យ វាមិន ចាំបាច់ប៉ុន្មានទេ។ ចូលក៏បាន មិនចូលក៏មិនបានដែរ រឿងពេទ្យ។ ដោយឡែកតែមេសមរភូមិមុខ អា ហ្នឹងគេចូលហើយ។ បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

អត់មានភាសាខ្មែរ ចេញមកសុទ្ធតែអង់គ្លេសទាំងអស់ ខ្ញុំ។

*(មានបញ្ហាបច្ចេកទេស)*

**ប្រធានអង្គជំនុំ៖**

បាទៗ អញ្ជើញ! អញ្ជើញតទៀត!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីខែមេសា៧៥ រហូតដល់ខែមករា ៧៩ តើលោកធ្លាប់ចូលរួមវគ្គរៀនសូត្រនយោបាយដែរឬទេ?

[១៤:០១:៤៧]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ចំពោះខ្ញុំ មិនដែលធ្លាប់រៀនសូត្រវគ្គនយោបាយណា អត់ដែលទេ ព្រោះផ្នែក ពេទ្យគេមិនសូវយកចិត្តទុកដាក់ប៉ុន្មានទេ អារឿងនយោបាយនយោអីហ្នឹង។

**ស៖** តើលោកធ្លាប់ទៅទីក្រុងភ្នំពេញដើម្បីចូលរួមវគ្គរៀនសូត្រ ឬក៏វគ្គបណ្តុះបណ្តាលអ្វីដែរទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អរគុណ។ ចំពោះរូបខ្ញុំ ៗមិនដែល មិនដែលទៅបើកវគ្គរៀនសូត្រនយោបាយអីនៅទីក្រុង ភ្នំពេញ អត់ដែល។

**ស៖** លោកបានប្រាប់យើងអំពីជម្លោះជាមួយវៀតណាម ចាប់ផ្តើមនៅក្នុងឆ្នាំ៧៣ ហើយលោក បានពន្យល់ថា វៀតណាមកម្ទេចចោលនូវសម្ភារៈផ្គត់ផ្គង់មកពីចិន នៅពេលនោះគឺមុនឆ្នាំ៧៥។ តើមាន

ការផ្លាស់ប្តូរប្រជាជនដែរឬទេ គឺផ្លាស់ប្តូរប្រជាជនវៀតណាមនៅកម្ពុជា ហើយនិងប្រជាជនកម្ពុជានៅវៀតណាម គឺគេប្តូរគ្នាឆ្លងកាត់ព្រំដែនដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ដូចខ្ញុំជម្រាបជូនអ៊ីចឹង ការផ្លាស់ប្តូរគឺតែទៅតាមច្រកព្រំដែន ទៅតាមបញ្ជាការ។ ហើយចំពោះខ្ញុំ វាជាតួនាទីរបស់ពេទ្យ អ៊ីចឹងមិនអាចដឹងទេរឿងនុ៎ង។ ការងារផ្លាស់ប្តូរយ៉ាងម៉េចៗ គេមិនដែលឲ្យពេទ្យដឹងទេ រឿងពេទ្យ។ អរគុណ។

[១៤:០៣:៥៣]

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពីអ្វីដែលលោកនិយាយ លោកចង់និយាយអំពីជនជាតិវៀត-ណាមចេញពីកម្ពុជាទៅវៀតណាម ហើយនិងជនជាតិខ្មែរ គឺខ្មែរក្រោមមកពីវៀតណាមចូលមកកម្ពុជាអ៊ីចឹងមែនទេ? តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** អរគុណ។ ខ្ញុំៗនិយាយ ហើយខ្ញុំដឹងៗរឿងណាដែលខ្ញុំឃើញ ហើយបើរឿងណាអត់ឃើញខ្ញុំអត់ដឹង ខ្ញុំបដិសេធ។ ព្រោះអត់ដឹង ហើយឮគេថា អត់យកជាផ្លូវការ។ ព្រោះរឿងខ្ញុំអត់ឃើញ ខ្ញុំអត់ទទួលស្គាល់ អត់ដឹង។ អរគុណ។

**ស៖** <នោះជាអ្វីដែលចង់ឲ្យលោកធ្វើ> ប៉ុន្តែខ្ញុំស្តាប់អត់ទាន់យល់។ នៅពេលដែលលោកនិយាយថា នៅពេលដែលមានការផ្លាស់ប្តូរតាមព្រំដែន តើលោកចង់និយាយអំពីការផ្លាស់ប្តូរវៀតណាមជនជាតិវៀតណាមដែលរស់នៅកម្ពុជាប្តូរទៅនៅវៀតណាមវិញ ឬមួយក៏យ៉ាងម៉េច? តើលោកចង់និយាយមានន័យអ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ កាលណានិយាយការផ្លាស់ប្តូរ ខ្ញុំអត់និយាយរឿងមនុស្សទេ។ ការផ្លាស់ប្តូរជំនាន់នោះ គឺរឿងសេដ្ឋកិច្ច។ ឧទាហរណ៍ថា យើងយកជ្រូក ឬយកគោ រកក្របី យកទៅដូរយកអំបិលផ្លាស់ប្តូរអ៊ីចឹងទេ មិនមែនផ្លាស់ប្តូរអី ពីមនុស្សមួយទៅមនុស្សមួយ គឺខ្ញុំអត់ដែលឃើញនៅឡើយ។

**ស៖** អរគុណ ឥឡូវខ្ញុំច្បាស់លាស់ហើយ។ បន្ទាប់ពីរបបខ្មែរក្រហមបានកើតឡើង ខ្ញុំចង់សួរលោកបន្តិច ដើម្បីឲ្យច្បាស់ ថាតើលោកបានដឹងអំពីអ្វី? ថាតើលោកមានវិទ្យុដែរឬទេ? ឬថាតើកងរបស់លោកមានវិទ្យុដែរឬទេ? តើលោកអាចស្តាប់ឮវិទ្យុពីទីក្រុងភ្នំពេញបានទេ?

[១៤:០៥:៥៣]

**ឆ៖** អរគុណ។ ចំពោះអង្គភាពរបស់ខ្ញុំ រឿងក្រុមរបស់ខ្ញុំ មិនដែលមានទូរទស្សន៍ទេ អ៊ូ!មិនដែលមានវិទ្យុទេ អត់ដែលស្តាប់ព័ត៌មានស្អីអី គឺមិនដែលស្តាប់ទេ។ អរគុណ តែប៉ុណ្ណឹង។

**ស៖** ចុះវិទ្យុទាក់ទងវិញ ថាតើកងរបស់លោកមានវិទ្យុទាក់ទង ដើម្បីទំនាក់ទំនង<ជាមួយមេបញ្ញាការរបស់លោក>ដែរឬទេ? <តើកងរបស់លោកមានវិទ្យុទាក់ទងចាប់តាំងពី៧៥ រហូតដល់អ្វីដែលលោកហៅថាជា>រដ្ឋប្រហារ<ថ្ងៃទី២៥ ខែឧសភា ៧៨>នុ៎ង គឺមុនពេលរដ្ឋប្រហារឆ្នាំ៧៨ហ្នឹង គឺមុនថ្ងៃ២៥ ខែ៥ ៧៨ហ្នឹង តើ កងរបស់លោកហ្នឹង មានវិទ្យុទាក់ទងទេ?

**ឆ៖** អរគុណ។ មុននឹងរដ្ឋប្រហារហ្នឹង ៧៨ហ្នឹង ពួកខ្ញុំនៅជាពេទ្យហ្នឹង ហើយពេទ្យគេមិនដែលមានវិទ្យុទាក់ទងអីទេ អត់ដែលមានទេ។ សម្រាប់តែព្យាបាលរបួស ជំងឺទេ ហ្នឹងរហូតដល់ ពី៧៧មក។ អត់ដែលមានទូរ -- វិទ្យុទាក់ទង អត់ដែលមានទេ។ បាទ អរគុណ។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺបានន័យថា ពីឆ្នាំ៧៧ គេបញ្ជូនលោកទៅសមរភូមិមុខ ក្នុងនាមជាពេទ្យទាហាន តើអ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ លោកនិយាយ គឺរឿងពិត វាទៅអ៊ីចឹង ព្រោះខ្ញុំទៅជាពេទ្យទាហាន ៧៧ហ្នឹង។

**ស៖** អ៊ីចឹងនៅពេលដែលលោកនិយាយអំពីពេទ្យវរសេនាធំហ្នឹង ថាតើពេទ្យហ្នឹង វាមានអគារឬមួយក៏ថា ជាពេទ្យចល័តទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ដែលទៅពេទ្យនៅសមរភូមិ គឺពេទ្យចល័ត គ្មានពេទ្យអគារទេ អត់មានទេ។ ជំនាន់នោះគ្មានអគារ មានអីទេ គឺពេទ្យចល័តនៅសមរភូមិតែម្តង។ អរគុណ។

**ស៖** តើមានបុគ្គលិកប៉ុន្មាននាក់ដែលនៅក្រោមឱវាទរបស់លោក នៅពេលដែលលោកធ្វើការនៅពេទ្យនោះ?

[១៤:០៨:២៤]

**ឆ៖** អរគុណ។ នៅក្រោមឱវាទរបស់ខ្ញុំទាំងអស់ បុគ្គលិកពេទ្យមាន២០នាក់។

**ស៖** តើបុគ្គលិកពេទ្យទាំងអស់ គឺសុទ្ធតែមានអាវុធដូចជាយុទ្ធជនដែរ ដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះពេទ្យទាំងអស់ហ្នឹង ដែលបុគ្គលិកទាំងអស់គ្មានអាវុធទេ គឺគេឲ្យបួនប្រាំដើម សម្រាប់ការពារកន្លែងប៉ុណ្ណឹងទេ កាលហ្នឹងគេមិនឲ្យ។ កាលណាចុះសមរភូមិ បានអង្គភាព បានគេប្រគល់ឲ្យ។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលជាពេទ្យនុ៎ង ថាតើលោកធ្លាប់ទទួលទស្សនាវដ្តីផ្សព្វផ្សាយ ឧបមាដូចជា ទស្សនាវដ្តីទង់បដិវត្ត ទស្សនាវដ្តីយុវជន-យុវនារីបដិវត្ត <គោលនយោបាយណាមួយ> ឬមួយក៏ថាមានការផ្សព្វផ្សាយព័ត៌មានអ្វីជាសាធារណៈដែរឬទេ នៅសម័យនោះ?

01377428



**ឆ៖** អរគុណ។ ចំពោះអង្គភាពខ្ញុំវិញ គេហៅថាអង្គភាពសម្រាប់សង្គ្រោះមនុស្ស អ៊ីចឹងគេមិនសូវផ្ដល់ព័ត៌មានអីឲ្យដឹងបានទេ ទស្សនាវដ្ដីឯកសារអីក៏អត់មានដែរ អត់មានទេ។ អត់មានដឹងឮថារឿងម៉េចៗ អត់ដឹងទេ។ សូមអរគុណប៉ុណ្ណឹង។

**ស៖** តើលោកអាចប្រាប់ទេថា លោកទៅសមរភូមិនៅឆ្នាំ៧៧ហ្នឹង តើទៅក្នុងខែណាដែរ ឬមួយក៏ថាអាចថានៅឆ្នាំ៧៦ ប្រសិនបើ៧៦ហ្នឹងខែណាដែរ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំទៅចុង៧៧ ខែ១២ ក្នុង៧៧ហ្នឹង ខែ១២ ប៉ុន្តែថ្ងៃ មិនដឹងជាថ្ងៃណាអត់ដឹង អត់ចាំ។

[១៤:១០:៥៤]

**ស៖** អ៊ីចឹងមុនខែ១២ ៧៧ គឺលោកនៅព្រៃវែង ប៉ុន្តែលោកនៅក្នុងពេទ្យ<យោធា។ តើត្រឹមត្រូវ>ទេ ឬមួយក៏លោកនៅកន្លែងណាផ្សេងមុនខែធ្នូ ឆ្នាំ៧៧នោះ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំមិនដែលនៅខេត្តព្រៃវែងទេ អត់មានដែរនៅព្រៃវែងទេ។

**ស៖** អ៊ីចឹងមុនខែ១២ ៧៧ហ្នឹង តើ<លោកធ្វើអ្វី ហើយ>លោកឈរជើង ឬក៏លោកបោះទីតាំងនៅកន្លែងណាដែរ?

**ឆ៖** អរគុណ។ មុនឆ្នាំ៧៧ គឺខ្ញុំនៅឈរជើងនៅអង្គភាព១៥៦ កងពលលេខ៤ ប៉ុន្តែនៅព្រៃវែងអត់មានទេ ខ្ញុំអត់ដែលនៅ។

**ស៖** អ៊ីចឹងលោកបោះទីតាំងនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំបាទបោះទីតាំងនៅភូមិឡូ អង្គភាពយើងខ្ញុំ។

**ស៖** តើលោកប្រាប់បានទេ តើភូមិឡូហ្នឹងនៅក្នុងខេត្តណាដែរ?

**ឆ៖** អរគុណ។ ភូមិឡូហ្នឹងនៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ឥឡូវនេះខេត្តត្បូងឃ្មុំ។

**ស៖** នៅពេលនុ៎ង តើមន្ទីរពេទ្យរបស់លោកមានទទួលអ្នករបួស ឬក៏អ្នកស្លាប់មកសង្គ្រោះទេមុនពេលដែលលោកត្រូវបានគេផ្ទេរទៅសមរភូមិមុខនោះ?

**ឆ៖** អរគុណ។ ចំពោះមន្ទីរពេទ្យ១៥៦ហ្នឹង បានជួយព្យាបាលរបួស ស្លាប់ក៏គេបញ្ជូនមកដែរ ហើយចំពោះប្រជាពលរដ្ឋនៅជុំវិញ ក៏ចូលទៅព្យាបាលនុ៎ងបានដែរ មិនបាច់តែថាទាហានទេ គឺកងពលអនុញ្ញាតឲ្យអ៊ីចឹង ឲ្យជួយព្យាបាល។

[១៤:១៣:២១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01377429



**ស៖** ចំពោះទាហានរបួស ហើយនិងស្លាប់ហ្នឹង តើលោកដឹងទេថាពួកគាត់ហ្នឹងរបួស ឬក៏ស្លាប់នៅក្នុងការវាយប្រហារ ឬក៏នៅក្នុងការប្រយុទ្ធបែបណា ប្រយុទ្ធជាមួយវៀតណាម ឬមួយក៏យ៉ាងម៉េច?

**ឆ៖** អរគុណ។ ការរបួសស្លាប់ហ្នឹង ហើយរបួសគេចែកជាពីរ បើរបួសហ្នឹងស្រាលទុកនៅព្យាបាលកន្លែងខ្ញុំ ប៉ុន្តែបើធ្ងន់ធ្ងរ ហ្នឹងបញ្ជូនទៅភូមិភាគហើយ។ ហើយអ្នករបួសអ្នកស្លាប់ហ្នឹងគឺប្រយុទ្ធគ្នាជាមួយវៀតណាមហ្នឹង អត់មានជាមួយអ្នកណាទេ។

**ស៖** តើលោកចាប់ផ្តើមឃើញអ្នកស្លាប់ដោយសារប្រយុទ្ធហ្នឹង គឺនៅក្នុងឆ្នាំណាដែរ ឆ្នាំ៧៥ ៧៦ ឬក៏៧៧?

**ឆ៖** អរគុណ។ ឥឡូវខ្ញុំនិយាយពីឆ្នាំ១៩៧៦ ព្រោះ៧៦ហ្នឹង គឺខ្ញុំ គឺបញ្ជូនពីខេត្តស្វាយរៀងមក ៗនៅភូមិភាគបូព៌ា។ អ៊ីចឹងខ្ញុំនិយាយមួយភូមិភាគបូព៌ាហ្នឹង ១៧៦អ៊ីចឹង ហើយការស្លាប់ហ្នឹងគឺស្លាប់ទៅនៅ គឺប្រយុទ្ធគ្នាជាមួយវៀតណាមហ្នឹង អត់មានស្លាប់នៅកន្លែងណាទៀត គឺអត់មានទេ។

**ស៖** សូមអរគុណ។ តើលោកដឹងទេថាតើការវាយប្រយុទ្ធដែលធ្វើឲ្យមានទាហានរបួស ស្លាប់ហ្នឹង តើការវាយប្រយុទ្ធហ្នឹងវាធ្វើឡើងនៅតំបន់ណាដែរ?

**ឆ៖** អរគុណ។ ការវាយធ្វើឲ្យរបួសស្លាប់សមរភូមិ ដូចខ្ញុំជម្រាបជូនពីមុនអ៊ីចឹង តាមព្រំប្រទល់ហ្នឹង គឺចាប់ពី២៧រហូតដល់ផ្សោត ដល់ក្រដាស អាហ្នឹងមួយមុខព្រួញ១៥៦ហ្នឹង គឺស្លាប់របួសនៅចំកន្លែងហ្នឹង។ អរគុណ។

**ស៖** អ៊ីចឹងទាហានដែលលោកបានទទួលមកព្យាបាលហ្នឹង គឺសុទ្ធតែជាទាហានមកពីកងវរសេនាធំ១៥៦ អ៊ីចឹងមែនទេ?

**ឆ៖** អរគុណ។ រឿងនេះរឿងពិត ត្រឹមត្រូវ។

[១៤:១៦:១៩]

**ស៖** ពាក់ព័ន្ធទៅនឹង<បន្ទាយ>២៧ ដែលលោកនិយាយថាវា<>នៅ<ក្នុងប្រទេស>វៀតណាម ហើយ<លោករួមចំណែក>ប្រតិបត្តិការនៅនេះផងដែរ ថាតើ<នោះជា>ពេល<តែម្តងគត់ តាមលោកដឹង> ដែលលោកបានចូលទៅវៀតណាម ឆ្លងព្រំដែនចូលទៅវៀតណាម <មុន>ពេល<>មានឧទ្ទម្ភាគចក្រមកដឹកលោកទៅទីក្រុងហូជីមិញអីហ្នឹង តើហ្នឹងវាជាពេលតែមួយ ឬក៏លោកមានពេលណាផ្សេងទៀតដែរ <ដែលលោកមានប្រតិបត្តិការឆ្លងព្រំដែនចូលទៅក្នុងប្រទេសវៀតណាមនោះ>?

**ឆ៖** អរគុណ។ ហើយលោកនិយាយអំមិញថា កងទ័ពវៀតណាម ២៧ មិនមែនកងទ័ព២៧ទេ

បន្ទាយដែលវៀតណាមរស់នៅ គឺបន្ទាយលេខ២៧ សូមបញ្ជាក់ឲ្យលោកច្បាស់។ បន្ទាយនោះគេហៅថា បន្ទាយ ឈ្មោះបន្ទាយ២៧ មិនមែនកងទ័ព២៧ទេ ហ្នឹងបញ្ហាមួយ។ បញ្ជាក់បញ្ហាទី២ ដែលលោកនៅតែងឿងឆ្ងល់ បញ្ហាខុទ្ទម្កាគចក្រដែលចុះយកខ្ញុំ នោះនៅឆ្នាំ៧៨ទេ ខែ១១ នៅមេមត់ ដែលខ្ញុំចាប់ផ្ដើមវ៉ៃពួកខ្មែរក្រហមនោះ។ អានោះផ្សេង រឿងផ្សេង រឿងក្រោយមកទៀត ដែលចុះយកខ្ញុំទៅរៀបចំរណសិរ្សនោះ អាហ្នឹងរឿងផ្សេងមួយទៀត អត់មានជាប់ក្នុងរឿងៗប្រយុទ្ធជាមួយវៀតណាមនៅបន្ទាយ២៧ទេ។ បាទ អរគុណ។

**ស៖** សូមទោស ខ្ញុំបាននិយាយពាក្យថាបន្ទាយ២៧ ប៉ុន្តែឥឡូវនេះខ្ញុំសួរឡើងវិញ។ ពិតហើយលោកទៅវៀតណាមពីរដង គឺទៅបន្ទាយ២៧ ហើយនិងនៅពេលក្រោយមកគឺខុទ្ទម្កាគចក្រដឹកលោកទៅ<ហូជីមិញ>។ ដូច្នេះខ្ញុំចង់សួរថា តើលោកមានទៅវៀតណាមផ្សេងពីពេលទាំងពីរនេះទៀតទេ? ថាតើលោកមានចូលរួមប្រតិបត្តិការទៅវៀតណាមនៅពេលណាផ្សេង មុនពេលដែលខុទ្ទម្កាគចក្រដឹកលោកទៅទីក្រុងហូជីមិញហ្នឹងដែរឬទេ?

[១៤:១៨:២៥]

**ឆ៖** អរគុណ។ ខ្ញុំមានតែពេលពីរទេ ក្រៅពីហ្នឹងអត់មានទេ។

**ស៖** នៅបន្ទាយ២៧ហ្នឹង តើទាហានវៀតណាមរស់នៅជាមួយក្រុមគ្រួសារដែរឬទេ នៅក្នុងបន្ទាយពួកគេនោះ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំអត់ដឹងទេ អត់ដឹងរស់នៅជាមួយគ្រួសារ ឬមិននៅជាមួយ អត់ដឹងព្រោះខ្ញុំអត់ដែលទៅ អ៊ីចឹងរស់នៅយ៉ាងម៉េច ក៏យើងអត់ដឹងដែរ។ បាទ អរគុណ។

**ស៖** បាទ មិនអីទេ អរគុណច្រើន។ ឥឡូវនេះខ្ញុំមានព័ត៌មានមួយចំនួនដែលខ្ញុំចង់អានឲ្យលោកស្ដាប់ ហើយខ្ញុំនឹងសួរលោក។ តើលោកស្គាល់ឈ្មោះ ឡេង អ៊ាង ទេ?

**ឆ៖** អរគុណ។ ព្រោះខ្ញុំអត់ស្គាល់ទេ ឡេង អ៊ាង អត់ដឹង--

**លោក សេង លាង៖**

ឈ្មោះមិនមែន ឡេង អ៊ាង ទេ, ឈ្មោះ ឡាយ អ៊ាន។

**2-TCW-1065៖**

**ឆ៖** អត់ដែលស្គាល់។

[១៤:១៩:៥៤]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ឥឡូវនេះខ្ញុំអាននូវចម្លើយមួយចំនួនរបស់គាត់ ហើយខ្ញុំនឹងសួរលោក។ គឺឯកសារE3/376 អង់គ្លេសមានលេខ 00278690, ខ្មែរមានលេខ 00270173, បារាំងមានលេខ 00486094។ <"ប្រហែល>៧ខែមុនថ្ងៃ០៧ មករា ៧៩ ខ្ញុំត្រូវបានគេបញ្ជាឲ្យរៀបចំ<អតីតយុទ្ធជនបង្កើតជា>ក្រុម <>ដើម្បីវាយប្រហារជាមួយវៀតណាម។ ប្រធានក្រុម ប្រធានកងវរសេនាធំ <ប្រធានកងពល> សុទ្ធតែជាកម្មាភិបាលរបស់និរតី។ គឺយើងបានវាយប្រហារទៅខាងក្រែក កំពង់ចាម ហើយ<ឆ្លងកាត់> បន្ទាយ២៧របស់វៀតណាម ចូលទៅក្នុងខេត្តតៃនិញ។" គឺថាប្រសិនបើតាមភាសាអង់គ្លេស គឺគេប្រើពាក្យថា "*ហ្វត ធ្វែនធីសេវេន*" ទៅវិញ។ "<ក្រុមខ្ញុំមានគ្នាប្រហែល២០០នាក់។> នៅក្នុងការវាយប្រហារនៅវៀតណាម ក្រុមខ្ញុំបានគប់គ្រាប់បែក <ដុត>ផ្ទះ <ដុតពេទ្យ>ទាហាន ក៏ដូចជាឃ្លាំងស្តុកអាវុធគ្រាប់រំសេវជាដើម។"

ហើយខ្ញុំចង់សួរលោកអំពីអ្វីដែល<លោក>និយាយគឺ ឯកសារមួយទៀតគឺ E3/470 ខ្មែរមានលេខ 00170623, បារាំងមានលេខ00205014 និងអង់គ្លេសមានលេខ 00205009។ គាត់បាននិយាយថា៖ "ក្រោយពេលមកដល់កំពង់ចាម គឺគេបញ្ជូនយើងទៅវាយប្រយុទ្ធនៅស្នួល ហើយនិងនៅក្នុងទឹកដីវៀតណាម នៅចាន់ទុង ក្នុងខេត្តតៃនិញ។ នៅពេលនោះ <>តាញ៉ា <ប្រធានកងពល២០៧> ហើយនិង តាសារី <អនុប្រធាន> បានបញ្ជាឲ្យយើងវាយប្រហារចូលទៅក្នុងភូមិ ហើយដុតផ្ទះសម្បែងនៅទីនោះ។ មនុស្សជាច្រើនបានស្លាប់ ហើយមនុស្សមួយចំនួនទៀតត្រូវបានគេចាប់ខ្លួន ហើយបង្ខំឲ្យសែងអ្នករបួស។"

ដូច្នេះខ្ញុំចង់សួរលោកថា មុនពេលដែលមានប្រតិបត្តិការដែលលោកបានចូលរួមនៅបន្ទាយ២៧ នោះ ខ្ញុំគិតថា វាអាចមានប្រតិបត្តិការផ្សេងមួយទៀត ដោយសារតែថាវាជាកងទ័ពរបស់និរតី <ប៉ុន្តែគាត់បាននិយាយថា ពួកគេត្រូវបានគេបញ្ជាឲ្យ>ទៅ<វាយប្រហារ និង>ដុតផ្ទះសម្បែង។ ដូច្នេះខ្ញុំចង់សួរថាតើនៅបន្ទាយ២៧ហ្នឹង វាមានភូមិស្រុកដែរ ឬមួយក៏ថាមានភូមិស្រុកនៅកន្លែងផ្សេងទេ?

[១៤:២៣:១៤]

**ឆ៖** អរគុណ។ បើនិយាយរឿងភូមិភាគនិរតី គឺខ្ញុំអត់ដឹង អត់ដឹងទេ។ តែចំពោះបន្ទាយ២៧ ខ្ញុំសុំបញ្ជាក់ចុះ ព្រោះវានៅឆ្ងាយពីភូមិ វាឆ្ងាយ វាដាច់ដោយឡែក គឺកន្លែងសម្រាប់ទាហានវៀតណាមគេការពារ។ រឿងនិរតី អត់ដឹងទេ ព្រោះ៧៧ហ្នឹង ខ្ញុំវាមិនដឹងនិរតីទៅវ៉ៃ ព្រោះមានតែភូមិភាគបូព៌ាទេ វ៉ៃមុន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេ។ ហើយបើថានិរតីទៅវ៉ៃទៀត អាហ្នឹងខ្ញុំមិនដឹង។ វារឿងរបស់គេ ខ្ញុំអត់ដឹង។ អរគុណ។

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំសូមបន្តទៅមុខទៀត។ ខ្ញុំមានសំណួរបន្ថែមទៀតទាក់ទងទៅនឹងអ្វីដែលលោកបាននិយាយ។ នៅក្នុងពេលដែលលោកនៅសមរភូមិមុខ ថាតើពេលវេលាហ្នឹង ជាពេលវេលាដែលគ្រោះថ្នាក់សម្រាប់លោក ក៏ដូចជាសម្រាប់កង<វរសេនាធំ>១៥៦ដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះការរស់នៅ ហើយការវាយប្រយុទ្ធនៅសមរភូមិ គឺគ្មានរឿងអីសុខទេ សុទ្ធតែរឿងគ្រោះថ្នាក់ទាំងអស់ សុទ្ធតែរឿងអាយុជីវិត តែចូលសមរភូមិគ្រោះថ្នាក់ហើយ បញ្ហាហ្នឹង។ មានប៉ុណ្ណឹង អរគុណ។

**ស៖** តើអ្នកដែលមកពី<វរសេនាធំរបស់លោក>និងកងដទៃទៀត<មកពីភូមិភាគបូព៌ា> ដែលបានចូលរួមនៅក្នុងការវាយប្រហារ<ឆ្នាំ១៩៧៧>ហ្នឹង ថាតើមានអ្នករបួស មានអ្នកស្លាប់ច្រើនដែរឬទេ? ក្នុងនាមលោកជាពេទ្យហ្នឹង តើលោកដឹងទេថា មានអ្នករបួស អ្នកស្លាប់ច្រើនទេ?

[១៤:២៥:១១]

**ឆ៖** អរគុណ។ ដែលខ្ញុំទទួលកិច្ចការងារនៅសមរភូមិមុខ រឿងស្លាប់មិនសូវច្រើនទេ ប៉ុន្តែច្រើនតែរបួស របួសច្រើន ស្លាប់មានដែរ ប៉ុន្តែមានតិច។ បាទ អរគុណ។

**ស៖** លោកបាននិយាយអំពីហេតុការណ៍នៅថ្ងៃ២៥ ឧសភា ៧៨ ដែលនៅពេលនោះមេបញ្ជាការជាច្រើនត្រូវបានចាប់ខ្លួន។ ថាតើមេបញ្ជាការទាំងអស់នេះ គឺជាមេបញ្ជាការដែលវាយប្រហារជាមួយវៀតណាម នៅក្នុងឆ្នាំ៧៧ និងដើមឆ្នាំ៧៨ មែនទេ?

**ឆ៖** អរគុណ។ មេបញ្ជាការដែលគេចាប់ទាំងអស់ហ្នឹង ជាមេបញ្ជាការនៅភូមិភាគបូព៌ា ហើយមេបញ្ជាការហ្នឹងដែលធ្លាប់វាយជាមួយវៀតណាម វាយជាមួយវៀតណាម។ អរគុណ។

**ស៖** តើការចាប់ខ្លួនមេបញ្ជាការហ្នឹង វាមានផលប៉ះពាល់អ្វីដល់សមត្ថភាពរបស់កម្ពុជាក្នុងការវាយប្រយុទ្ធ ឬក៏ទប់ទល់ជាមួយវៀតណាមនោះ?

**ឆ៖** អរគុណ។ ការចាប់ និយាយរួមបញ្ជាការនៅសមរភូមិមុខ តែចាប់ហើយមានតែការប៉ះពាល់ហើយ មិនមែនអត់ទេ ព្រោះរឹងៗ គឺនៅបញ្ជាការហ្នឹង ដែលធ្លាប់ប្រយុទ្ធនៅជាមួយវៀតណាម ហើយបើចាប់មេៗអស់ហើយ ហើយនៅតែកូនៗ ហើយយកទ័ពថ្មីទៅដាក់ សួរថាប្រយុទ្ធនោះវារឹងទេ? វាអត់រឹងទេ វាទៅថយចុះហើយ វាខ្សោយហើយ។ បាទ អរគុណ ជម្រាបជូនប៉ុណ្ណឹង។

**ស៖** អ៊ីចឹងលោកបានហៅថ្ងៃ២៥ ឧសភាហ្នឹងថាជារដ្ឋប្រហារ ហើយថា ប៉ុល ពត ជាជនក្បត់

ថាតើលោកចង់មានន័យថាម៉េច នៅពេលដែលលោកហៅ ដែលលោកប្រើពាក្យបែបនេះ?

[១៤:២៧:៣០]

**ឆ៖** អរគុណ។ ចំពោះខ្ញុំដែលបានប្រើពាក្យថា ថ្ងៃ២៥ ជាថ្ងៃរដ្ឋប្រហារ ថ្ងៃនុ៎ងហើយដែលកងទ័ពភូមិភាគកណ្ដាល ដែលឲ្យឈ្មោះ កែ ពក ហ្នឹងទៅចាប់តាមក្រសួង មន្ទីរ កងទ័ព ទៅចាប់ដាក់ខ្នោះចាប់យកទៅសម្លាប់ អ៊ីចឹងបានថ្ងៃហ្នឹងខ្ញុំហៅថា ថ្ងៃរដ្ឋប្រហាររបស់ភូមិភាគកណ្ដាល របស់ ប៉ុល ពត។ កើតឡើងនៅថ្ងៃនុ៎ង ហើយអាវុធវាផ្ទុះក្នុងប្រទេសក៏ថ្ងៃនុ៎ងដែរ ផ្ទុះក្នុងភូមិភាគបូព៌ានុ៎ងគឺថ្ងៃហ្នឹងតែម្ដង។ បាទ អរគុណ។

**សៈ** ហេតុអ្វីបានជាលោកចាត់ទុកថា ប៉ុល ពត ជាជនក្បត់? តើគាត់ក្បត់អីដែរ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំបានប្រើពាក្យថា "ប៉ុល ពត ក្បត់" ព្រោះធម្មតាមនុស្ស អ្នកណាក៏កើតមកចង់រស់ ចង់ស្រួល ចង់ឆ្ងាញ់ ចង់ល្អដែរ ប៉ុន្តែបើយើងអ្នកដឹកនាំគេ បញ្ជាកងទ័ពមកឲ្យសម្លាប់គេធ្វើទារុណកម្មសព្វបែបសព្វយ៉ាង អានុ៎ងហើយគឺជាក្បត់ហើយ គ្មានរឿងអីទៀតទេ មិនបាច់ទៅរកហេតុផលអីច្រើនទៀតទេ។ បាទ អរគុណ។

**សៈ** មុនពេលប្រតិបត្តិការរបស់ កែ ពក ចុះចាប់មេបញ្ជាការនៅថ្ងៃ២៥ ឧសភា <១៩៧៨> ថាតើមុននុ៎ងមានការចាប់ខ្លួននៅខាងបូព៌ា ឬក៏ចាប់ខ្លួនមេបញ្ជាការកម្មាភិបាលបូព៌ាដែរឬទេ?

**ឆ៖** បាទ អរគុណ។ ខ្ញុំនិយាយរឿងនេះ វែងបន្តិច។ ដំបូងនោះកងទ័ពបូព៌ានោះនៅសមរភូមិទេដើម្បីវាយវៀតណាមទេ។ ប៉ុន្តែភូមិភាគកណ្ដាលមកហ្នឹង កែ ពក ហ្នឹងមកនៅហ្នឹង មកស្នាក់នៅដូចជាតាហៀវ, នៅស៊្មឹង, នៅម៉ៃសាក់ ពីម្សិលបាននិយាយម្ដងហើយរឿងហ្នឹង ដែលកងទ័ពហ្នឹង កងទ័ពថាកងទ័ពមកជួយវ៉ៃភូមិភាគបូព៌ា វ៉ៃវៀតណាម។ ប៉ុន្តែផ្ទុយទៅវិញ មានវ៉ៃវៀតណាមឯណា វាលេងក្រសួងមន្ទីរខាងក្រោយហ្នឹង ដែលចាប់ក្រសួងមន្ទីរទាំងអស់ហ្នឹង ទាំងកម្មាភិបាលនៅខាងក្រោយហ្នឹង។ រឿងវាអ៊ីចឹង។ គេមកមុនដំបូងគេថាវ៉ៃវៀតណាម ប៉ុន្តែមិនវ៉ៃវៀតណាម លេងអាក្រសួង មន្ទីរខាងក្រោយហ្នឹង ស្ថាប័នខាងក្រោយហ្នឹង។ អាណាចាប់បានចាប់ អាណារត់រួច រត់រួច ផ្ទុះអាវុធនៅពេលហ្នឹង។ រឿងហ្នឹងប៉ុណ្ណឹង បាទ អរគុណ ជម្រាបជូនដោយខ្លីៗ។

[១៤:៣០:២៩]

**សៈ** ខ្ញុំនឹងបន្តសួររហូតដល់ពេលលោកប្រធាន គាត់ជម្រាបមកខ្ញុំថាដល់ពេលឈប់សម្រាកហើយ។ តើការចាប់ខ្លួនហ្នឹង ចាប់ផ្ដើមនៅក្នុងឆ្នាំណា?

**ឆ៖** អរគុណ។ គឺចាប់ខ្លួនកម្មាភិបាលហ្នឹង គឺដែលកើតខ្លាំងបំផុតគឺឆ្នាំ១៩៧៨ – ៧៨ហ្នឹងតែម្តង ៧៨ដែលខ្លាំង។

**សៈ** ចម្លើយរបស់លោកកាលពីម្សិលមិញនៅម៉ោង១៥:០៦នាទី លោកបាននិយាយអំពីចុងឆ្នាំ៧៧។ លោកថា៖ “នៅពេលនោះយើងមានសង្គ្រាមជាមួយនឹងវៀតណាម ខ្ញុំនៅឯសមរភូមិ ប៉ុន្តែល្ងាចមួយប្រហែលជាម៉ោងប្រាំល្ងាច ខ្ញុំបានមកផ្ទះរបស់ខ្ញុំ ៗបានជួបជាមួយនឹង សោ ភឹម។ ហើយគាត់បានសួរខ្ញុំអំពីសមរភូមិមុខ ខ្ញុំឆ្លើយប្រាប់គាត់ថា អត់ល្អទេ។” លោកនៅចាំទេ ដែលថាលោកមានការសន្ទនាជាមួយ សោ ភឹម?

**ឆ៖** អរគុណ។ ព្រោះខ្ញុំទៅៗមែន ទៅលេងគ្រួសារនៅភូមិភាគ ហើយបានសន្ទនានៅពេលយប់ម៉ោងប្រាំបួនហ្នឹង។ គាត់សួរៗ ខ្ញុំប្រាប់ និយាយរឿងៗពិត ខ្ញុំនិយាយអ៊ីចឹងមែន។ ខ្ញុំប្រាប់គាត់ ថាសភាពការណ៍នៅខាងមុខអត់ល្អ។ សូមអរគុណ។

[១៤:៣២:២៩]

**សៈ** នៅពេលនោះ នៅពេលដែលលោកនិយាយថា ស្ថានភាពអត់ល្អទេ <តើលោកនិយាយសំដៅទៅលើសមរភូមិប្រយុទ្ធជាមួយវៀតណាម ឬក៏លោកសំដៅទៅលើអ្វីផ្សេង ដូចជាការចាប់ខ្លួនការបោសសម្អាតជាដើម តើលោក>និយាយពីអ្វីដែរ?

**ឆ៖** អរគុណ។ ខ្ញុំបានប្រើពាក្យ និយាយថាពាក្យ “អត់ល្អ” ត្រង់នេះគឺការប្រយុទ្ធ ការប្រយុទ្ធអត់ល្អ វាមានគ្រោះថ្នាក់ច្រើន ត្រង់ហ្នឹងហើយដែលខ្ញុំថាប្រយុទ្ធវាអត់ល្អ។ នៅសមរភូមិនុំងមិនទាន់មានអ្នកណាចាប់ខ្លួនទេ ព្រោះចាប់អត់បានទេ នៅខ្សែត្រៀមមុខ តែចាប់ភ្លាមគ្រោះថ្នាក់ភ្លាម។ អ៊ីចឹងគ្រាន់តែប្រយុទ្ធវាអត់ល្អ ខ្ញុំចង់និយាយហ្នឹងបានន័យថាប៉ុណ្ណឹង។

**សៈ** ហើយបន្ទាប់មក (សូមទោស) បន្ទាប់មក លោកនិយាយថា សោ ភឹម បានវិភាគអំពីស្ថានការណ៍នោះ។ ហើយគាត់បាននិយាយថា មានព្យុះនៅចិន ប៉ុន្តែព្យុះហ្នឹងវាប៉ះពាល់មកដល់កម្ពុជា។ តើគាត់មានបានពន្យល់ថា គាត់ចង់មានន័យថាដូចម្តេចដែរទេ?

**ឆ៖** អរគុណ។ ដែលខ្ញុំនិយាយ ខ្ញុំគោលបំណងរបស់ខ្ញុំចង់និយាយតែការប្រយុទ្ធ។ ប៉ុន្តែនិយាយបញ្ហាទី១ និយាយពីដើមឈើ ខ្ញុំនិយាយពីដើមឈើ។ ដើមឈើដែលធំៗដុះនៅតាមព្រំដែន ដែលនៅតាមការប្រយុទ្ធគ្នាហ្នឹងណ៎ា ខ្យល់មិនខ្យល់ប៉ុន្មាន ប៉ុន្តែវាដួល រលើងទាំង ដួលទាំងអស់តែម្តង ដួលគ្រឹមៗដួល។ អ៊ីចឹងដល់ដួល ខ្ញុំនិយាយពីដើមឈើ។ ដល់ដើមឈើអ៊ីចឹងវាអត់ល្អទេ បើដួលអ៊ីចឹង គាត់ថាវាអត់

អីទេ អារឿងហ្នឹងវានោះព្យុះនៅចិនទេ ប៉ុន្តែឥទ្ធិពលមកវាដល់កម្ពុជា។ អាហ្នឹងនិយាយអ៊ីចឹង ដែលខ្ញុំ និយាយក្នុងគោលបំណងប៉ុណ្ណឹង។

[១៤:៣៥:០១]

**ស៖** ខ្ញុំនៅតែច្របូកច្របល់ មិនយល់ថាគាត់ចង់មានន័យថាម៉េច ប៉ុន្តែខ្ញុំរំលងចំណុចនេះចុះ។ <លោកបាននិយាយថា> នៅក្នុងការសន្ទនានោះ នៅម៉ោង១៥:០៧នាទី លោកនិយាយថា៖ “បញ្ហាហ្នឹង គឺយើងចាប់ផ្តើមប្រយុទ្ធជាមួយនឹងវៀតណាម។ នៅពេលនោះវៀតណាមអត់ប្រយុទ្ធជាមួយយើងទេ។ ហើយការមានជម្លោះប្រដាប់អាវុធផ្ទៃក្នុងហ្នឹង កើតឡើងនៅខែឧសភា ខ្ញុំដឹងស្ថានភាពនេះមិនល្អទេ។ ហើយខ្ញុំបានគិតថា មានអ្នកខ្លះជាមនុស្សក្បត់ ហើយខ្ញុំបាននិយាយលេងជាមួយនឹងគាត់ គឺថាអាចថា ប៉ុល ពត ជាអ្នកក្បត់។ ហើយគាត់និយាយថា បើ ប៉ុល ពត ជាអ្នកក្បត់ ប៉ុល ពត អាចនឹងប្រាប់គាត់ហើយ។” សូមបញ្ជាក់ឲ្យច្បាស់ នៅពេលដែលលោកមានការសន្ទនាជាមួយ សោ ភឹម នៅចុងឆ្នាំ១៩៧៧ គឺ ការសន្ទនានេះ គឺនៅមុនការចាប់ខ្លួនក្នុងខែឧសភា ៧៨មែនទេ?

**ឆ៖** អរគុណ។ គឺមុន ៧៨ ហើយពេលនោះគឺខ្ញុំចេញពីសមរភូមិទៅ ទៅអង្គុយលេងហ្នឹងខែភ្លឺ លើគ្រែខាងមុខផ្ទះហ្នឹង អង្គុយលេងពីរនាក់គាត់ ហើយគាត់ក៏សួរ ថាយ៉ាងម៉េច សភាពការណ៍ ខ្ញុំថា សភាពការណ៍ ដូចវាមិនស្រួល សភាពការណ៍យោធា ដូចអត់ស្រួលទេ ប្រហែលជាមានពួកក្បត់ហើយ ធ្វើរដ្ឋប្រហារនុ៎ង។ ខ្ញុំនិយាយអ៊ីចឹង។ ហើយបើក្បត់អ្នកណា? ខ្ញុំថា មានអ្នកណា វាមានតែ ប៉ុល ពត។ ហើយគាត់ក៏មិនជឿខ្ញុំដែរ គាត់ថាបើ ប៉ុល ពត ក្បត់ រឿងអីមិនប្រាប់គាត់ ព្រោះគាត់ក្នុងនាមជាអ្នកភូមិភាគមួយដែរ។ ខ្ញុំថា ធម្មតាគេៗក្បត់ គេមិនដែលប្រាប់ទេ ហើយគាត់សន្និដ្ឋានថា សុន សេន ព្រោះអ្នក កាន់ទ័ត ក្បត់អ៊ីចឹង។ បាទ រឿងហ្នឹងប៉ុណ្ណឹង។ បាទ អរគុណ។

[១៤:៣៧:១៩]

**ស៖** គ្រប់ការសន្ទនារបស់លោកជាមួយនឹង សោ ភឹម តើគាត់ ថាគាត់មានភាពប្រទូសរ៉ាយអី ជាមួយនឹង ប៉ុល ពត ឬមានផែនការទម្លាក់ ប៉ុល ពត ឬមានផែនការសម្លាប់ ប៉ុល ពត អីដែរទេ? គាត់ ដែលប្រាប់លោកទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ ខ្ញុំមិនដែលឮ អត់ដែលឮទេ ថាមានផែនការទម្លាក់ ប៉ុល ពត មាន ផែនការអី គាត់ដែល អត់ដែលនិយាយទេ អត់ដែលនិយាយ។ អ៊ីចឹងខ្ញុំក៏អត់ដែលដឹងដែរ។ អានេះជាទឹក ចិត្តរបស់គាត់ គេធ្វើយ៉ាងម៉េច ក៏យើងមិនដឹងដែរ ព្រោះគាត់អត់ប្រាប់ ព្រោះទាល់តែគាត់ប្រាប់ ចេញជា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ពាក្យសម្ដីមក បានខ្ញុំដឹង។ បាទ អរគុណ មានប៉ុណ្ណឹង។

**ស៖** បាទ សូមកែតម្រូវផង បើខ្ញុំខុស។ លោកគឺជាសាច់ញាតិរបស់គាត់ ហើយជាមនុស្សម្នាក់ដែលគាត់ធ្លាប់និយាយជាមួយ។ តើលោកយល់ឃើញថា សោ ភឹម ស្មោះត្រង់នឹងលោកទេ? ហើយរាល់អ្វីដែលគាត់គិតទាំងអស់ហ្នឹង លោកគិតថា គាត់ស្មោះត្រង់នឹងលោកទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ អត់គិតអីចឹងទេ ព្រោះខ្ញុំគិតផ្សេង។ ការរាប់អានគឺជាឪពុកមា ប៉ុន្តែរាប់អានជាធម្មតា ឲ្យគិតរឿងស្មោះត្រង់ មិនស្មោះត្រង់អី ខ្ញុំអត់និយាយទេ ព្រោះគាត់ជាឪពុកមា គ្រាន់ខ្ញុំគ្រាន់តែនិយាយអី ខ្ញុំស្ដាប់ ប៉ុន្តែឲ្យខ្ញុំសួរអី ខ្ញុំអត់សួរទេ។ ហើយការស្មោះត្រង់ ក៏ខ្ញុំមិនៗនិយាយថាទេ គាត់ក្បត់ខ្ញុំ ឬស្មោះត្រង់ ក៏ខ្ញុំអត់មាននិយាយដែររឿងហ្នឹង។ អរគុណ។

**ស៖** សំណួរខ្ញុំសួរថា តើ សោ ភឹម មានផែនការសម្លាប់អីដែរឬទេ ព្រោះមានការចោទប្រកាន់ <ពីខាងមេធាវីការពារក្ដី>ថា គាត់មានផែនការសម្លាប់ជាមួយវៀតណាម? <លោកជាទាហាននៅភូមិភាគបូព៌ា ហើយលោកជាសាច់ញាតិរបស់គាត់។ តើ>គាត់<ធ្លាប់>ព្យាយាមជ្រើសរើសលោក ចូលធ្វើកងទ័ព<>ដើម្បីប្រយុទ្ធជាមួយ ប៉ុល ពត <ដែរទេ>?

[១៤:៣៩:៣០]

**ឆ៖** អរគុណ។ អម្បាញ់មិញចង់និយាយថា សោ ភឹម មានផែនការសម្លាប់ជាមួយវៀតណាម អាហ្នឹងខ្ញុំអត់ដឹង អត់ដឹង។ រឿងផែនការសម្លាប់ ផែនការចំហរម៉េច ខ្ញុំអត់ដឹងទេ ព្រោះគាត់អត់ប្រាប់។ បើគាត់ប្រាប់ បានខ្ញុំដឹង ហើយបើមិនប្រាប់ យើងធ្វើម៉េចនឹងដឹង អត់ដឹង។ ការចោទប្រកាន់ពីមួយទៅមួយ ហ្នឹងវាជារឿងភាគីទាំងពីរនុ៎ង។ អាហ្នឹងខ្ញុំអត់ដឹងទេ។ បាទ អរគុណ។

**ស៖** សុំបញ្ជាក់ឲ្យបានច្បាស់លោកសាក្សី ខ្ញុំមិនបាននិយាយថា គាត់មានផែនការសម្លាប់ទេ។ អីចឹងបញ្ជាក់ឲ្យបានច្បាស់។ តើលោកធ្លាប់ដែលបានឃើញទាហានវៀតណាមត្រូវបាន<វរសេនាធំ ១៥៦ ឬក៏វរសេនាធំរបស់លោក ឬក៏>វរៈណាមួយ <របស់>កងទ័ពកម្ពុជាប្រជាធិបតេយ្យ អង្គភាពណាមួយចាប់បានកងទ័ពវៀតណាមនោះ ដែលឃើញទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំអត់ដែលឃើញ អត់ដែលឃើញចាប់បាន។ អើ! គេចាប់នៅកៀនកោះចន្លោះសមរភូមិណា ខ្ញុំអត់ដឹងទេ ប៉ុន្តែឲ្យខ្ញុំឃើញផ្ទាល់ អត់ដែលឃើញ។

**ស៖** ចុះតើលោកធ្លាប់ឃើញជនស៊ីវិល ឬក៏អតីតទាហានទួគីជាដើម។ល។ តើធ្លាប់ឃើញអ្នកទាំងអស់នោះឆ្លងកាត់ប្រទេសវៀតណាម ចូលមកក្នុងប្រទេសកម្ពុជាដើម្បីស្វែងរកការជ្រកកោនណា

---

មួយដែរទេ?

**ប្រធានអង្គជំនុំ៖**

មិនមែនទាហានទួគីទេ ទាហានធីវគី អ្ហ៎? មានទាហានទួគីឯណាមកនៅខ្មែរ។

[១៤:៤១:៣៧]

**លោក នីកូឡាស គូមជែន៖**

<អរគុណលោកប្រធាន។>

**2-TCW-1065៖**

**ឆ៖** អរគុណ។ រឿងអំមិញខ្ញុំក៏មិនច្បាស់ដែរ មិនដឹងឆ្លើយថាម៉េច។ ហើយបើសួរអំមិញនេះ វាសួរដល់ឆ្នាំ៧០ហើយ មិនមែនសួរបច្ចុប្បន្ននេះទេអាហ្នឹងវាសួរពីឆ្នាំ៧០ហើយ វាត្រឡប់ទៅក្រោយវិញ។ ហើយបើឆ្នាំ៧០ហ្នឹង វាមានធីវគី វាចូលមកមានមែន។ អាហ្នឹង អរគុណ មានប៉ុណ្ណឹងទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នេះជាកំហុសរបស់ខ្ញុំហើយ អ៊ីចឹងខ្ញុំមកសួរបញ្ជាក់ពេលវេលាឲ្យបានច្បាស់។ ខ្ញុំសួរនៅពេលដែលលោកនៅជាមួយវរៈ១៥៦នេះ គឺលោកថា<>ពីឆ្នាំ៧៦ <រហូត>ដល់ចុងឆ្នាំ៧៨ នៅពេលដែលលោកនៅជាមួយវរសេនាធំ១៥៦នៅភូមិភាគបូព៌ានោះ តើលោកធ្លាប់ឃើញប្រជាជនរត់ចេញមកពីវៀតណាមដែរទេ? អាចថាជាជនស៊ីវិល អាចថាជាទាហានធីវគី កាលពីជំនាន់នោះចាញ់សង្គ្រាមអ៊ីអ៊ីចឹង ដល់ហើយក៏ឆ្លងកាត់ទឹកដីចូលកម្ពុជា ដែលឃើញដែរ?

**ឆ៖** អត់មានទេ អត់មានរត់ចូលមកខាងក្នុងទេ អត់មានទេ។ នេះចំពោះមុខព្រួញខ្ញុំអត់មានទេ ប៉ុន្តែបើចូលខាងណា ខាងណាទៀត ក៏ខ្ញុំមិនដឹងទេ។ បាទ អរគុណ។

**ស៖** ឥឡូវនិយាយអំពីថ្ងៃទី២៥ ឧសភា ឆ្នាំ៧៨ លោកបាននិយាយថា លោកបានទទួលព័ត៌មានអំពីការចាប់ខ្លួនទ្រង់ទ្រាយធំ គឺចាប់មេបញ្ជាការ ហើយមានមនុស្សម្នាក់<ខ្ញុំជឿថាឈ្មោះ ផន គាត់មានរបួស>ដៃ <ហើយបានរត់គេចខ្លួន>។ តើលោកមាន<មធ្យោបាយអីដើម្បី>ទំនាក់ទំនងជាមួយកងទ័ព<>ភូមិភាគបូព៌ា<ទេ>កាលនោះ <ដូចជាតាមរយៈវិទ្យុទាក់ទង> តាមរយៈសារទូរលេខ នីរសារ ឬក៏តាមរយៈអ្វីដែរ?

[១៤:៤៣:៥៨]

**ឆ៖** អរគុណ។ សូមជម្រាបជូនបន្តិចពេលនោះ។ ពេលហ្នឹង និយាយរួម យើងក៏ចាប់ផ្តើម

ប្រយុទ្ធនៅវៀតណាមកំពុងតែជាប់ដៃគ្នា កងទ័ពបូព៌ា អ៊ីចឹងភូមិភាគកណ្ដាលដែលមក ដែលវាយពីខាងក្រោយហ្នឹងមកនេះ បើហៅមេបញ្ជាការកងពល កងវរសេនាធំ វរសេនាតូច អនុសេនាធំ ត្រឹមអនុសេនាធំ មកប្រជុំនៅកន្លែងកងពលលេខ៤ហ្នឹង នៅក្រែកហ្នឹង។ ដល់មកប្រជុំហ្នឹងទៅ ពេលនោះគឺគេមកទាំងអស់ ដោយឡែកតែខ្ញុំមួយទេអត់មក អ៊ីចឹងអត់មក គេឱ្យនៅចាំនៅសមរភូមិអ៊ីចេះ នៅចាំសមរភូមិ។ ដល់នៅចាំសមរភូមិអ៊ីចឹង គេហៅមកប្រជុំពេលហ្នឹង ដល់ហៅមកប្រជុំ មានបានប្រជុំឯណា វាៗចាប់ទាំងអស់កម្មាភិបាលនោះ។ ដល់ចាប់បណ្ដើរមក បណ្ដើរមក ប្រធានកងអនុសេនាធំម្នាក់ឈ្មោះ សុខហ្នឹង ចេះតែដើរមក គេយកក្រមារុំមុខជិតហើយ។ ដើរមកដល់ថាអង្គុយ ដល់អង្គុយ វានៅដល់អណ្ដូង វាឱ្យអង្គុយ។ ដល់អង្គុយ អានោះបូតក្រមាទៅ ឃើញអណ្ដូងមុខ លោតផុតពីអណ្ដូងទៅមុខ។ ដល់លោតផុតហ្នឹង វាបាញ់ពីក្រោយ ត្រូវដៃ។ អាត្រូវដៃហ្នឹងហើយ ដែលរត់ទៅដល់ខ្ញុំនៅសមរភូមិនោះ ថាបង ពួកប៉ុល ពត ក្បត់ហើយ បាញ់ហើយហើយ បាញ់សម្លាញ់យើងហើយ។ ឥឡូវមេៗទាំងអស់ហ្នឹងចាប់ វាចាប់យកចងដាក់ខ្នោះអស់ហើយ។ រឿងហ្នឹងហើយបានខ្ញុំមានផែនការហៅសេនាធិការគ្រប់កងវរសេនាតូចប្រជុំដើម្បីរៀបចំ។ ពេលនុ៎ងខ្ញុំមិនថានេះ ខ្ញុំប្រជុំហ្នឹង ប្រុងប្រជុំរើកម្ទេចនៅកន្លែងកងពលតែម្ដង។ ប៉ុន្តែដោយសារអី? ដោយសារកងវរសេនាតូចមួយចំនួនគេមិនឯកភាព។ គេថាបើរើ បើរើនៅកន្លែងនុ៎ង យើងទៅណា? ខ្ញុំរឿងទៅណាមិនទៅណា សឹមដោះស្រាយសិន គិតសិន។ អានេះយើងនិយាយវាក្បត់ទៅហើយ វាចាប់អ្នកដឹកនាំដែលនៅប្រយុទ្ធសមរភូមិអស់ទៅហើយហ្នឹង ហើយយើងទុកធ្វើអី។ ដល់អ៊ីចឹងគេមិនព្រមព្រៀងទៅ ខ្ញុំក៏សម្រេចថាឥឡូវ បងប្អូនណាទៅណាក៏ទៅៗ។ អ្នកណាទៅចូលព្រៃជាមួយខ្ញុំចូល អ្នកណាមិនចូល ទៅផ្ទះទៅៗ។ ដល់មួយចំនួនទៅ ក៏ទៅផ្ទះវិញទៅ។ ដល់អ៊ីចឹងខ្ញុំឱ្យស៊ើបការណ៍ហ្នឹង ទៅដកពីខ្សែត្រៀម៣០០មកឱ្យខ្ញុំ ដកកម្លាំងតែត្រៀមប្រយុទ្ធវៀតណាមនុ៎ង ឱ្យដកមក ដើម្បីចូលព្រៃវៃ ប៉ុល ពត វិញ។ បាទ អាហ្នឹងប៉ុណ្ណឹង សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឱ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងបី។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៧ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណដល់លោកសាក្សីដែលលោកបានពន្យល់ថា លោកដឹងអំពីការសម្លាប់ទាហានមេបញ្ជាការ ហើយនិងការនាំទាហាន៣០០នាក់<ចូលទៅក្នុងព្រៃ>។ ដូច្នេះ ខ្ញុំចង់សួរនៅពេលដែលលោកនាំទាហានទៅក្នុងព្រៃ នៅ<ថ្ងៃទី២៥> ខែឧសភា ៧៨ តើនៅពេលនោះ លោកមានទំនាក់ទំនងជាមួយនឹង សោ ភឹម ឬក៏មេបញ្ជាការបូព៌ាដទៃទៀតដែរឬទេ ឬមួយក៏លោកធ្វើសកម្មភាពនេះ តែម្នាក់ឯងទេ?

2-TCW-1065៖

**ឆ៖** អរគុណ។ ចំពោះកងទ័ព៣០០នាក់ដែលទៅជាមួយខ្ញុំនៅព្រៃអត់មាន គ្មានអ្នកណាទេ មានតែខ្ញុំម្នាក់ឯងគត់ អត់មានទំនាក់ទំនងជាមួយអ្នកណាទេ គឺដាច់អស់ហើយ បញ្ចប់ត្រឹមហ្នឹង។ អរគុណ។

**ស៖** តើមានអ្នកដទៃណាចូលរួមជាមួយលោកទេ? ឧទាហរណ៍ថាតើមានជនស៊ីវិល ឬក៏ទាហានណាផ្សេងនៅពេលដែលមកជួបជាមួយក្រុមលោក ហើយគេចូលជាមួយលោកទេ?

**ឆ៖** អរគុណ។ អត់មានទេ ទាហានសុទ្ធតែម្តង ចេញពីសមរភូមិមក។

**ស៖** កាលពីម្សិលមិញលោកនិយាយថា លោកបានវាយប្រហារដើម្បីជួយសង្គ្រោះជនស៊ីវិល តើលោកបាននិយាយអ៊ីចឹងមែនទេ? ថាតើក្រុមរបស់លោកមានបានព្យាយាមជួយជនស៊ីវិលដទៃដែរឬទេ?

[១៥:០៣:៤២]

**ឆ៖** អរគុណ។ ពេលដែលខ្ញុំរៀបចំកងទ័ពចំនួន៣០០នាក់ នៅព្រៃអាងុយហើយ ពេលនោះក៏មានស៊ីវិលមួយចំនួនដែរ ដែលរត់ចូលព្រៃហ្នឹង មានៗស៊ីវិលហ្នឹង។ អ៊ីចឹងខ្ញុំក៏ចាប់ផ្តើមបើកយុទ្ធនាការ

01377440



មក វៃពួកប៉ុលពតវិញ នៅតាមតំបន់ តាមអង្គភាពមួយៗ វៃវិញ។ ថាយើងបើមិនវៃទេ យើងអត់មានអី ទាំងអស់ បើយើងវៃយើងរស់ បើមិនវៃយើងស្លាប់។ អ៊ីចឹងដាច់ខាត ត្រូវតែប្រយុទ្ធតែម្តង ប្រយុទ្ធយក អង្ករ ប្រយុទ្ធយកថ្នាំពេទ្យ ដើម្បីធ្វើជាទុន និងប្រយុទ្ធបន្តទៀត។ សូមអរគុណ។

**ស៖** ជនស៊ីវិលដែលបានរត់គេច ហើយបានចូលជាមួយលោកហ្នឹង តើហេតុអ្វីបានជាពួកគាត់ រត់គេច លោកអាចពន្យល់បានទេ?

**ឆ៖** អរគុណ។ ជនស៊ីវិលដែលរត់គេចទៅពួននៅនឹងព្រៃ ដូចថាភូមិមួយៗគេរកចាប់ ដល់ចាប់ គាត់រត់ពួនទៅទាំងគ្រួសារៗ នៅក្នុងព្រៃហ្នឹងតែម្តង លាក់ខ្លួននៅហ្នឹង។ អ៊ីចឹងបើលាក់ខ្លួនអ៊ីចឹង គាត់ បានស្អីហូប អ៊ីចឹងមានតែយើងជួយចិញ្ចឹមគាត់ ជួយចិញ្ចឹមគាត់។ អរគុណ មានតែប៉ុណ្ណឹង។

**ស៖** ដូច្នេះដើម្បីបញ្ជាក់ឲ្យបានច្បាស់ តើអ្នកណាដែលគេចង់ចាប់ជនស៊ីវិលទាំងអស់នោះ?

**ឆ៖** អរគុណ។ អ្នកដែលចង់ចាប់ស៊ីវិលហ្នឹង គឺភូមិភាគកណ្តាលហ្នឹង ដែលចេញមកហ្នឹងធ្វើ សកម្មភាពចាប់ទាំងស៊ីវិល ចាប់ទាំងទាហាន ចាប់ទាំងអស់។ ត្រង់ហ្នឹងដែលឲ្យធ្វើប្រជាជននៅភូមិភាគ បូព៌ាហ្នឹង គឺនាំគ្នារត់ខ្ចាត់ខ្ចាយទាំងទាហាន ទាំងស៊ីវិលហ្នឹង មិនអាចនៅបានទេ។ ហើយអាវុធក៏ផ្ទុះឡើង គ្រប់ៗក្រសួងមន្ទីរ។ អរគុណ មានប៉ុណ្ណឹង។

[១៥:០៥:៥០]

**ស៖** នៅក្នុងពេលដែលលោកនៅក្នុងព្រៃ ឬក៏ក្រោយខែមករា ៧៩ នៅពេលដែលលោកត្រឡប់ មកកម្ពុជាវិញ តើលោកមានដែលឃើញកន្លែងសម្លាប់មនុស្ស ឧទាហរណ៍ដូចថាលោកឃើញសាកសព មនុស្សត្រូវបានគេសម្លាប់ ឬក៏ឃើញការសម្លាប់មនុស្សអ្វីដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំវិលពីវៀតណាមមក ដែលវៃចូលមកភ្នំពេញមក ខ្ញុំអត់ឃើញទេ សាកសព ប៉ុន្តែឃើញរណ្តៅ រណ្តៅដែលគេវៃ ទម្លាក់ក្នុងរណ្តៅឃើញ ប៉ុន្តែដោយសព សាកសពនៅលើ គោកលើអី អត់ដែលឃើញទេ ប៉ុន្តែក្នុងរណ្តៅមួយៗគឺឃើញ។ ប្រជាពលរដ្ឋគេប្រាប់។ អរគុណ។

**ស៖** តើលោកអាចប្រាប់បានទេ ថាតើរណ្តៅសាកសពដែលឃើញមានសាកសពនៅក្នុងរណ្តៅ ហ្នឹង ថានៅកន្លែងណា? ហើយ<តើគេ>ប្រាប់លោក<អ្វីខ្លះអំពីរណ្តៅទាំងនោះ>?

**ឆ៖** អរគុណ។ រណ្តៅសាកសពហ្នឹងគឺនៅត្បូងឃ្មុំហ្នឹង គឺនៅគឺថាកន្លែងដើមស្វាយហ្នឹង កន្លែង សន្តិសុខ ៗរបស់ស្រុក ប៉ុល ពត ហ្នឹងនៅនុ៎ង កន្លែងសន្តិសុខគេ រណ្តៅមាន ប៉ុន្តែឥឡូវវាលប់ខ្មេចខ្ចីអស់ ហើយ ជិតអស់ហើយ ធ្វើចម្ការធ្វើអីហ្នឹង។ ប៉ុន្តែពីមុនគឺមាននៅក្នុងរណ្តៅហ្នឹងតែម្តង អណ្តូងទម្លាក់ក្នុង

អណ្តូងហ្នឹង។ បាទអរគុណ។

**ស៖** តើនៅក្នុងភូមិ ឃុំ ស្រុក ខេត្តណាទេ លោកចាំទេ?

**ឆ៖** ខ្ញុំសូមជម្រាបជូនថាអ៊ីចេះ។ ភូមិខ្ញុំភ្លេច មិនដឹងជាភូមិអី ប៉ុន្តែឃុំៗវិហារល្ហួង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ បច្ចុប្បន្នស្រុកត្បូង ខេត្តត្បូងឃ្មុំ។ ប៉ុន្តែនៅក្នុងឃុំវិហារល្ហួង នៅកន្លែងនុ៎ង ប៉ុន្តែភូមិមិនដឹងឈ្មោះភូមិអីខ្ញុំភ្លេចហើយ។

[១៥:០៨:០៩]

**ស៖** នៅពេលដែលលោកធ្វើការនៅមន្ទីរពេទ្យរបស់កងវរសេនាធំ១៥៦នោះ តើ<គ្រួសារ> លោកនៅទីណាដែរ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំដែលនៅមន្ទីរពេទ្យ១៥៦ហ្នឹង គឺកន្លែងអង្គភាព១៥៦ នៅកន្លែងស្រុករាល់ថ្ងៃនេះ ស្រុកពញាក្រែកនេះ។ ហើយចំពោះខ្ញុំនៅខាងកើតមន្ទីរពេទ្យហ្នឹង នៅភូមិហ្លួច ហ្លួចក្រោម។ ខ្ញុំនៅហ្នឹង មន្ទីរពេទ្យរបស់១៥៦នៅហ្នឹង។ អរគុណ។

**ស៖** នៅពេលនោះ តើលោករៀបការហើយឬនៅ? ហើយតើលោកមានកូនហើយឬនៅ?

**ឆ៖** ខ្ញុំការឆ្នាំ១៩៧២ ខ្ញុំរៀបការរួចហើយ មានកូនហើយ មានកូនបីនាក់។ ហើយកូនយកមកនៅកន្លែងៗភូមិភាគហ្នឹង។ កូនបីនាក់ ប្រពន្ធ និងយាយក្មេកមួយទៀតនៅហ្នឹង។

**ស៖** ចុះប្រពន្ធកូន ហើយនិងយាយក្មេករបស់លោកហ្នឹង តើពួកគាត់មានបញ្ហាអីកើតឡើងដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** អរគុណ។ ចំពោះយាយក្មេក ប្រពន្ធខ្ញុំ និងកូនបីនាក់ហ្នឹង គាត់រស់នៅក្នុងអង្គភាពកសិកម្មរបស់ភូមិភាគ។ អ៊ីចឹងពេលដែលផ្ទុះអាវុធឡើងហ្នឹង ថ្ងៃ២៥ ខែ៥ ៧៨ហ្នឹង គាត់ក៏បានរត់ចេញពីហ្នឹងទៅស្វាយរៀងវិញ ទៅស្រុកកំណើតរកឪពុកនៅអីនោះ រកឪពុក។ ដល់ទៅដល់ស្វាយរៀងហ្នឹង គេកៀរពីនុ៎ងទៅពោធិ៍សាត់តែម្តង ទៅលាចនោះ។ អ៊ីចឹងប្រជាពលរដ្ឋពីលាចមក គេមកប្រាប់ខ្ញុំថា នោះទាំងប្រពន្ធ ទាំងកូន ពួកប៉ុល ពត វាកៀរទៅនៅលាច នៅពោធិ៍សាត់ហើយ។ រឿងហ្នឹងហើយដែលខ្ញុំទៅតាមរកហ្នឹង បានគេចោទប្រកាន់ហ្នឹង។ អរគុណ។ ឥឡូវសម្លាប់អស់ហើយ គេសម្លាប់អស់ហើយ គ្មានសល់ទេ។

[១៥:១១:០០]

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាគេសម្លាប់ពួកគាត់?

**ឆ៖** អរគុណ។ ចំពោះខ្ញុំអត់ដឹង ព្រោះខ្ញុំនៅសមរភូមិ អត់ដឹងទេ។ ប៉ុន្តែអានេះវាគោលការណ៍របស់គេ ប្រជាពលរដ្ឋមិនមែនតែគ្រួសារខ្ញុំទេ អ្នកណាក៏ដោយតែគៀរទៅគេសម្លាប់ហើយ វាត្រូវតែសម្លាប់ចោលតែម្តង។ នយោបាយគេអ៊ីចឹង មិនមែនថាអ្នកឯងធ្វើការ ឬមិនធ្វើការ ឬអង្គភាព មិនអង្គភាពទេ ត្រូវសម្លាប់ ក៏កូនក្មេងក៏វាសម្លាប់ចោលដែរ។ នេះជាផែនការរបស់វា។ បាទ អរគុណ។

**ស៖** លោកសាក្សី លោកបាននិយាយអំពីការនៅសមរភូមិមុខជាមួយនឹងកងវរសេនាធំ១៥៦ ដោយលោកថាលះបង់ជីវិត ដើម្បីវាយប្រយុទ្ធជាមួយវៀតណាមនោះ។ <លោកក៏បានប្រាប់យើងដែរ ថា> លោក<ត្រូវ>បាន<>វៀតណាម<ចាប់ខ្លួន ហើយដាក់គុករយៈពេល៨ខែ ហើយនៅខែវិច្ឆិកា ឆ្នាំ ១៩៧៨> លោកទៅវៀតណាម ដើម្បីសហការរំដោះប្រទេស។ តើលោកអាចពន្យល់បានទេ ហេតុអ្វីបានជាលោកធ្វើដូច្នេះ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា វាជារឿងចម្លែកដែលគាត់សួរសំណួរបែបនេះ លោកប្រធាន។ <ការចាប់ខ្លួនរបស់គាត់ ឬក៏ការកាត់ទោសគាត់ដាក់ពន្ធនាគារ> គឺធ្វើនៅក្នុង៨០, ៨១។ <ដូច្នេះ ចំណុចនេះមិនអាចជាកត្តានៅក្នុងចិត្តគាត់>មុន<ពេលគាត់ទៅវៀតណាមនៅឆ្នាំ៧៨នោះទេ។ វានៅមិនទាន់កើតឡើងនៅឡើយទេ>។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថា វាច្បាស់ណាស់ថា ខ្ញុំគួរតែផ្តល់ហេតុផលដែលថា គាត់មិនគួរជាអ្នកគាំទ្រ<>វៀត-ណាមនោះទេ ព្រោះគាត់<ជាជនរងគ្រោះ>ត្រូវបានគេឃុំខ្លួន<ប្រាំបីខែដោយខុសច្បាប់ ដោយគ្មានការកាត់ទោស>។ ដូច្នេះឥឡូវនេះ យើងត្រូវគិតឲ្យបានច្បាស់។ យើងចង់ស្តាប់ឮសាក្សី ហេតុអ្វីបានជាគាត់ចូលរួមជាមួយវៀតណាម ដើម្បីសហការរំដោះប្រទេសដូច្នេះ?

[១៥:១៣:២១]

**2-TCW-1065៖**

**ឆ៖** អរគុណ។ អ៊ីចឹងលោកសួរអំពីចាប់ពីខែ១២ ឆ្នាំ៧៨ ពេលហ្នឹងដែលខ្ញុំនៅទ័ពនៅនឹងព្រៃហ្នឹង ហើយវៀតណាមហ្នឹង ដែលគេចល័តមួយក្រុមៗ មកជួបអ្នកតស៊ូនៅនឹងព្រៃហ្នឹង បានទំនាក់ទំនងគ្នា ព្រោះខាងក្នុងហ្នឹង ប៉ុល ពត វាចេះតែសម្លាប់បន្តបន្ទាប់ហើយ។ រវាងសមរភូមិវៀតណាម ហើយនិងពួក ប៉ុល ពត ហ្នឹងក៏ចាប់ផ្តើមប្រយុទ្ធគ្នាដែរ ហើយឯខ្ញុំវិញជាអ្នកតស៊ូនៅនឹងព្រៃក៏ប្រយុទ្ធដែរ ប្រយុទ្ធជាមួយ ប៉ុល ពត ដែរ វាអ៊ីចេះ។ ដល់ជួបគ្នាហើយ យើងពិភាក្សាគ្នា ទាំងខាងភាគីវៀតណាម

និងភាគីកម្ពុជាថា យើងបើមិនរួមគ្នារំដោះប្រជាជនកម្ពុជាចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ទេ ឃើញថាប្រជាជនត្រូវតែស្លាប់ទាំងអស់។ អ៊ីចឹងបានយើងសម្រេច ៗត្រូវតែរួមគ្នាធ្វើ។ បើរួមគ្នាធ្វើ យើងត្រូវតែរៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានយើងធ្វើកើត។ ហើយវៀតណាមគេធ្វើ ក៏គេធ្វើអាងកម្លាំងយើងដែរ ព្រោះកម្លាំងក្នុងប្រទេស កម្លាំងនេះជាកម្លាំងគាំទ្រ។ គេក៏មិនមែនមកធ្វើតែកម្លាំងរបស់គេមកវ៉ៃចូល ក៏វ៉ៃមិនបានដែរ វាខុស។ អ៊ីចឹងទាល់តែកម្លាំងអ្នកតស៊ូក្នុងប្រទេសត្រូវគាំទ្រវៀតណាមដែរ ដើម្បីវ៉ៃកម្ទេចកងទ័ព ប៉ុល ពត យកប្រជាជនមកវិញ។ បាទ អរគុណ ខ្លីៗ។

**ស៖** ហេតុអ្វីលោកជឿជាក់ថា ប្រទេសកម្ពុជាចាំបាច់ត្រូវរំដោះចេញពីរបប ប៉ុល ពត? បើទោះបីជាត្រូវការសហការជាមួយបរទេសក៏ដោយ ហេតុអ្វីលោកគិតថា ត្រូវរំដោះប្រទេសចេញពី ប៉ុល ពត បែបនេះ?

[១៥:១៥:១០]

**ឆ៖** អរគុណ។ ហេតុផលមានដែលខ្ញុំត្រូវសហការជាមួយវៀតណាម។ ហេតុរឿងអី ហេតុផលរឿង ប៉ុល ពត នេះវាសម្លាប់ខ្មែរ និងខ្មែរនេះ។ យើងឃើញហេតុផលជាក់ស្តែងអ៊ីចឹង ហើយបើយើងមិនជួយគាត់ទេ ពេលហ្នឹងគាត់ត្រូវស្លាប់ទាំងអស់ ស្លាប់ទាំងអស់។ អ៊ីចឹងមានតែសហការជាមួយវៀតណាមទៅ ដែលគេមានកម្លាំង ដែលគេមានអាវុធយុទ្ធភណ្ឌគ្រប់គ្រាន់នោះ ហើយបើយើងតែខ្មែរអ្នកតស៊ូម្នាក់ឯង ក៏វ៉ៃមិនបានដែរ រឿងហ្នឹង។ ទៅវ៉ៃរំដោះសិន ធ្វើម៉េចយកប្រជាជនឲ្យរួចខ្លួនសិន កុំឲ្យ -- ផុតពីការកាប់សម្លាប់។ សូមអរគុណ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទេ ហើយបើតាមដែលខ្ញុំដឹង ដូចជាខាងដើមបណ្តឹងរដ្ឋប្បវេណី ក៏ប្រហែលជាមិនមានសំណួរដែរមើលទៅ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅ ខាងដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរដែរទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបញ្ជាក់ម្តងទៀតថា ខាងក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី អត់មានសំណួរទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី។ ដំបូងនេះផ្តល់វេទិកាជូនទៅមេធាវីការពារក្តី លោក នួន ជា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

[១៥:១៦:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ការពិតទៅខ្ញុំរំពឹងថាក្រុមខ្ញុំចាប់ផ្តើមនៅថ្ងៃចន្ទទេ ប៉ុន្តែមិនអីទេ ខ្ញុំបានត្រៀមសំណួរគ្រប់គ្រាន់ហើយ រហូតដល់ទៅម៉ោងបួន។ ដូច្នេះខ្ញុំសូមចាប់ផ្តើមសំណួររបស់ខ្ញុំ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាដំបូងសូមជម្រាបសួរលោកសាក្សី ខ្ញុំគឺជាមេធាវីអន្តរជាតិការពារក្តី នួន ជា។ ខ្ញុំសូមចាប់ផ្តើមសួរលោកអំពីមនុស្សមួយចំនួននៅក្នុងភូមិភាគបូព៌ា។ ខ្ញុំគ្រាន់តែចង់សួរថាលោកស្គាល់ មិនស្គាល់ពួកគាត់ តើលោកដឹងតួនាទីរបស់ពួកគាត់ដែរឬអត់ជាដើមនោះ។ ជាដំបូងខ្ញុំសូមសួរលោកមួយថាតើលោកស្គាល់បងប្អូនរបស់ ហេង សំរិន ឈ្មោះ ហេង សំកៃ ដែរឬទេ?

**2-TCW-1065៖**

**ឆ៖** អរគុណ។ លោកបានសួរខ្ញុំ ព្រោះ ហេង សំកៃ នេះ ខ្ញុំក៏ស្គាល់ ធ្លាប់តស៊ូជាមួយគាត់ដែរគឺនៅក្នុងព្រៃហ្នឹង ស្គាល់។ ប៉ុន្តែឥឡូវគាត់ស្លាប់បាត់ទៅហើយ ហេង សំកៃ ហ្នឹង ជាបង ហេង សំរិន។ អានេះស្គាល់កាលរួមចំណែកតស៊ូជាមួយគ្នានៅនឹងព្រៃ។ អរគុណ។

**ស៖** តើលោកមានន័យយ៉ាងម៉េច នៅពេលដែលលោកនិយាយថា ចូលរួមប្រយុទ្ធជាមួយគ្នានោះ? ថាតើលោកអាចបញ្ជាក់ឲ្យបានលម្អិតបន្តិចបានទេ អំពីចំណុចនេះ?

[១៥:១៨:៥៥]

**ឆ៖** អរគុណ។ ចំពោះលោកសួរថា ឲ្យខ្ញុំបញ្ជាក់លម្អិតរឿង ហេង សំកៃ។ ថ្ងៃ២៥ ខែ៥ ៧៨ ហ្នឹង ដែលខ្ញុំរត់ចូលព្រៃហ្នឹង ក៏ទៅជួប ហេង សំកៃ នៅនឹងព្រៃនុំង ត្រូវបង ហេង សំរិន ហ្នឹង គឺរួមចំណែកជាមួយខ្ញុំហ្នឹងដែរ ដើម្បីធ្វើការតស៊ូប្រយុទ្ធនឹងៗពួកភូមិភាគកណ្តាលដែរ នឹងពួកសម្លាប់មនុស្សដែរ គឺ ហេង សំកៃ គឺជួបគ្នាប៉ុណ្ណឹងទេ។ ប៉ុន្តែអត្តសញ្ញាណយ៉ាងម៉េចៗ គឺខ្ញុំអត់ដឹងដែរ ជួបនឹងរយៈពេលខ្លី។ បាទ អរគុណ។

**ស៖** តើ ហេង សំកៃ គាត់នៅឯណាមុនថ្ងៃ២៥ ខែ៥ ៧៨ មែនទេ?

**ឆ៖** អរគុណ។ បើ ហេង សំកៃ ហ្នឹងវាៗទៅជាមួយគ្នា អត់មានទៅមុនទេ។ ត្រឹមមួយរត់ចូលព្រៃហ្នឹង ទៅទាំងអស់ ទៅរួមគ្នាទាំងអស់ ហេង សំកៃ, ហេង សំរិន ទៅទាំងអស់គ្នា។ អត់មានទៅមុនទៅក្រោយ ពួកនុំងសុទ្ធអ្នកតស៊ូក្នុងព្រៃដូចគ្នា។

**ស៖** ខ្ញុំនឹងសួរលោកអំពីចំណុចនេះនៅពេលក្រោយបន្តិចទៀត។ ឥឡូវនេះខ្ញុំចង់សួរលោកអំពីតួនាទីរបស់គាត់នៅក្នុងភូមិភាគបូព៌ាវិញ។ តើគាត់មានតួនាទីអ្វីដែរ?

**ឆ៖** អរគុណ។ ចំពោះ ហេង សំកៃ ព្រោះខ្ញុំ ក្នុងភូមិភាគបូព៌ា ខ្ញុំអត់មានទំនាក់ទំនង។ មិនដឹងគាត់មានតួនាទីស្អី នឹងស្អីក៏ខ្ញុំអត់ដឹង។ កាលណាដឹង ខ្ញុំឆ្លើយជូន បើមិនដឹង ខ្ញុំឆ្លើយមិនដឹង។

[១៥:២១:០៥]

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោកសាក្សី។ មនុស្សម្នាក់ដែលលោក គឺមនុស្សពីរនាក់ដែលលោកស្គាល់នៅក្នុងរូបថតពេលរសៀលនេះ គឺពួកគាត់និយាយអំពី ហេង សំកៃ គឺ ស៊ិន អ៊ុន ដែលជាអង្គរក្សរបស់ សោ ភឹម គឺឯកសារ <E3/10716> <មានលេខ ERN តែជាភាសាខ្មែរទេ គឺ 01340542> គឺគាត់បានរៀបរាប់ថា ហេង សំកៃ គឺជាប្រធានផ្នែកនីរសារ។ ហើយ ណន នីម ដែលជាអង្គរក្ស និងជាអ្នកបើកបរ ឯកសារ E3/ ឯកសារលេខ <E3/10717> ខ្មែរមានលេខ <01340511> បានរៀបរាប់ថា ហេង សំកៃ គឺជាប្រធាននីរសារភូមិភាគ។ តើវាអាចធ្វើឲ្យលោកនឹកឃើញដែរទេ ថាគាត់ហ្នឹងជាប្រធាននីរសារភូមិភាគបូព៌ា?

**ឆ៖** អរគុណ។ បាទ ចំពោះខ្ញុំ វាដាច់ ព្រោះខាងយោធា ហើយខាងនីរសារភូមិភាគ វាដាច់ វាអត់មានការទាក់ទងគ្នាទេ។ អ៊ីចឹងក៏ជួបគ្នា ជួបកាលពេលដែលរត់ចូលព្រៃតស៊ូជាមួយគ្នាទេ។ ប៉ុន្តែការងារពីមុនមក ខ្ញុំអត់បានដឹងដែរ មិនដឹងជាគាត់ធ្វើអី ធ្វើអី ខ្ញុំអត់បានដឹងទេ។ អរគុណ។

**ស៖** មិនអីទេខ្ញុំយល់អំពីចំណុចនេះ។ ឥឡូវនេះខ្ញុំចង់ងាកទៅលើអ្វីដែលលោកនិយាយថា លោកចូលជាមួយគាត់។ ហើយអ្នកសារព័ត៌មានអាមេរិកម្នាក់ដែលត្រូវបានគេតែងតាំងជាអ្នកជំនាញនៅក្នុងសវនាការលើរឿងក្តី ឌុច បានសរសេរសៀវភៅមួយក្បាលដែលមានចំណងជើងថា “សត្រូវបងប្អូន”។ ហើយគាត់បាននិយាយអំពី ហេង សំកៃ គឺឯកសារ E3/2376។ ហើយគាត់បានជួប<សម្ភាសន៍> ជាមួយនឹង ហេង សំកៃ នៅឆ្នាំ<១៩៨១> អង់គ្លេសមានលេខ 00192440, ខ្មែរមានលេខ 00191596 ដល់97, បារាំងមានលេខ <00237111>។ ខ្ញុំសុំអាននូវសម្រង់ទាំងស្រុងតែម្តង ដើម្បីឲ្យយើងយល់ថាខ្ញុំចង់និយាយអំពីអី។ គាត់និយាយថា៖ “ការពិតដែលថា បងរបស់ ហេង សំរិន គឺ ហេង សំកៃ ជាមេ

01377446



ដឹកនាំនៅបូព៌ា<ម្នាក់>ទៀតបានរត់ទៅវៀតណាមដើម្បីជួយចរចា។” ហើយបានដកស្រង់នូវសម្ដីរបស់ ហេង សំរិន៖ “យើងបានដឹងគឺថា ហេង សំរិន បានប្រាប់ខ្ញុំនៅឆ្នាំ៨១ ថាវាមិនអាចផ្តួលរំលំ ប៉ុល ពត ដោយខ្លួនយើងផ្ទាល់បានទេ យើងត្រូវតែស្វែងរកការជួយពីវៀតណាម។ ក្នុងនាមជាប្រធាននីរសារភូមិភាគបូព៌ា ក្នុងការនាំសារពីថ្នាក់ដឹកនាំនីមួយៗ <ក៏ដូចជានាំសារទៅវៀតណាម> គាត់បានស្គាល់វៀតណាមច្បាស់។ អានេះជាផ្នែកសំខាន់មួយសម្រាប់លោក។ ការធ្វើដំណើរទៅព្រំដែននៅខែមករា ៧៨ គាត់បានចូលបានជិះកន្ទុរយ<វៀតណាម>ទៅទីក្រុងហូជីមិញ ហើយគាត់<រួមជាមួយនឹងអ្នកផ្ដាច់ខ្លួនពីខ្មែរក្រហមផ្សេងទៀត>បានចូលទៅសាលាបណ្ដុះបណ្ដាលនគរបាលនៅ<ធូឌុក>។” លោកសាក្សី ខ្ញុំមានសំណួរពីរបីដើម្បីសួរលោក។ ទី១ ច្បាស់ណាស់ថា យោងតាម ចាន់ដា គឺថា ហេង សំរិន គាត់បានចូលទៅវៀតណាមនៅខែមករា ៧៨ រួចទៅហើយ។ តើវាអាចទេដែលថា ហេង សំរិន គាត់ចូលទៅវៀតណាមនៅខែមករា ៧៨ រួចហើយនោះ?

[១៥:២៦:០៥]

**ឆ៖** អរគុណ។ ចំពោះខ្ញុំគឺដឹងរយៈពេលខ្លីណាស់ ព្រោះបានជួប ហេង សំរិន នៅព្រៃរយៈពេលខ្លីណាស់ ជួបនោះ។ ហើយ ហេង សំរិន តាមនិយាយទៅ នៅក្នុងព្រៃមិនទាំងមានអីផង មានគ្នាពីរបីនាក់ហ្នឹង ស្ពាយតែកូនឆ្នាំងមួយដាំបាយហ្នឹង គ្មានឃើញអីផង។ ហើយជាក់ស្ដែង អស់លោកមួយចំនួនក៏លោកដឹងដែររាល់ថ្ងៃហ្នឹង សួរតែអស់លោកមួយចំនួនក៏ដឹងដែរ បងហេង សំរិន – ហេង សំរិន ហ្នឹង។ គាត់មានអី ស្ពាយតែកូនឆ្នាំងមួយ ប៉ុណ្ណឹង ឆ្នាំងក្រហមឆ្នាំងខ្វាន់ហ្នឹង ហើយអ្នកពីរបីនាក់ហ្នឹងចេះតែទៅ មិនដឹងជាទៅណាមកណា ព្រោះខាងខ្ញុំវាអត់មានទំនាក់ទំនងទេ។ រឿងគ្រាន់តែឃើញថា ហ្នឹង ហេង សំរិន គ្រាន់តែប៉ុណ្ណឹង។ អរគុណ។

**ស៖** ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ។ ខ្ញុំគិតថា ភស្តុតាងដែលលោកបានបង្ហាញគឺថា នៅថ្ងៃ ២៥ ឧសភា ៧៨ លោកហើយនិងកងវរៈរបស់លោកបានបះបោរប្រឆាំងពួកខាងមជ្ឈិម គឺលោកនៅព្រៃប្រហែលជាបីបួនខែ មុននឹងទៅវៀតណាម។ ហើយនៅពេលនោះហើយលោកបានជួប ហេង សំរិន។ ប្រសិនបើអ៊ីចឹង តើវាអាចទេថា ហេង សំរិន គាត់នៅវៀតណាមប្រហែលជាប្រាំពីរប្រាំបីខែរួចទៅហើយនោះ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំ អានេះគាត់ជួបផ្ទាល់ អាហ្នឹងជាសម្ដីរបស់គាត់ថា អាហ្នឹងរឿងគាត់ ប៉ុន្តែបើខ្ញុំឃើញថា វាមិនអាចដល់ន៉ុងទេ ព្រោះខ្ញុំជួបហ្នឹងវារយៈពេលខ្លី ហេង សំរិន ហ្នឹង។ ព្រោះខ្ញុំក្ដាប់

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទ័ព ខ្ញុំវ៉ៃ ដល់វ៉ៃទៅ ជួបគាត់នៅព្រៃហ្នឹង ហើយគាត់ក៏គ្មានគ្នាប៉ុន្មានដែរ រត់យកតែរួចខ្លួនដែរហ្នឹង កាលហ្នឹង គ្មានអ្នកណាមានទាហានច្បាំង វាអត់មាន។ ហើយរឿងគាត់ ក៏ខ្ញុំដឹងមិនអស់ដែរ។ សូមអរគុណ។

[១៥:២៨:៣០]

**ស៖** ឥឡូវនេះខ្ញុំចង់ដកស្រង់នូវសម្រង់មួយទៀតពី ហេង សំរិន។ "គឺថាមិនអាចផ្តួលរំលំ ប៉ុល ពត ដោយខ្លួនឯង ដូច្នេះយើងត្រូវតែស្នើសុំជំនួយពីវៀតណាម"។ ថាតើគាត់ធ្លាប់ប្រាប់លោកអំពីគំនិតនេះ ដែរឬទេ? ឬក៏ថាតើលោកធ្លាប់ឮពីអ្នកដទៃ អំពីការព្យាយាមចង់ផ្តួលរំលំ ប៉ុល ពត នៅដើម៧៨ដែរឬទេ? ហើយដោយសារការព្យាយាមនោះមិនបានសម្រេច ទើបពួក<>វៀតណាម<ត្រូវតែចូលអន្ត-រាគមន៍>?

**ឆ៖** អរគុណ។ ចំពោះខ្ញុំវិញ អានេះវាជាគំនិតរបស់គាត់ គាត់និយាយម៉េច ជាពាក្យសម្តីរបស់គាត់ ខ្ញុំមិនជំទាស់ទេ រឿងរបស់គាត់។ តែរឿងវ៉ៃវៀតណាមនេះ ដំបូងឡើយគឺខ្ញុំទេ ដែលមានការទំនាក់ទំនងគ្នានេះ នៅភូមិកន្ទួតនេះ។ ប៉ុន្តែអ្នកដែលទំនាក់ទំនងហ្នឹងវាស្លាប់អស់ ព្រាប វិជ័យ, ព្រាបអីនោះ ក៏ងាប់អស់ទៅហើយ ប៉ុន្តែនៅសល់ម្នាក់ដែរ សមាជិកព្រឹទ្ធសភានោះរាល់ថ្ងៃ។ ហើយទៅសួរគាត់ដឹងហើយរឿងហ្នឹង រឿងទំនាក់ទំនងហ្នឹង ដែលសហការគ្នាវ៉ៃចូលកម្ពុជាដើម្បីសង្គ្រោះប្រជាពលកម្ពុជាហ្នឹង។ ព្រោះកម្លាំងយើងមានកម្លាំងឯណា អ៊ីចឹងមានតែរួមចំណែកជាមួយវៀតណាមទេ ដែលអាចវ៉ៃបាន កម្លាំង ប៉ុល ពត នោះ។ យើងត្រូវតែពឹងគេ រឿងហ្នឹងនោះ។ បានសុខចិត្តទាំងអស់គ្នាហ្នឹង ក៏ទៅទីក្រុងហូជីមិញរៀបចំរណសិរ្សហ្នឹង មានលោក ហេង សំរិន ហ្នឹងជាប្រធានរណសិរ្ស។ ខ្ញុំសូមអរគុណ។

**ស៖** ខ្ញុំនឹងសួរនៅពេលក្រោយបន្តិចទៀត។ ឥឡូវនេះខ្ញុំចង់សួរលោកអំពីកម្មាភិបាលយោធាជាន់ខ្ពស់នៅបូព៌ា។ កាលពីម្សិលមិញលោកនិយាយអំពី ប៉ុល សារឿន ដូច្នេះខ្ញុំចង់សួរថា ប៉ុល សារឿន ជាអ្នកណា? ហើយគាត់មានតួនាទីអ្វីដែរ?

[១៥:៣១:០៧]

**ឆ៖** អរគុណ។ ចំពោះ ប៉ុល សារឿន សម័យប៉ុលពត យើងអត់ដឹងថាតួនាទីគាត់អីទេ ប៉ុន្តែដល់ពេលដល់ចូលព្រៃបានជួបគ្នាកន្លែងនុ៎ង។ ចូលព្រៃវ៉ៃ ប៉ុល ពត ទាំងអស់ហ្នឹងគឺយើងជួបគ្នា។ អ៊ីចឹងពីមុនតួនាទីរបស់គាត់អីទៅណាៗ ខ្ញុំបាទអត់ដឹងទេ។ ហ្នឹងបានស្គាល់គ្នាហ្នឹង ព្រោះមួយចូលព្រៃហ្នឹង។ បាទអរគុណ។

**ស៖** តើគាត់ជាប្រធានសេនាធិការ ឬក៏ជាអនុប្រធានសេនាធិការកងទ័ពភូមិភាគបូព៌ា រួមគ្នា

ជាមួយនឹង ហេង សំរិន ឬក៏យ៉ាងណា?

**ឆ៖** អរគុណ។ ចំពោះ ប៉ុល សារឿន វាដាច់ដោយឡែកផ្សេង មិនមែននៅជាមួយកងពលលេខ ៤ទេ ហើយក៏មិនមែននៅជាមួយលោក ហេង សំរិន ដែរ។ លោក ហេង សំរិន លោកជាប្រធានកងពល គឺជាមេរបស់ខ្ញុំ ប៉ុន្តែ ប៉ុល សារឿន វាផ្សេង។ ពីសម័យមុន មិនដឹងជាគាត់នៅអង្គភាពណា ក៏ខ្ញុំមិនដឹងបានដែរ ប៉ុន្តែជួបគ្នាពេលដែលប្រយុទ្ធនៅក្នុងព្រៃនោះ ទើបយើងស្គាល់គ្នា។ អាហ្នឹងសូមជម្រាបជូនប៉ុណ្ណឹង។ អរគុណ។

**ស៖** តើសព្វថ្ងៃ ប៉ុល សារឿន គាត់ធ្វើអ្វីដែរ លោកដឹងទេ?

**ឆ៖** អរគុណ។ ប៉ុល សារឿន រាល់ថ្ងៃ គាត់នៅខាងសេនាធិការ។

**ស៖** ហើយសព្វថ្ងៃមានមន្ត្រីយោធាជាន់ខ្ពស់ម្នាក់ទៀតឈ្មោះ គន់ គីម លោកស្គាល់ទេ?

[១៥:៣៣:១១]

**ឆ៖** អរគុណ។ លោកមេធាវីសួរ ហើយខ្ញុំក៏ស្គាល់ដែរ ប៉ុន្តែស្គាល់វាមិនដឹង។ ស្គាល់អ៊ីចេះស្គាល់ត្រឹម៧៩នេះ ៧៩នេះស្គាល់។ ព្រោះកន្លងមកហ្នឹងវា គន់ គីម ហ្នឹងវា គាត់ជានៅតួនាទីជាស៊ីវិលទេ ពេលខ្ញុំដែលរំដោះកម្ពុជាហើយ ហើយខ្ញុំមកនៅវត្តជ្រោយហ្នឹង បានខ្ញុំស្គាល់ គន់ គីម គេប្រាប់ថា គន់ គីម។ ប៉ុន្តែ គន់ គីម នេះខ្ញុំគ្រាន់ស្គាល់ប៉ុណ្ណឹង ប៉ុន្តែវាគ្មានការទំនាក់ទំនងអីជាមួយ គន់ គីម អត់មានទេ គ្រាន់បានតែមួយស្គាល់ប៉ុណ្ណឹង។ បាទ អរគុណ។

**ស៖** អ៊ីចឹងនៅក្នុងឆ្នាំ៧៨នោះ គឺថាលោកមិនបានជួបគាត់នៅក្នុងព្រៃទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ត្រឹមត្រូវ អត់បានជួបក្នុងព្រៃទេ។

**ស៖** មនុស្សពីរនាក់ទៀតដែលខ្ញុំចង់សួរលោក តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ ហែម សាមីន ដែរឬទេ?

**ឆ៖** អរគុណ។ ឈ្មោះ ហែម សាមិន នេះខ្ញុំអត់ស្គាល់ទេ។ អត់ស្គាល់ទេ។

**ស៖** តើលោកស្គាល់ ប៉ែន សុវណ្ណ ដែរឬទេ?

**ឆ៖** អរគុណ។ ចំពោះ ប៉ែន សុវណ្ណ ប៉ុន្តែជួបគ្នាម្ដងគត់ កាលនៅព្រៃមេមត់ ជួបម្ដង។ ពេលនោះដែលខ្ញុំចេញពីៗសមរភូមិទៅ ហើយគាត់បើកឡានហ្ស៊ីបA-2 មកសួរហ្នឹង។ ហើយខ្ញុំក៏សួរគាត់ថា ឈ្មោះអី? គាត់ថាឈ្មោះ ប៉ែន សុវណ្ណ។ ជួបតែប៉ុណ្ណឹង ហើយចប់ អត់ដែលជួបគ្នាទៀតទេ។ អាហ្នឹងមុនទៅរៀបចំរណសិរ្ស។ ជួបតែប៉ុណ្ណឹង ហើយក៏ចប់។ អរគុណ។

**សៈ** ខ្ញុំនឹងត្រឡប់មកសួរអំពី ប៉ែន សុវណ្ណ បន្តទៅទៀត។ តើនៅក្នុងឆ្នាំ៧៨ លោកមានបានជួបមនុស្សម្នាក់ឈ្មោះ យស ផល ដែរឬទេ?

**ឆៈ** អរគុណ។ ខ្ញុំមិនដែលជួបទេ ឈ្មោះ យស ផល នោះ។

[១៥:៣៥:៤០]

**ប្រធានអង្គជំនុំ៖**

ទំនងមិនមែន យស ផល ទេ អាចអានខុសទេ។ យស ប៉ោ ពាក្យខ្មែរ មានតែ យស ប៉ោ ទេដែលមាននៅក្នុងឯកសារ។ មានទេ យស ប៉ោ? បើ យស ប៉ោ វិញមានទេ? ស្គាល់ទេ?

**2-TCW-1065៖**

**ឆៈ** អរគុណ។ ចំពោះលោកចៅក្រមបានប្រាប់ខ្ញុំថា ឈ្មោះ យស ប៉ោ ឈ្មោះនេះគឺខ្ញុំឮ ប៉ុន្តែខ្ញុំក៏មិនស្គាល់ដែរ យស ប៉ោ មាន។ មាន យស ប៉ោ ហ្នឹងប៉ុន្តែជួប ខ្ញុំអត់ដែលជួបទេ។ មាន អរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** ចុះ ប៊ូ ថង លោកស្គាល់ឈ្មោះ ប៊ូ ថង ទេ?

**ឆៈ** អរគុណ។ ចំពោះខ្ញុំអារឿងឮៗពាក្យគេនិយាយចេះតែឮហើយ ប៉ុន្តែឲ្យជួបគ្នាផ្ទាល់ អត់ដែលជួបទេ ប៊ូ ថង ហ្នឹង។ ជួបអត់ដែលជួបទេ ប៉ុន្តែគ្រាន់តែឮថា ឈ្មោះ ប៊ូ ថង គឺឮ។

**សៈ** តើលោកស្គាល់ ជា ស៊ីម ដែរឬទេ?

**ឆៈ** អរគុណ។ ជា ស៊ីម ស្គាល់ លោក ជា ស៊ីម គឺស្គាល់ច្បាស់តែម្តង។

**សៈ** តើលោកអាចជម្រាបអង្គជំនុំជម្រះបានអ្វីខ្លះដែរ ចំពោះ ជា ស៊ីម នេះ?

[១៥:៣៧:១៦]

**ឆៈ** អរគុណ។ ខ្ញុំសូមជម្រាបបន្តិច ជម្រាបដោយខ្លីៗ។ និយាយបើលោក ជា ស៊ីម ឈ្មោះដើមគាត់មិនមែន ជា ស៊ីម ទេ ហៅ ជា សាឡាត់។ ហើយនៅសម័យមុននោះ សម័យពីឆ្នាំ៧៥, ៧៦ហ្នឹងគាត់ជាអនុប្រធានស្រុក មិនមែនប្រធានទៀត។ នៅស្រុកពញាក្រែកនេះ អនុប្រធាន។ តាធ្មេញស គេហៅតាធ្មេញស តាំងប្រធាន ហើយ ជា សាឡាត់ ហ្នឹងគាត់អនុប្រធានទេ ឈ្មោះដើមគាត់ ប៉ុន្តែក្រោយមកគាត់ដាក់ឈ្មោះ ជា ស៊ីម, ខ្ញុំស្គាល់។ ប៉ុន្តែកិច្ចការងាររបស់គាត់ គឺខ្ញុំអត់មានដឹងទេ អត់មានទាក់ទងដែរ ប៉ុន្តែស្គាល់គាត់។ ហើយពេលដែលចូលទៅរៀបចំរណសិរ្សហ្នឹងក៏ជួបគ្នា ក៏ស្គាល់គ្នាដែរ។ មានតែប៉ុណ្ណឹងទេ បាទ អរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** <ណាន នឹម> ឯកសារ E3/10717 ខ្មែរ ERN 01340448 បាននិយាយថា ប្រពន្ធរបស់ ជា ស៊ឹម គឺជាប់សាច់ឈាម ជាមួយនឹង សោ ភឹម។ ត្រឹមត្រូវដែរឬទេ?

**ឆៈ** អរគុណ។ បើនិយាយប្រពន្ធ ជា ស៊ឹម អត់មានជាប់សាច់ឈាម សោ ភឹម ទេ ព្រោះ សោ ភឹម ហ្នឹងស្រុកកំណើតគាត់នៅស្វាយរៀង នៅស្វាយរៀងតើ! គាត់នៅឃុំគគីសោម ស្រុកស្វាយទៀប ខេត្តស្វាយរៀង។ ហើយ ជា ស៊ឹម គាត់នៅអីនេះនុំង រឿងអីទៅជាប់សាច់ឈាម អត់មានទេ។ ហើយ សោ ភឹម នុំង មានបងប្អូនតែបីនាក់ទៀត។ បាទ អរគុណ។

**សៈ** តើអាចទេ ដែលថាប្រពន្ធ សោ ភឹម ជាប់សាច់ឈាមជាមួយនឹងប្រពន្ធ ជា ស៊ឹម?

[១៥:៣៩:៣៩]

**ឆៈ** អរគុណ។ រឿងនេះខ្ញុំក៏ដឹងមិនច្បាស់ដែរ ព្រោះប្រពន្ធ សោ ភឹម យាយការ៉ូៗ គាត់នៅខាង នេះ ខាងព្រៃវែងនេះ ហើយប្រពន្ធ ជា ស៊ឹម ក៏នៅខាងហ្នឹងដែរ ខាងក្របៅនេះ។ អ៊ីចឹងរឿងជាប់មិនជាប់ ក៏ខ្ញុំមិនដឹងដែរ។ ប៉ុន្តែមួយប្រពន្ធទាំងសងខាង គឺមុំខាងហ្នឹង គ្រាន់តែដឹងប៉ុណ្ណឹងទេ។ អរគុណ។

**សៈ** ខ្ញុំសួរឈ្មោះមនុស្សបីនាក់ទៀត ចប់ហើយលោកសាក្សី។ តើលោកស្គាល់ឈ្មោះ កែវ ចិន្តា ដែរឬទេ?

**ឆៈ** អរគុណ។ កន្លងមកហ្នឹង កែវ ចិន្តា ខ្ញុំគ្រាន់តែឮឈ្មោះទេ ប៉ុន្តែខ្ញុំអត់មានទំនាក់ទំនងទេ កែវ ចិន្តា ហ្នឹង។ ពេលដែលរំដោះកម្ពុជាហើយហ្នឹង ឮ កែវ ចិន្តា ហ្នឹង ប៉ុន្តែការទំនាក់ទំនងពាក្យសម្តី ទៅវិញទៅមក អត់មានទេបាទ។ អរគុណ ប៉ុន្តែឮ។

**សៈ** តើគាត់ជាចៅក្រមកាត់សេចក្តីនៅក្នុងការកាត់សេចក្តីឆ្នាំ១៩៧៩ ក្នុងសវនាការកំបាំងមុខ កាត់ទោស ប៉ុល ពត និង អៀង សារី នោះ ឬក៏មិនមែនទេ?

**ឆៈ** បាទ រឿងនេះ ខ្ញុំអត់ដឹងទេ។ បាទ សូមអរគុណ អត់ដឹងទេ។

**សៈ** តើលោកស្គាល់ឈ្មោះ អ៊ុក ប៊ុនឈឿន ដែរឬទេ?

**ឆៈ** អរគុណ។ បើលោក អ៊ុក ប៊ុនឈឿន ហ្នឹងវាស្គាល់ច្បាស់ណាស់ គឺនៅក្នុងព្រៃជាមួយគ្នា កិច្ចការងារអីទំនាក់ទំនងកិច្ចការងារ ក៏ជាមួយគ្នា ហើយជិះយន្តហោះទៅរៀបចំរណសិរ្ស ក៏ជាមួយគ្នា ដែរ គឺជាមួយគ្នា រឿងគឺដឹងច្បាស់លាស់ណាស់ អ៊ុក ប៊ុនឈឿន ក្រៅពីហ្នឹង ខ្ញុំអត់ដឹងទេ។

**សៈ** ហើយមនុស្សចុងក្រោយ គឺឈ្មោះ ម៉ាត់ លី លោកស្គាល់ឬទេ?

**ឆៈ** ចំពោះ ម៉ាត់ លីៗ នេះជនជាតិអ៊ីស្លាមទេ។ ខ្ញុំស្គាល់ ប៉ុន្តែខ្ញុំអត់មានទំនាក់ទំនងទេ ព្រោះ

ជួបគ្នានៅនឹងព្រៃទាំងអស់ ម៉ាត់ លី ក៏ជួបដែរ ប៉ុន្តែស្លាប់ទៅហើយ ម៉ាត់ លី នោះៗ ជនជាតិអ៊ីស្លាម។ កន្លងមកហ្នឹង ទៅជាសមាជិកសភានោះ ម៉ាត់ លី ហ្នឹង។ បាទ អរគុណ គឺស្គាល់។

[១៥:៤២:៣២]

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ ឥឡូវខ្ញុំចូលទៅសួរអ្វីដែលលោកបានឆ្លើយក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកគឺ E3/10667 សំណួរចម្លើយលេខ៣។ លោកក៏បាននិយាយអំពីអំឡុងពេលពីខែវិច្ឆិកា ៧៨ ហើយលោកបាននិយាយថា វៀតណាមបានឲ្យក៏បង្កើតបក្សប្រឆាំងដែលហៅថា "រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា"។ តើលោកអាចរៀបរាប់អំពីកិច្ចប្រជុំដែលលោកបានចូលរួមនៅពេលដែលបង្កើតរណសិរ្សនេះបានដែរឬទេ?

**ឆ៖** ពេលនោះ រវាងភាគីនៅក្នុងកម្ពុជា និងភាគីវៀតណាម ក៏បានព្រមព្រៀងគ្នា ថាយើងត្រូវតែរៀបចំរណសិរ្សសាមគ្គី រៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីសង្គ្រោះប្រជាជនឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ហ្នឹង។ អ៊ីចឹងក៏ព្រមព្រៀងគ្នាហ្នឹងទាំងអស់គ្នា មិនមែនតែវៀតណាមមួយទេ ឯកម្ពុជាក៏អ៊ីចឹងដែរ ព្រមព្រៀងគ្នា នឹងរៀបចំ ៗបង្កើតរណសិរ្សហ្នឹងហើយ បានយើងចាប់ផ្តើមបើកយុទ្ធនាការ រំដោះប្រទេសកម្ពុជា។ បាទអរគុណ។

**ស៖** តើការជួបប្រជុំនេះ ជួបនៅពេលណា? ហើយនៅកន្លែងណាដែរ?

**ឆ៖** អរគុណ។ ព្រោះការជួបប្រជុំ នៅប្រជុំនៅទីក្រុងហូជីមិញនោះ កន្លែងទីក្រុងហូជីមិញនោះ ដែលរៀបចំរណសិរ្សនោះ។ អរគុណ។

**ស៖** តើការប្រជុំនោះពីរលើក មួយប្រជុំនៅទីក្រុងហូជីមិញ និងជំនួបប្រជុំមួយទៀតនៅដើមឆ្នាំ ៧៩ នៅស្នួល? សំណួរចម្លើយលេខ៥៖ "ដែលថានៅដើម<ឆ្នាំ៧៩> នៅពេលខ្ញុំនៅឡុងយ៉ាវ កងទ័ពខ្មែរ<និងវៀតណាម>បានបង្កើតរណសិរ្ស<២ធ្នូ> គឺថានៅក្នុងស្រុកស្នួល ខេត្តក្រចេះ ដើម្បីរៀបចំការប្រយុទ្ធវាយចូលមកក្នុងប្រទេសកម្ពុជា<>" តើកិច្ចប្រជុំមានតែមួយលើកទេ ឬក៏កិច្ចប្រជុំមានពីរលើក មួយលើកនៅហូជីមិញ មួយលើកនៅស្នួល នៅ<ថ្ងៃ២ធ្នូ> ក្នុងឆ្នាំ៧៨នោះ?

[១៥:៤៥:៥២]

**ឆ៖** អរគុណ។ នៅទីក្រុងហូជីមិញក៏យើងប្រជុំ ដើម្បីរៀបចំគោលនយោបាយរណសិរ្ស។ ប៉ុន្តែដល់ប្រជុំនៅស្នួល ប្រជុំអី ប្រជុំនៅ២ធ្នូនេះ? គឺប្រជុំមានព្រះសង្ឃ មានប្រជាពលរដ្ឋគាំទ្រ គាំទ្រ ដើម្បីបើកយុទ្ធនាការនៅ២ធ្នូនេះ នៅស្រុកស្នួលនេះ ហ្នឹងប្រជុំលើកទី២។ អ៊ីចឹងមានព្រះសង្ឃ មានអី មាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រជាពលរដ្ឋសព្វបែបសព្វយ៉ាង មានកងទ័ពអី ដើម្បីវាយចូលកម្ពុជា។ បាទ អររគុណ។

**ស៖** បាទ ច្បាស់ហើយ។ តើលោកអាចរៀបរាប់អំពីកិច្ចប្រជុំលើកទី១ នៅក្រុងហូជីមិញ? តើនៅឯហូជីមិញហ្នឹង ប្រជុំនៅត្រង់កន្លែងណា? ហើយអ្នកចូលរួមជាអ្នកណាខ្លះដែរ? ហើយនិយាយគ្នាអំពីអ្វីដែរ?

**ឆ៖** អររគុណ។ ប្រជុំនៅទីក្រុងហូជីមិញ ខ្ញុំស្គាល់អត់អស់ទេ មិនដឹងជាពីណាខ្លះ ពីណាខ្លះ អត់ស្គាល់ទេ។ ពេលនោះវាចម្រុះ។ ប៉ុន្តែការប្រជុំនោះអត់មាននិយាយអីទេ និយាយតែរៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិហ្នឹង ហើយគោលការណ៍១១(ខ) និង៨(ខ) និយាយតែប៉ុណ្ណឹង។ ធ្វើម៉េចឯកភាពគ្នាទាំងកម្ពុជា ទាំងវៀតណាម។ ប៉ុន្តែដល់ទៅមកធ្វើមិទ្ទីង មកធ្វើនៅ៧មករា នៅស្នួលនេះវិញ។ អាហ្នឹងមានព្រះសង្ឃ មានប្រជាពលរដ្ឋអីគាំទ្រ គគ្រឹកគគ្រេង។ តែប៉ុណ្ណឹងទេ សូមអររគុណ។

**ស៖** កិច្ចប្រជុំនៅហូជីមិញហ្នឹង លោកនៅចាំទេថា អ្នកណាខ្លះចូលរួមក្នុងកិច្ចប្រជុំនេះ?

**ឆ៖** បាទ អររគុណ ព្រោះខ្ញុំអត់បានចាំទេ វាភ្លេចអស់ហើយឥឡូវ អត់បានចាំទេ។

[១៥:៤៧:៥៩]

**ស៖** ខ្ញុំយល់ហើយ។ ប៉ុន្តែអ្នកដែលខ្ញុំទើបតែសួរឈ្មោះមុននេះ មាន ហេង សំរិន, ហេង សំកែ, ជា ស៊ីម, ប៉ែន សុវណ្ណ អីចឹងឈ្មោះដែលខ្ញុំទើបសួរលោកនេះ តើពួកគាត់ទាំងនោះ មានវត្តមានក្នុងជំនួបនៅហូជីមិញនោះដែរឬទេ?

**ឆ៖** បាទប្រជុំនៅក្រុងហូជីមិញ មាន។ ប៉ុន្តែនៅក្រៅពីនេះ នៅមានច្រើនទៀត ប៉ុន្តែអត់ស្គាល់។

**ស៖** តើលោកនៅចាំបានទេថា រយៈពេលប៉ុន្មានដែរ មុនពេលប្រជុំធំនៅ២ធ្នូ? តើវាជាជំនួបប្រជុំហ្នឹង គឺជួបប្រជុំមុនកិច្ចប្រជុំនៅហូជីមិញមួយសប្តាហ៍ ឬក៏ពីរសប្តាហ៍? <តើប្រជុំពីរបីខែមុន? តើលោកចាំទេ?>

**ឆ៖** អររគុណ។ ព្រោះខ្ញុំអត់បានចាំទេ ព្រោះប្រជុំនៅ២ ធ្នូ គឺប្រជុំហ្នឹងគឺបង្ហាញ ១ថាយើងត្រូវបង្កើតរណសិរ្សមួយ មានព្រះសង្ឃ មានឧបាសក មានកងទ័ព សព្វបែបសព្វយ៉ាង គឺបង្ហាញឲ្យប្រជាពលរដ្ឋដឹង។ គ្រាន់តែប៉ុណ្ណឹងទេ នៅ២ ធ្នូ ហ្នឹង។ អររគុណ។

**ស៖** តើត្រឹមត្រូវដែរឬទេ កិច្ចប្រជុំ<>២<ធ្នូ>នៅស្នួល តើមានអ្នកចូលរួមនោះរហូតទៅដល់រៀបពាន់នាក់មែនទេ?

**ឆ៖** អររគុណ។ ប៉ុន្តែមនុស្សរយមិនដឹងពាន់ម្តង ព្រោះខ្ញុំអត់បានរៀបទេ ប៉ុន្តែមានប្រជុំនៅស្នួល

កន្លែង២ធ្នូ។ ហើយរាល់ថ្ងៃគេដាក់ភូមិហ្នឹង គេដាក់ភូមិ២ធ្នូ តែម្តង។ បាទ អរគុណ។

**ស៖** តើនៅពេលហ្នឹប្រជុំនៅក្នុងចម្ការកៅស៊ូ នៅភាគខាងកើតនៃក្រុងស្នួលនោះមែនទេ?

**ឆ៖** អរគុណ។ គឺនៅចម្ការកៅស៊ូ ខាងកើតស្នួលហ្នឹង ត្រឹមត្រូវហើយ។

**ស៖** តើលោកនៅនឹកឃើញទេ នៅពេលនោះ តើគេមានច្រៀងបទចម្រៀងជាតិថ្មីដែរទេ នៅក្នុងកិច្ចប្រជុំ ២ ធ្នូ ៧៨ នោះ?

[១៥:៥០:៥៣]

**ឆ៖** អរគុណ។ ពេលនោះបទចម្រៀងហ្នឹង និយាយរួមឈ្មោះហ្នឹងឈ្មោះ ចាន់ ហើយ ចាន់ វាជាសិល្បៈរបស់ភូមិភាគបូព៌ាហ្នឹង "ឱភ្នំពេញអើយ" ហ្នឹង ច្រៀង១បទហ្នឹង។ ឈ្មោះ ចាន់ នារីនុំង នារី ចាន់ ជាសិល្បៈរបស់ភូមិភាគបូព៌ាហ្នឹង ជាអ្នកច្រៀង។ អរគុណ។

**ស៖** ចុះទង់ជាតិថ្មី ដែលមានពណ៌លឿង និងពណ៌<ក្រហម> គេមានដាក់បង្ហោះដែរឬទេ លោកនឹកឃើញទេ?

**ឆ៖** អរគុណ។ ទង់ជាតិពេលហ្នឹងគឺយើងបានបង្ហោះតើ នៅកន្លែង២ធ្នូហ្នឹង មាន ទង់ជាតិនោះមានដោតនៅកន្លែង២ធ្នូនោះ។

**ស៖** តើលោកនៅនឹកឃើញទេ សមាជិក១៤នាក់នៃគណៈកម្មាធិការមជ្ឈិមនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាហ្នឹង គឺថាត្រូវបានបង្កើតឡើងក្នុងពេលប្រជុំនោះតែម្តង។ លោកនឹកឃើញទេ?

**ឆ៖** អរគុណ។ ឥឡូវខ្ញុំភ្លេចបាត់អស់ហើយ មិនដឹងទៅណាទេ នឹកឃើញៗ ប៉ុន្តែមិនដឹងជាអ្នកណា អ្នកណា ភ្លេចឈ្មោះអស់ហើយ ដល់វាយូរពេក។ បាទ ភ្លេចឈ្មោះអស់ហើយ អរគុណ។

**ស៖** ខ្ញុំយល់ហើយ។ តើប្រធានរណសិរ្ស ហេង សំរិន មានអានកម្មវិធីរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានេះដែរឬទេ?

**ឆ៖** អរគុណ។ លោក ហេង សំរិន បានអានរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានអានហើយនិងផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋដឹង។ បាទ អរគុណ។

[១៥:៥៣:០៣]

**ស៖** តើលោកនៅចាំបានទេ ថាមានអ្នកដែលមានបណ្តាស័ក្តិខ្ពង់ខ្ពស់វៀតណាមហ្នឹង បានចូលរួមក្នុងកិច្ចប្រជុំនោះដែរឬទេ?

**ឆ៖** អរគុណ។ មានចេះមានអ្នកបណ្តាស័ក្តិ ប៉ុន្តែខ្ញុំអត់បានស្គាល់ឈ្មោះទេ អត់បានស្គាល់ទេ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

នៅខ្ទុំងវាមានកងទ័ពកម្ពុជាក៏មាន វាមានកងទ័ពវៀតណាម ចម្រុះគ្នា ប៉ុន្តែមិនបានស្គាល់ឈ្មោះគេ។ អរគុណ។

**សៈ** ចុះឈ្មោះវៀតណាមម្នាក់ ឈ្មោះ ឡឺ ឌុកតូ លោកអាចនៅនឹកឃើញ ឬក៏អាចស្គាល់គាត់ទេ?

**ប្រធានអង្គជំនុំ៖**

ឡេ ឌឹកថ ស្គាល់ទេ?

**2-TCW-1065៖**

**ឆៈ** អរគុណ។ ជនឈ្មោះ ឡេ ឌឹកថ ហ្នឹង ខ្ញុំបាទគ្រាន់តែឮទេ គ្រាន់តែឮឈ្មោះ ឡេ ឌឹកថ វៀតណាមហ្នឹង ប៉ុន្តែយើងអត់ដែលជួបគាត់ទេ។ ប៉ុន្តែឮ យើងឮ គេនិយាយថា ឡេ ឌឹកថ ប៉ុន្តែអត់ដែលជួបទេ។ បាទ អរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** នៅពេលដែលលោក ហេង សំរិន បញ្ចប់សុន្ទរកថារបស់គាត់ទៅ តើលោកមានបានឃើញគាត់ដើរសំដៅទៅ ឡេ ឌឹកថ ហើយដើម្បីនិយាយជាមួយគាត់ ស្វាគមន៍ពីអ្វីមួយដែលទេ លោកមានឃើញទេ?

[១៥:៥៤:៥៩]

**ឆៈ** អរគុណ។ ចំពោះរូបខ្ញុំផ្ទាល់ ខ្ញុំអត់បានឃើញទេ អត់បានឃើញ។

**សៈ** តើត្រឹមត្រូវដែរឬទេ ដែលថាអ្នកដែលខ្ញុំបានសួរឈ្មោះគាត់ហ្នឹង ហើយលោកថាលោកស្គាល់ហ្នឹង មានវត្តមាននៅកិច្ចប្រជុំ<>២<ធ្នូ>ក្នុងស្រុកស្នួល នៅអតីតទឹកដីរបស់ភូមិភាគបូព៌ានោះដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ គឺត្រឹមត្រូវ។

**សៈ** ខ្ញុំចូលទៅប្រធានបទថ្មីមួយទៀត។ ម្សិលមិញគឺថាគេបានបង្ហាញសារទូរលេខមួយចំនួន។ លោកប្រធានបានបង្ហាញសារទូរលេខឲ្យលោកមើល គឺសារទូរលេខដែលចុះហត្ថលេខាដោយឈ្មោះ ឆុន ហើយលោកក៏បាននិយាយអំពីសារទូរលេខនេះម្តងទៀតនៅព្រឹកមិញនេះ។--

**ឆៈ** អរគុណ។ *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់! អត់ទាន់សួរផង ចាំស្តាប់សំណួរសិន!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ម្សិលមិញលោកបានឆ្លើយថា អត់ស្គាល់ឈ្មោះ ឌុន នេះទេ។ ឌុន នេះតាមពិតទៅ ឌុន នេះតាមពិតទៅ គឺ សោ ភឹម នេះតែម្តង បើថាអ៊ីចឹង តើលោកភ្ញាក់ផ្អើលទេ?

[១៥:៥៦:៤១]

**2-TCW-1065៖**

**ឆ៖** អរគុណ។ ទោះបីលោកថា សោ ភឹម ក៏ខ្ញុំអត់ជឿដែរ ព្រោះគ្មានអ្នកណាដែលឮហៅថា សោ ភឹម ហ្នឹងឈ្មោះ ឌុន នេះអត់មានទេ។ ព្រោះយើងមើល មើលសំណុំឯកសារទាំងអស់ ដែលរាយការណ៍ទៅជូនៗទៅឈ្មោះ អ៊ំនួន, អ៊ំអីនោះ សុទ្ធតែឈ្មោះ ឌុន ទាំងអស់ ប៉ុន្តែធាតុពិត ឌុន ហ្នឹងមិនមែនៗឈ្មោះ សោ ភឹម ទេ។ សោ ភឹម ហ្នឹងឈ្មោះគេហៅក្រៅ សោ ភឹម ប៉ុន្តែខាងក្នុងគេហៅ សោ យ៉ាន់ ហើយ ឌុន ហ្នឹងមិនមែនទេ។ ហើយលោកថាៗឈ្មោះ ឌុន ខ្ញុំអត់ជឿ ខ្ញុំបដិសេធ។

**ស៖** ភាគីទាំងខាងសហព្រះរាជអាជ្ញា ខាងយើងខ្ញុំហ្នឹង គឺមានការយល់ស្របគ្នាហើយថា ឌុន ហ្នឹងគឺ សោ ភឹម ហ្នឹងហើយ។ ប៉ុន្តែឥឡូវចូលទៅប្រធានបទថ្មីទៀតចុះ។ សំណួរចុងក្រោយមុននឹងយើងបញ្ចប់ថ្ងៃនេះ។ តើឈ្មោះ ហៃ សូ ជាមន្ត្រីយោធាជាន់ខ្ពស់ម្នាក់ លោកស្គាល់ទេ មន្ត្រីយោធាជាន់ខ្ពស់វៀតណាម លោកស្គាល់ដែរ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំអត់បានស្គាល់ទេ ឈ្មោះ ហៃ សូ អត់ស្គាល់។

**ស៖** តើលោកធ្លាប់បានឃើញ សោ ភឹម និយាយជាមួយនឹងកម្មាភិបាលវៀតណាម ទោះបីជាចុងឆ្នាំ៧៧ក្តី ឬក៏ដើមឆ្នាំ៧៨ក្តី លោកធ្លាប់ឃើញទេ ឃើញគាត់និយាយជាមួយកម្មាភិបាលវៀតណាមទេ?

**ឆ៖** អរគុណ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំមិនដែលឃើញទេ មិនដែលឃើញ សោ ភឹម និយាយជាមួយវៀតណាម អត់ដែលឃើញទេ។

[១៥:៥៨:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសាក្សី។ សវនាសការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើ

នៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការដាក់បង្ហាញឯកសារគន្លឹះរបស់ភាគីពាក់ព័ន្ធទៅនឹងអង្គហេតុជម្លោះប្រដាប់អាវុធ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី សវនាការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាបន្តទៀត។ ហើយអង្គជំនុំជម្រះក៏សូមអរគុណដែល លោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី សវនាការស្តាប់សក្ខីកម្មសាក្សីរូបនេះនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីមកបន្តផ្តល់ប្រឹក្សាសាក្សីរូបនេះនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត។

ហើយឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោកសាក្សីនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់ត្រឡប់ចូលរួមផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០០ នាទី)*